កម្ពុជាប្ដេជ្ញាជំរុញកំណើនសេដ្ឋកិច្ចឱ្យកើនជាង ៥ភាគរយ នៅឆ្នាំ២០២២ <ទំព័រ៖៨

រដ្ឋាភិបាលឥណ្ឌា ចុះអនុស្សរណៈយោគយល់ជាមួយអង្គការការិតាសកម្ពុជា <ទំព័រ៖១៦


# អ្នកនាំសារ
# the messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី១២

ខែ មីនា | ឆ្នាំ ២០២២ | លេខទី ១៤៩

www.catholiccambodia.org/km/ www.facebook.com/RVAKHMER/ https://khmer.rvasia.org/

March, 2022 | #149


## អគ្គសញ្ញាជ្រមុជទឹកក្នុងព្រះសហគមន៍កាតូលិក

នៅក្នុងរាត្រីបុណ្យចម្លងក្នុងឆ្នាំ២០២២នេះ ព្រះសហគមន៍កាតូលិកទាំងបីភូមិភាគមានមនុស្សពេញវ័យចំនួន១៩១នាក់ ដែលត្រៀមខ្លួនដើម្បីទទួលអគ្គសញ្ញាជ្រមុជទឹក ដែលក្នុងនោះមាននៅភូមិភាគភ្នំពេញចំនួន៩៥នាក់ ភូមិភាគបាត់ដំបង ចំនួន៤៧នាក់ និងភូមិភាគកំពង់ចាម ចំនួន ៤៩នាក់។ <ទំព័រ៖ ១៧&១៩






យើងបានស្តាប់ និងមើលរឿងរ៉ាវជាច្រើនក្នុងព្រឹត្តិការណ៍ពិភពលោក ដែលពេលនេះ កំពុងផ្តោតសំខាន់លើ ព្រឹត្តិណ៍ក្តៅកំពុងកើតមានឡើងនៅតំបន់អឺរ៉ុប ដោយសារវិបត្តិ រុស្ស៊ី និងអ៊ុយក្រែន។ វិបត្តិនេះដ៏ធំនេះ បានជះឥទ្ធិពលយ៉ាងខ្លាំងលើសេដ្ឋកិច្ចពិភពលោក និងការរស់នៅរបស់មនុស្សទាំងអស់ផងដែរ។ វិបត្តិដែលបង្កជាការបង្ហូរឈាម ទាំងកងទ័ព និងជនស៊ីវិល បណ្តាលឱ្យមនុស្សរាប់ពាន់នាក់បានស្លាប់ រាប់ម៉ឺននាក់បានរត់ចេញពីផ្ទះសម្បែង ។ គ្រាប់ផ្លោងបានកំពុងបាញ់តគ្នាមិនដាច់រៀងរាល់ថ្ងៃ ជិត២ខែមកហើយ។

រុស្ស៊ីនៅតែប្រកាន់ជំហររបស់ខ្លួន រារាំង អ៊ុយក្រែន ចូលក្នុងសហភាពអឺរ៉ុបនិងក្នុងសម្ពន្ធមិត្តអង្គការណាតូ ដែលបានបញ្ជាក់យ៉ាងច្បាស់ៗថា អាចបង្ករគ្រោះថ្នាក់ដល់រុស្ស៊ីនាពេលអនាគត។ ចំណែកអ៊ុយក្រែននៅតែប្រកាន់ជំហរ មិនចុះរណបជាមួយរុស្ស៊ីនោះឡើយ ទោះបីមានការគំរាមកំហែង។ ការជួបចរចារជាច្រើនលើកត្រូវបរាជ័យ មិនអាចជៀសវៀងការបង្ហូរឈាមបាន។ ចំណែកលោកខាងលិចមានមហាអំណាចធំៗ ដូចជាបារាំង ចក្រភពអង់គ្លេស កាណាដា សហរដ្ឋអាមេរិក អាល្លឺម៉ង់... បានដាក់ទណ្ឌកម្ម បង្កកទ្រព្យសម្បត្តិលើប្រទេសរុស្ស៊ី ដើម្បីការពារអ៊ុយក្រែន។ ជាងនេះក៏បានផ្តល់ថវិកា និង យោធបរិក្ខាទំនើបៗជាច្រើន ដែលមានតម្លៃរាប់ពាន់លានដុល្លារអាមេរិកដល់ប្រទេសអ៊ុយក្រែន ដើម្បីប្រយុទ្ធជាមួយនឹងរុស្ស៊ីវិញដែរ។

ព្រឹត្តិការណ៍ ដែលនាំឱ្យយើងម្នាក់មានសំណួរថា តើការកសាងសន្តិភាពក្នុងតំបន់ជាអ្វី? តើវិបត្តិអ៊ុយក្រែន-រុស្ស៊ី មកពីអ្វី?

មានមនុស្សជាច្រើនបានសម្តែងការសោកស្តាយ និងប្រឆាំងនិងការវាយលុកចូលប្រទេសអ៊ុយក្រែន ពីសំណាក់ប្រទេសរុស្ស៊ី និងបានផ្តោលទោសប្រទេសរុស្ស៊ី ជាពិសេសលោកប្រធានាធិបតី វ្លាឌីមៀរ ពូទីន។ មានមនុស្សមួយចំនួនទៀត បានលើកឡើងនូវគំនិតមួយផ្ទុយមកវិញថា វិបត្តិនេះកើតឡើងកាន់តែធ្ងន់នោះបណ្តាលមកពីប្រទេសលោកខាងលិច សហភាពអឺរ៉ុប និងសហរដ្ឋអាមេរិក ជាអ្នកនៅពីក្រោយខ្នង។

ទោះបីជាយ៉ាងណា អ្នកនាំសារគ្រាន់តែអាចជម្រាបបានថា ប្រទេសនីមួយៗមានគោលការណ៍និងនិន្នាការនយោបាយរៀងខ្លួន និងអាស្រ័យលើមេដឹកនាំផងដែរ។ ប៉ុន្តែគ្រាន់តែទាញចំណាប់អារម្មណ៍របស់លោកអ្នក បងប្អូន ឱ្យពិចារណាលើអង្គហេតុ និងសេចក្តីដែលមានកើតឡើង មិនប្រកាន់មួយ រើសយកមួយនោះឡើយ។ ដោយយើងក្រលេកមកមើលអំពីប្រវត្តិសាស្ត្រនៃកម្ពុជាកាលពីជាង៤០ឆ្នាំមុន។ កម្ពុជា មានសន្តិភាពដូចពេលបច្ចុប្បន្ន គឺត្រូវប្រើពេលវេលាដ៏វែងឆ្ងាយ និងឆ្លងកាត់នូវទុក្ខវេទនាយ៉ាងខ្លោចផ្សារបំផុត ជាពិសេស ក្នុងរបប៣ឆ្នាំ ៨ខែ ២០ថ្ងៃ របស់ក្រុមប៉ុលពត។ ទោះបី ប៉ុលពត បានសម្លាប់មនុស្ស រាប់លាននាពេលនោះ ហើយបានកងទ័ពវៀតណាម មកវាយផ្តួលរំលំរបបនេះចេញពីកម្ពុជា ក៏នៅតែមានមហាអំណាចជួយផ្តល់អាវុធ គាំទ្រខ្មែរក្រហម ប្រឆាំងជាមួយរដ្ឋាភិបាល និងកងព័ទវៀតណាមផងដែរ រហូតដល់មានការចរចារ និងកិច្ចព្រមព្រៀងសន្តិភាពក្នុងឆ្នាំ១៩៩១ ហើយមានការបោះឆ្នោតជាថ្មីក្នុងឆ្នាំ១៩៩៣ ដែលមានបាវនា ជាតិ សាសនា ព្រះមហាក្សត្រ ឡើងវិញ។ ជាងនេះសន្តិភាពបានពេញលេញនៅឆ្នាំ១៩៩៨ ក្រោមនយោបាយឈ្នះរបស់សម្តេចតេជោហ៊ុនសែន។ សូមរួមគ្នាបន្តថែរក្សាសន្តិភាពនេះជានិច្ច ទោះបីម្នាក់ៗមាន និន្នាការនយោបាយណាក៏ដោយ។

សម្តេចប៉ាបហ្វ្រង់ស៊ីស្កូ នៅក្នុងសារលិខិត សម្រាប់ទិវាទូរគមនាគមន៍ពិភពលោក បានជំរុញឱ្យមានការយកចិត្តទុកដាក់ស្តាប់គ្នាទៅវិញទៅមក ដោយត្រចៀកនៃដួងចិត្ត។ ទ្រង់ បានបញ្ជាក់ថា តាមពិតទៅ យើងកំពុងបាត់បង់សមត្ថភាពក្នុងការស្តាប់អ្នកដែលនៅចំពោះមុខយើង ទាំងនៅក្នុងទំនាក់ទំនងធម្មតានៃទំនាក់ទំនងប្រចាំថ្ងៃ និងនៅពេលពិភាក្សាអំពីបញ្ហាសំខាន់បំផុតក្នុងសង្គម។ ទន្ទឹមនឹងនេះ ការស្តាប់កំពុងឆ្លងកាត់ការអភិវឌ្ឍថ្មីដ៏សំខាន់មួយក្នុងវិស័យទំនាក់ទំនង និងព័ត៌មាន តាមរយៈសារជាសំឡេងផ្សេងៗដែលមាន ដែលបម្រើដើម្បីបញ្ជាក់ថាការស្តាប់នៅតែមានសារៈសំខាន់ក្នុងការទំនាក់ទំនងរបស់មនុស្ស។

ការស្តាប់ក្នុងសង្គមមានតម្លៃជាងពេលណាៗទាំងអស់ លើសជំងឺរាតត្បាតដ៏យូរ។ កន្លងទៅមានចំណុចជាច្រើនដែលមិនទុកចិត្តចំពោះ "ព័ត៌មានផ្លូវការ" អំពី "ជំងឺឆ្លង" ដែលពិភពលោក កំពុងតស៊ូកាន់តែខ្លាំងឡើងដើម្បីឱ្យមានភាពជឿជាក់ និងតម្លាភាព។ យើងត្រូវស្តាប់ និងស្តាប់ឱ្យបានស៊ីជម្រៅ ជាពិសេសចំពោះ អ្វីៗកំពុងកើតនៅក្នុងសង្គម ដែល នាំឱ្យមានការធ្លាក់ចុះ ឬរាំងស្ទះដំណើរសេដ្ឋកិច្ចជាច្រើនសព្វថ្ងៃ។

ដូច្នេះការស្តាប់ និងសន្ទនាគ្នាមានសំខាន់ណាស់ ដែលនាំមកនូវសុខដុមរមនា និងសេចក្តីសុខសាន្ត ដូចគ្រីស្តទូតប៉ូល បានលើកឡើងថា ជំនឿកើតមកពីសេចក្តីដែលយើងបានស្តាប់ រីឯសេចក្តីដែលយើងបានស្តាប់នោះកើតមកពីព្រះបន្ទូលរបស់ព្រះគ្រីស្ត។ ព្រះគ្រីស្តជាសេចក្តីពិត ដែលមកពីព្រះជាម្ចាស់ ជាប្រភពនៃសេចក្តីសុខសាន្តគ្រប់យ៉ាង៕

*លី សុវណ្ណា*

ចាងហ្វាង : លោក លី សុវណ្ណា
សេចក្តីប្រកាសលេខ៖ ០៦០/១៩ ព.ម.រ.ល.អ/ ១៥-មករា-២០១៩
ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ
Tel/Fax : (855) 23 224 120
Email : csccambodia@gmail.com / Website : www.catholiccambodia.org
Email : catholicphnompenh@gmail.com / Website : www.catholicphnompenh.org
https://www.facebook.com/CatholicCambodia / https://www.facebook.com/CatholicPhnomPenh
Formation, Dailouge, Cooperation
ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក



# នាយករដ្ឋមន្ត្រីកម្ពុជា ៖ អត្រាឈឺនិងស្លាប់ដោយជំងឺរបេងរបស់ប្រជាជនកម្ពុជាមានការថយចុះច្រើន ប៉ុន្តែត្រូវបន្តយកចិត្តទុកដាក់

*អត្ថបទ៖ អមរិន្ទ ជានុត*

កម្ពុជាបានសម្រេចសមិទ្ធផលគួរជាទីមោទនៈក្នុងការប្រយុទ្ធនឹងជំងឺរបេងក្នុងរយៈពេល ប៉ុន្មានឆ្នាំកន្លងមកនេះ ខណៈដែលកាលពី២០ឆ្នាំមុន ប្រទេសកម្ពុជាស្ថិតក្នុងចំណោមប្រទេសដែលមានអត្រា អ្នកកើតជំងឺរបេងខ្ពស់ជាងគេក្នុងពិភពលោក តែក្នុងរយៈពេលយ៉ាងខ្លីកម្ពុជាបានក្លាយជាប្រទេសគំរូមួយ សម្រាប់ពិភពលោកចំពោះការងារកំចាត់ជំងឺរបេងយ៉ាងសកម្មនិងប្រកបដោយប្រសិទ្ធភាព។

លទ្ធផលដ៏គាប់ប្រសើរនេះបានកើតចេញពីកិច្ចខិតខំប្រឹងប្រែងរួមគ្នារបស់ប្រជាជាតិខ្មែរ ដែលក្នុងនោះរាជរដ្ឋាភិបាលបានពង្រីកសេវាពិនិត្យ និងព្យាបាលជំងឺរបេងតាមយុទ្ធសាស្ត្រដូតស៍នៅគ្រប់មន្ទីរពេទ្យបង្អែក មណ្ឌលសុខភាព និង ប៉ុស្តិ៍សុខភាពទាំងអស់ រួមទាំងថ្នាក់សហគមន៍ផងដែរនៅទូទាំងប្រទេស។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងថា ៖ «យើងក៏បានធ្វើការស្រាវជ្រាវ និងការព្យាបាលជំងឺរបេងជូនប្រជាជនដោយឥតបង់ថ្លៃ ដែលកិច្ចការនេះ មានការរីកចម្រើនគួរឱ្យកត់សម្គាល់ និងជាហេតុធ្វើឱ្យអត្រាឈឺនិងស្លាប់ដោយសារជំងឺរបេងក្នុងប្រទេសកម្ពុជាយើងមានការធ្លាក់ចុះយ៉ាងខ្លាំងច្រើនជាងប្រទេសដទៃ»។



ជាក់ស្តែងអត្រាស្លាប់បានថយចុះពី ៤២ករណីក្នុង ចំណោមប្រជាជន ១០០ ០០០នាក់ នៅឆ្នាំ២០០០ មកត្រឹម ២០ករណី ក្នុងចំណោមប្រជាជន ១០០ ០០០នាក់ ក្នុងឆ្នាំ២០២០ ដែលមានអត្រាធ្លាក់ចុះស្មើនឹង៥២%។រីឯអត្រាកើតមានជំងឺថ្មី (អាំងស៊ីដង់) បានធ្លាក់ចុះ ពី៥៧៥ករណីក្នុងចំណោមប្រជាជន ១០០ ០០០នាក់ នៅឆ្នាំ២០០០ មកដល់ ២៧៤ករណី ក្នុងចំណោមប្រជាជន ១០០ ០០០នាក់ នៅឆ្នាំ២០២០ ដែលស្មើនឹង ៥៣%។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាក់ថា កម្ពុជាបានសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សពាក់ព័ន្ធនឹងការកាត់បន្ថយអត្រាឈឺ និងស្លាប់ដោយសារជំងឺរបេងនេះរួចហើយ នៅមុនកាលកំណត់ ៤ឆ្នាំ។ ជោគជ័យរបស់កម្ពុជាក្នុងការកំចាត់ជំងឺរបេង គឺជាស្នាដៃមួយដែលមានប្រទេសក្នុងចំនួនតិចតួចប៉ុណ្ណោះ អាចសម្រេចបាន។

ទោះបីជាកម្ពុជាទទួលបានជោគជ័យយ៉ាងនេះក៏ដោយ ក៏ប្រមុខរាជរដ្ឋាភិបាលកម្ពុជារូបនេះយល់ថាប្រទេស កម្ពុជានៅមានអត្រាឈឺ និងស្លាប់ដោយសារជំងឺរបេងខ្ពស់នៅឡើយបើប្រៀបធៀបនឹងបណ្តាប្រទេស មួយចំនួនទៀត និងនៅមានមនុស្សច្រើននៅឡើយ ដែលនៅពុំទាន់បានទទួលសេវា។

លោកមានប្រសាសន៍ថា ៖ «បញ្ហានេះតម្រូវឱ្យយើង ត្រូវបង្កើនល្បឿននៃកិច្ចខិតខំប្រឹងប្រែងបំពេញកិច្ចការបន្ថែមទៀត ដើម្បីកាត់បន្ថយឱ្យបានកាន់តែច្រើនថែម ទៀតនូវអត្រាឈឺនិងស្លាប់ដោយសារជំងឺរបេង ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៃកម្ពុជា និងសកលលោក»។

ជំងឺរបេង គឺជាការឆ្លងមេរោគបាក់តេរីដែលឆ្លងតាមរយៈការស្រូបនូវដំណក់ទឹកតូចៗពីការក្អក ឬកណ្តាស់របស់អ្នកដែលមានមេរោគរបេង។ វាប៉ះពាល់ខ្លាំងទៅលើសួត ប៉ុន្តែវាក៏អាចប៉ះពាល់ដល់ផ្នែកផ្សេងទៀតនៃរាងកាយ រួមមាន ក្បាលពោះ ក្រពេញ ឆ្អឹង និងប្រព័ន្ធប្រសាទ។ លើសពីនេះ ជំងឺរបេង គឺជាជំងឺដែលបណ្តាលឲ្យក្លាយទៅជាជំងឺធ្ងន់ធ្ងរ ក៏ប៉ុន្តែជំងឺនេះក៏អាចព្យាបាលបាន ប្រសិនបើទទួលការព្យាបាលបានទាន់ពេលវេលា។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាក់ថា ទាំងអស់គ្នាចាំបាច់ត្រូវបន្ត និងរួមគ្នាជំរុញបន្ថែមការយកចិត្តទុកដាក់លើបញ្ហាជំងឺរបេង ដោយមិនអាចមើលរំលងនូវចំណុចសេសសល់នេះបានឡើយ ដើម្បីបន្តលើកកម្ពស់សុខភាព គុណភាពនៃការរស់នៅនិងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។

លោកថា ៖ «យុទ្ធនាការទិវារបេងពិភពលោកឆ្នាំ២០២២នេះ នឹងបន្តបំផុសឱ្យមនុស្សទាំងឡាយនៅលើសកលលោកឱ្យមានការយល់ដឹងបន្ថែម និងធ្វើសកម្មភាពដោយរួមគ្នានឹងមានលក្ខណៈសកម្មជាងមុន ដើម្បីឱ្យអ្នកសង្ស័យកើតជំងឺរបេងគ្រប់គ្នាទទួលបាននូវការធ្វើរោគវិនិច្ឆ័យទាន់ពេលវេលានិងព្យាបាលជាសះស្បើយ ហើយនៅថ្ងៃអនាគត យើងនឹងឃើញ ពិភពលោកមួយដែលគ្មានជំងឺរបេង និងគ្មានអ្នកស្លាប់ដោយសារជំងឺរបេងទៀតទេ»។

លោកស្រី លី អាយលែន តំណាងអង្គការសុខភាពពិភពលោកប្រចាំកម្ពុជា បានធ្វើការកោតសរសើរ និងអបអរសាទរយ៉ាងស្មោះស្ម័គ្រចំពោះក្រសួងសុខាភិបាល ជាពិសេសមជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន ចំពោះការខិតខំប្រឹងប្រែង និងសមិទ្ធិផលដ៏អស្ចារ្យក្នុងការបង្ការ និងគ្រប់គ្រងជំងឺរបេង។

លោកស្រី លី អាយលែន បានបន្ថែមថា៖ «យើងត្រូវការការគាំទ្របន្ថែមទៀតដើម្បីឱ្យការឆ្លើយតបរត់មកត្រូវគន្លងវិញ និងបំបាត់ផលប៉ះពាល់ធ្ងន់ធ្ងរនៃជំងឺកូវីដ-១៩។ មេដឹកនាំពិភពលោកបានប្តេជ្ញាបញ្ចប់ជំងឺរបេងនៅឆ្នាំ ២០៣០ ប៉ុន្តែយើងត្រូវការវិធានការបន្ទាន់ដើម្បីធ្វើឱ្យគោលដៅនេះក្លាយជាការពិត»។

ទោះបីជាមានបញ្ហាប្រឈមទាំងនេះក៏ដោយ កម្ពុជាបានប្តេជ្ញាចិត្ត និងពន្លឿនកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួន ដើម្បីកាត់បន្ថយផលប៉ះពាល់នៃជំងឺកូវីដ-១៩រួមទាំងការធានាថា បទអន្តរាគមន៍បច្ចុប្បន្ន និងសេវាជំងឺរបេង ត្រូវបានពង្រឹង និងរក្សា។

តំណាងអង្គការWHOរូបនេះថា ៖ «យើងនឹងបន្តធ្វើការយ៉ាងជិតស្និទ្ធជាមួយក្រសួងសុខាភិបាល មជ្ឈមណ្ឌលជាតិកំចាត់រោគរបេង និងហង់សិន សហគមន៍ដែលរងផលប៉ះពាល់ ដើម្បីពង្រីកការឆ្លើយតបចំពោះជំងឺរបេងប្រកបដោយភាពច្នៃប្រឌិតដោយប្រកាន់យកគោលការណ៍ណែនាំ និងអនុសាសន៍ថ្មីរបស់អង្គការសុខភាពពិភពលោក និងជំរុញសន្ទុះនៃវឌ្ឍនភាពឆ្ពោះទៅរកការបញ្ចប់ជំងឺរបេងនៅឆ្នាំ ២០៣០»៕

# វត្តមាននៃកូនដំរីព្រៃ និងកូនដំរីក្នុងស្រុកគឺជាក្តីសង្ឃឹមនៃការអភិរក្សសត្វដំរីអាស៊ីនៅកម្ពុជា

*អត្ថបទ៖ អមរិន្ទ ជានុត*

ដំរីញីឈ្មោះជីប៉ាល់ដែលត្រូវបានដំរីព្រៃឈ្មោលមួយក្បាលគៀងចូលព្រៃអស់រយៈពេល ២ សប្តាហ៍មុននឹងត្រឡប់មកកាន់ទីតាំងអភិរក្សវិញក្នុងខេត្តមណ្ឌលគិរីបានផ្តល់កំណើតដល់កូនដំរីញីមួយក្បាលកាលពីចុងខែមីនា ឆ្នាំ២០២២ កន្លងទៅនេះប្រកប ដោយភាពភ្ញាក់ផ្អើលព្រោះមិននឹកស្មានថាដំរីញីជីប៉ាល់មានផ្ទៃពោះឡើយ។

«ជីប៉ាល់» ជាដំរីស្រុកញីតែមួយគត់នៅខេត្តមណ្ឌលគិរី មានអាយុ ៣៥ ឆ្នាំ ទើបបង្កើតបានកូនញីមួយក្បាលឈ្មោះនាង«ជីពេជ្រ» ដែលជាកូនដំរីស្រុកកាត់ព្រៃមួយក្បាល ដែលទើបនឹងកើតលើទឹកដីខេត្តមណ្ឌលគិរី។ ដាក់ឈ្មោះជីពេជ្រដោយសារតែកូនដំរីញីមួយក្បាលនេះពិតជាមានតម្លៃមិនអាចកាត់ថ្លៃបាន។

កញ្ញា Jemma Bullock ប្រធានអង្គការ ELIE ធ្វើការងារលើការអភិរក្សសត្វដំរី បានលើកឡើងថា រូបនាងពិតជាមានសេចក្តីរំភើបរីករាយបំផុត ព្រោះជាលើកទីមួយហើយដែលមានកូនដំរីស្រុកកាត់ព្រៃនៅលើទឹកដីនៃខេត្តមណ្ឌលគិរី។ កញ្ញាបានពន្យល់ថា មូលហេតុដែលដាក់ឈ្មោះ «ជីពេជ្រ» គឺដោយសារកូនដំរីញីនេះមានតម្លៃស្មើគ្រាប់ពេជ្រមួយគ្រាប់ដែលបានចាប់កំណើតនៅខេត្តមណ្ឌលគិរី។

កញ្ញាបានបន្តទៀតថា ម្តាយនឹងកូនមានសុខភាពល្អបន្ទាប់ពីបានសម្រាលកូនបានបីថ្ងៃ ដែលជីប៉ាល់បានអស់កម្លាំងខ្លាំងបន្ទាប់ពីសម្រាលជីពេជ្រ។

ប្រធានមន្ទីរបរិស្ថានខេត្តមណ្ឌលគិរី លោក កែវ សុភក៌ បានថ្លែងថា កូនដំរីជីពេជ្រគឺជាកូនដំរីព្រៃញី០១ក្បាលដែលកើតចេញពីសេចក្តីស្នេហារវាងដំរីព្រៃឈ្មោល និងដំរីស្រុកញីឈ្មោះ ជីប៉ាល់ កាលពីអំឡុងថ្ងៃទី២២ មេសា ឆ្នាំ២០២០ និងបានត្រឡប់មកវិញ ២ សប្តាហ៍ក្រោយមក។




ជីពេជ្រនាងកើតនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ដែលអាជ្ញាធរខេត្ត ក៏ដូចជាក្រុមការងារអភិរក្ស មន្ទីរបរិស្ថានខេត្តមណ្ឌលគិរី និងបងប្អូនជនជាតិដើមភាគតិចពូនងនៅភូមិពូត្រុំរង់ចាំអស់រយៈពេល ២៣ខែ ៣ថ្ងៃដែលជីពេជ្របានប្រសូត្រចេញមកជាកូនដំរីញី ១ក្បាលដែលមានឪពុកជាដំរីព្រៃ និងម្តាយជាដំរីស្រុក។

រដ្ឋលេខាធិការក្រសួងបរិស្ថាន លោក នេត្រ ភក្ត្រា បានប្រាប់ថា ជីពេជ្រ គឺជាកូន ដំរីស្រុកទី២ ដែលបានកើតក្នុងរយៈពេល ៣ ខែចុងក្រោយក្រោយនេះ ខណៈកាលពីខែធ្នូ ឆ្នាំ២០២១ កូនដំរីស្រុកមួយក្បាលឈ្មោះណូអែលបានកើតនៅលើទឹកដីខេត្តរតនគិរី។

លោកថា ៖ «វត្តមាននៃកូនដំរីព្រៃ និងកូនដំរីក្នុងស្រុកគឺជាក្តីសង្ឃឹមនៃការអភិរក្សសត្វដំរីអាស៊ីនៅកម្ពុជា»។

នៅកម្ពុជាមានដំរីអាស៊ីចំនួនប្រមាណចន្លោះពី ៤០០ ទៅ ៦០០ ក្បាល ដែលភាគច្រើនរស់នៅក្នុងតំបន់ជួរភ្នំក្រវាញ តំបន់ខ្ពង់រាបខាងជើងទន្លេសាប និងតំបន់ខ្ពង់រាបភាគខាងកើតក្នុងខេត្តមណ្ឌលគិរី ដែលជាតំបន់ជីវៈចម្រុះដ៏សំបូរបែបប្រព័ន្ធអេកូឡូស៊ី និងមានទីជម្រាលអំណោយផលដល់ការរស់នៅរបស់សត្វដំរី និងសត្វព្រៃផ្សេងៗទៀត។ ចំណែកដំរីស្រុកត្រូវបានប៉ាន់ស្មានថាមានចំនួន ៧១ ក្បាល៕

# យុទ្ធនាការសម្អាតទន្លេទាំង៣ ក្នុងរាជធានីភ្នំពេញ ជាបេសកកម្មដំបូងដ៏សំខាន់សម្រាប់កម្ពុជា

*អត្ថបទ៖ អមរិន្ទ ដានុត*

«យុទ្ធនាការសម្អាតទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ ក្នុងរាជធានីភ្នំពេញ ដោយប្រើប្រាស់ទូកប្រមូលសំរាមបំពាក់បច្ចេកវិទ្យាថ្មីរបស់អាល្លឺម៉ង់» របស់ក្រុមហ៊ុន និងអង្គការអាល្លឺម៉ង់ ជាបេស កកម្មដំបូងដ៏សំខាន់មួយសម្រាប់កម្ពុជា ក្នុងការចូលរួមចំណែកធ្វើឲ្យទន្លេស្អាត ទីក្រុងស្អាត ពិសេសចូលរួមក្នុងយុទ្ធនាការប្រឡងប្រណាំងទីក្រុងស្អាតនៅកម្ពុជា។

នេះជាការថ្លែងឡើងរបស់រដ្ឋមន្ត្រីក្រសួងទេសចរណ៍ និងជាប្រធានគណៈកម្មាធិការជាតិវាយតម្លៃទីក្រុងស្អាត លោក ថោង ខុន ក្នុងពិធីបើកយុទ្ធនាការសម្អាតទន្លេ នៅសួនច្បារមាត់ទន្លេមុខ វត្តឧណ្ណាលោម នាពេលកន្លងមក។

យុទ្ធនាការសម្អាតទន្លេមេគង្គនេះ ធ្វើការសំអាតដោយក្រុមហ៊ុន Everwave GmbH និងអង្គការ River Ocean Cleanup របស់អាល្លឺម៉ង់ ដោយប្រើប្រាស់ទូកប្រមូលសំរាម បំពាក់បច្ចេកវិទ្យាថ្មីរបស់អាល្លឺម៉ង់ មានឈ្មោះថា «Moringa by Landmarken» ដែលមានសមត្ថភាពអាចប្រមូលទិន្នន័យទីតាំងដែលមានសំរាមបានរហ័សតាមរយៈដ្រូន និងកាម៉េរ៉ា ដែលមានសមត្ថភាពប្រមូលសំរាមក្នុងទឹកបានប្រមាណ ២០តោនក្នុងមួយថ្ងៃ។

លោក ថោង ខុន មានប្រសាសន៍ថា ៖ «វាពិតជាមានសារៈសំខាន់ណាស់សម្រាប់យុទ្ធនាការសម្អាតទន្លេនៅកម្ពុជា ហើយយើងបានស្នើឲ្យបន្តបេសកកម្មសម្អាតទន្លេនេះរយៈពេលវែង និងមិនត្រឹមតែក្នុងភូមិសាស្ត្ររាជធានីភ្នំពេញទេ គឺត្រូវបន្តទៅខេត្ត ឬតំបន់ដែលមានទេសចរប្រមូលផ្តុំជាពិសេស ខេត្តជាប់ទន្លេ និងជាប់សមុទ្រទាំង៤ ដើម្បីចូលរួមជំរុញភាពស្អាត និងបៃតងនៅតាមដងទន្លេ សមុទ្រ ដែលអាចទាក់ទាញភ្ញៀវទេសចរជាតិ និងអន្តរជាតិកាន់តែច្រើនថែមទៀត»។

លោកបានបញ្ជាក់ថា ចំពោះយន្តការប្រឡងប្រណាំងទីក្រុងស្អាត ត្រូវបានដាក់ឲ្យអនុវត្តតាំងពីឆ្នាំ២០១១ ហើយយន្តការវាយតម្លៃផ្តោតលើ «ស្តង់ដាទីក្រុស្អាត» ដែលមាន៧សូចនាករគោលសំខាន់ៗ ដូចជា ការរៀបចំនិងគ្រប់គ្រងបរិស្ថាន, ភាពស្អាត, ការគ្រប់គ្រងសំណល់, ការបញ្ជ្រាបការយល់ដឹង, តំបន់បៃតង និងខ្សែក្រវ៉ាត់បៃតង, សុវត្ថិភាពសុខភាពសាធារណៈ សន្តិសុខ និងសណ្តាប់ធ្នាប់ទីក្រុង និងហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍។

ជាមោទនភាពនាឱកាសវេទិកាទេសចរណ៍អាស៊ានឆ្នាំ២០២២នេះ ទីក្រុងចំនួនបីមាន ក្រុងបាត់ដំបង ក្រុងព្រះសីហនុ និងក្រុងសៀមរាប បានទទួលជ័យលាភីទីក្រុងទេសចរណ៍ស្អាត។

លោក Clemens Nepomuk Feigl នាយកប្រតិបត្តិ និងសហស្ថាបនិក Everwave GmbH, លោក Tilman Petter Flöhr នាយកផ្នែកបច្ចេកវិទ្យា និងជាសហស្ថាបនិក Everwave GmbH និងលោកនូ សុវណ្ណ ក៏បានបញ្ជាក់ថា លោកនឹងខិតខំបញ្ជូនទូកប្រមូលសំរាមបន្ថែមទៀតមកកម្ពុជា ហើយលោកពេញចិត្តនឹងបំពេញ បេសកម្មនៅកម្ពុជារយៈពេលយូរផងដែរ។












លោក ថោង ខុន បានបញ្ជាក់ផងដែរថា ៖ «យុទ្ធនាការសម្អាតទន្លេមេគង្គ ទន្លេសាប និងទន្លេបាសាក់ ក្នុងរាជធានីភ្នំពេញនេ ក៏ជាឆ្លើយតបទៅនឹងយុទ្ធនាការ ឆ្ពោះទៅអបអរសាទរស៊ីហ្គេមឆ្នាំ២០២៣ដែលកម្ពុជានឹងទទួលភ្ញៀវរាប់ម៉ឺននាក់»។

លោកបានបន្តថា ក្នុងនោះក៏មានយុទ្ធនាការមួយ គឺយុទ្ធនាការកម្ពុជាស្អាត ភ្នំពេញស្អាត ទូទាំងប្រទេសស្អាត ប្រជាជនម្នាក់លេងកីឡាមួយមុខ កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ កាត់បន្ថយគ្រឿងញៀន សំដៅធ្វើយ៉ាងណាឱ្យទីក្រុងភ្នំពេញក្លាយជាទីក្រុងដែលមានសុវត្ថិភាពបំផុតផងដែរ៕





# ស្ថានីយតាមដានកម្រិតទឹកទន្លេមេគង្គទីមួយ នៅផ្នែកខាងលើអាងទន្លេមេគង្គក្រោម ត្រូវដាក់ឱ្យប្រើប្រាស់



*អត្ថបទ៖ អមរិន្ទ ដានុត*

គណៈកម្មការទន្លេមេគង្គ (ហៅកាត់ថា MRC) បានសម្ពោធដាក់ឱ្យប្រើប្រាស់នូវស្ថានីយតាមដានកម្រិតទឹកទន្លេមេគង្គទីមួយ ស្ថិតនៅផ្នែកខាងលើអាងទន្លេមេគង្គក្រោម ដែលជាផ្នែកមួយសម្រាប់ផែនការកាន់តែទូលំទូលាយរបស់ MRC សំដៅកាត់បន្ថយភាពងាយរងគ្រោះសម្រាប់ប្រជាជនអាស៊ីអាគ្នេយ៍រាប់លាននាក់ ដែលអាយុជីវិត និងជីវភាពរបស់គេនៅផ្នែកខាងក្រោមទន្លេ ងាយរងឥទ្ធិពលបំផុតពីរំហូរទឹកភ្លាមៗ និងដោយមិនរំពឹងទុក។

គណៈកម្មការទន្លេមេគង្គ បានឱ្យដឹងថា ស្ថានីយតាមដានទន្លេមេគង្គច្រើនបន្ថែមទៀត នឹងជួយការពារជីវិតអ្នកពឹងអាស្រ័យតាមដងទន្លេខាងក្រោមកាន់តែប្រសើរ។

ស្ថានីយតាមដានថ្មីក្នុងស្រុកសៀងកុក ស្ថិតនៅព្រំប្រទល់ភាគខាងជើងឡាវ ជាប់នឹងប្រទេសមីយ៉ាន់ម៉ា នឹងជំរុញកិច្ចសហប្រតិបត្តិការដែល MRC ចង់បានជាយូរមកហើយ។ ក្នុងករណីនេះ ប្រទេសមីយ៉ាន់ម៉ា មានឱកាសចូលរួមប្រមូលទិន្នន័យការបញ្ចេញទឹក រួមគ្នាជាមួយនឹងសហការីឡាវ ដែលប្រជាជនរាប់លាននាក់ រស់នៅខាងក្រោមទន្លេ នឹងទទួលបានសម្រាប់ប្រើប្រាស់យ៉ាងឆាប់រហ័ស។

គណៈកម្មការទន្លេមេគង្គ បានបញ្ជាក់ថា ៖ «ទិន្នន័យនេះ នឹងផ្តល់លទ្ធភាពឲ្យពួកគេសម្របខ្លួនដោយសមស្រប ដូចជាកសិករដែលគ្រោងនឹងប្រមូលផល ឬអ្នកនេសាទដែលពឹងអាស្រ័យលើទន្លេ សម្រាប់ការនេសាទត្រីជារៀងរាល់ថ្ងៃ»។

លោក អានុល័ក នាយកប្រតិបត្តិលេខាធិការដ្ឋាន MRC បានគូសបញ្ជាក់ពីសារៈសំខាន់នៃស្ថានីយថ្មីនេះ ដោយហេតុថា វានឹងកត់ត្រារំហូរទឹកពីផ្នែកខាងលើនៃទន្លេមេគង្គ ដែលនៅប្រទេសចិន គេហៅថាទន្លេឡាងឆា ដែលស្ថិតនៅចម្ងាយប្រមាណ ១៣០ គីឡូម៉ែត្រពីស្ថានីយនេះ។

លោកបានថ្លែងថា៖«នេះជាស្ថានីយតាមដានបែបយុទ្ធសាស្ត្រមួយ។ ប្រសិនបើមានការប្រែប្រួលណាមួយពីការបញ្ចេញទឹក ការបិទច្រកទ្វារ ឬភ្លៀងធ្លាក់ភ្លាមៗ យើងនឹងទទួលបានដំណឹងនេះភ្លាម។ ជាមួយនឹងសមត្ថភាពកាន់តែប្រសើរ យើងអាចផ្តល់ព័ត៌មានច្រើនទៅឲ្យប្រទេសជាសមាជិក និងសហគមន៍តាមមូលដ្ឋាន ប៉ុន្តែវាក៏ទាមទារឲ្យប្រទេសនីមួយៗ ចែករំលែកព័ត៌មានកាន់តែច្រើនពីប្រតិបត្តិការទំនប់ផងដែរ»។

ជាការពិត ស្ថានីយសៀងកុក ជាស្ថានីយមួយក្នុងចំណោមស្ថានីយតាមដានថ្មីៗជាច្រើន ដែលការសាងសង់ត្រូវបានពន្យារពេលដោយសារជំងឺកូវីដ។ វាធ្វើឲ្យការដឹកជញ្ជូនសម្ភារៈ និងគ្រឿងបន្លាស់ចាំបាច់ផ្សេងៗ មានភាពយឺតយ៉ាវ។ ទោះជាយ៉ាងនេះក្តី សព្វថ្ងៃនេះ ស្ថានីយបែបនេះជាច្រើន កំពុងនឹងដំណើរការថ្មី ព្រោះថា ប្រទេសជាសមាជិកទាំងបួន រួមមានកម្ពុជា ឡាវ ថៃ និងវៀតណាម បានជំរុញធ្វើឲ្យសមត្ថភាពតាមដាន និងព្យាការណ៍តាមតំបន់កាន់តែប្រសើរ។

គណៈកម្មការទន្លេមេគង្គ (ហៅកាត់ថា MRC) បានឱ្យដឹងទៀតថា ចាប់ពីឆ្នាំ២០០៨ ដល់ឆ្នាំ២០១២ នៅដំណាក់កាលទីមួយនៃគម្រោងប្រព័ន្ធអង្កេតតាមដានវដ្តជលសាស្ត្រ (ហៅកាត់ថា HYCOS) គេបានសាងសង់ស្ថានីយចំនួន ៤៩ តាមដងទន្លេមេគង្គ និងដៃទន្លេនេះ ដើម្បីធ្វើការវាស់ស្ទង់ជាបន្តបន្ទាប់ពីកម្រិតទឹក និងបរិមាណភ្លៀងធ្លាក់។

សមាជិកជំនួសឡាវសម្រាប់ក្រុមប្រឹក្សា MRC លោក ចាន់ថាណេត បូអាឡាផា (Chanthanet Boualapha) អនុរដ្ឋមន្ត្រីក្រសួងធនធានធម្មជាតិ និងបរិស្ថាន បានបរិយាយពីសនិទានភាពរបស់ប្រទេសឡាវ ទន្ទឹមនឹងថ្លែងអំណរគុណដល់ភាគីផ្តល់ជំនួយ និងដៃគូនានា។

លោក បូអាឡាផា បានមានប្រសាសន៍ថា ៖ «តាមរយៈការតំឡើងស្ថានីយទាំងនេះក្នុងដែនដីរបស់យើង យើងសង្ឃឹមនឹងផ្ញើសារថា យើងបានឈានមួយជំហានបន្ថែមទៀត ដើម្បីបំពេញតួនាទីរបស់យើងក្នុងការគ្រប់គ្រងទន្លេមេគង្គ និងព្យាករណ៍អនាគតនៃទន្លេនេះឲ្យកាន់តែមានប្រសិទ្ធភាព»។

លោកថា ទាំងអស់គ្នាគិតពីអត្ថប្រយោជន៍នៃកិច្ចសហប្រតិបត្តិការសម្រាប់តំបន់ទាំងមូល និងប្រជាជនរបស់យើង៕





# អង្គការ GAVI និងមជ្ឈមណ្ឌលកូវ៉ាក់ (COVAX) នឹងបន្តការគាំទ្រលើផ្នែកពង្រឹងប្រព័ន្ធសុខាភិបាលកម្ពុជា

*អត្ថបទ៖ អមរិទ្ធ ដានុត*

មន្ត្រីជាន់ខ្ពស់នៃអង្គការGAVI និងមជ្ឈមណ្ឌលកូវ៉ាក់ (COVAX) ប្រចាំប្រទេសកម្ពុជា និងប្រទេសឡាវ ប្រចាំការិយាល័យកណ្តាលនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស បានជួបជាមួយនឹងមន្ត្រីនៃក្រសួងសុខាភិបាលកម្ពុជាដើម្បីសិក្សាស្វែងយល់អំពីប្រព័ន្ធសុខាភិបាលកម្ពុជា និងការងារចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩។

លោកស្រី ឱ វណ្ណឌីន រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស (គ.វ.ក-១៩) ដែលបានដឹកនាំនៃជំនួបនេះបានប្រាប់គណៈប្រតិភូអំពីស្ថានភាពជំងឺកូវីដ-១៩ ព្រមទាំងយុទ្ធនាការចាំបាច់ និងសំខាន់ៗ ដែលត្រូវបានអនុវត្តនាពេលកន្លងមករហូតឈានទៅគ្រប់គ្រងការរាតត្បាតជំងឺកូវីដ-១៩ និងការបើកប្រទេសឡើងវិញតាមគន្លងប្រក្រតីភាពថ្មី។

លោកស្រីថា៖«លទ្ធផលសម្រេចបានគួរជាទីមោទនៈនេះ បានមកពីការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈការដាក់ចេញនូវផែនការយុទ្ធសាស្ត្រប្រយុទ្ធនឹងជំងឺកូវីដ-១៩ និងផែនការស្រោចស្រប់ចាក់វ៉ាក់សាំងកូវីដ-១៩ នៅទូទាំងប្រទេសតាមយុទ្ធសាស្ត្រផ្ការីក»។

ជាមួយគ្នានេះ ក្នុងនាមក្រសួងសុខាភិបាល និងគ.វ.ក-១៩ លោកស្រី ឱ វណ្ណឌីន បានថ្លែងអំណរគុណដល់អង្គការ GAVI និងមជ្ឈមណ្ឌលកូវ៉ាក់ (COVAX) ដែលសម្របសម្រួលដោយអង្គការសុខភាពពិភពលោក (WHO) និងអង្គការ UNICEF ដែលមានផែនការផ្តល់នូវវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ចំនួន ៦,៦លាន ដូសមកដល់កម្ពុជា (ស្មើនឹង ២០% នៃចំនួនប្រជាពលរដ្ឋសរុប)។

លោកស្រីថា៖ «មកដល់ពេលបច្ចុប្បន្ននេះកម្ពុជាបានទទួលវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ចំនួន ១,៨៧២,២៦០ ដូស នាពេលកន្លងមករួចហើយ និងកំពុងសម្របសម្រួលដើម្បីផ្តល់នូវវ៉ាក់សាំងបង្ការកូវីដ-១៩ ចំនួន ៥,៥១៥,៣៨០ ដូសបន្ថែមទៀតមកកម្ពុជា ក្នុងឆ្នាំ២០២២»។

ប្រធានគ្រប់គ្រងជាន់ខ្ពស់របស់អង្គការ GAVI និងមជ្ឈមណ្ឌល កូវ៉ាក់ (COVAX) ប្រចាំប្រទេសកម្ពុជា និងប្រទេសឡាវ លោកស្រី ណាឌីយ៉ា ឡាស្រ៊ី (Nadia Lasri) បានសាទរ និងកោតសរសើរនូវការខិតខំជាបន្តបន្ទាប់ និងជាប្រចាំរបស់រាជរដ្ឋាភិបាល និងក្រសួងសុខាភិបាល ក្នុងការពង្រឹងប្រព័ន្ធសុខាភិបាល ការលើកកម្ពស់គុណភាពសេវាសុខាភិបាល ជាពិសេសការគ្រប់គ្រងការរាតត្បាតនៃជំងឺកូវីដ-១៩ បានយ៉ាងល្អប្រសើរ។

លោកស្រីក៏បានបញ្ជាក់នូវគោលជំហររបស់អង្គការ GAVI និងមជ្ឈមណ្ឌលកូវ៉ាក់ (COVAX) ក្នុងការបន្តគាំទ្រពង្រឹងកម្មវិធីចាក់ថ្នាំបង្ការនៅកម្ពុជា ជាពិសេសពិនិត្យលទ្ធភាពផ្តល់ជំនួយវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ បន្ថែមទៀតផងដែរ។

លោកស្រី ណាឌីយ៉ា ឡាស្រ៊ី ថាលោកស្រីនឹងសម្របសម្រួលក្នុងការផ្តល់ជំនួយវ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ពីដៃគូអភិវឌ្ឍដល់កម្ពុជា ក្នុងនោះក៏មានការគាំទ្រផ្តល់ជាជំនួយសម្រាប់ការងារចាក់ថ្នាំបង្ការជំងឺជាប្រចាំ និងដំណើរការបច្ចេកទេសគាំទ្រការងារចាក់វ៉ាក់សាំងសម្រាប់ឆ្នាំ២០២៣-២០២៧។ ទឹកប្រាក់ចំនួន ១៩,៥០៧,០២៨ ដុល្លារសហរដ្ឋអាមេរិក នឹងបន្ថែមលើគម្រោងដែលកំពុងអនុវត្តបច្ចុប្បន្ននូវទឹកប្រាក់សរុបចំនួន ៤២,៥១២,២១៣ ដុល្លារសហរដ្ឋអាមេរិក សម្រាប់ឆ្នាំ២០២១-២០២២។

លោកស្រីថា ជំនួយនេះធ្វើឱ្យទឹកប្រាក់ជំនួយផ្តល់មកកម្ពុជាពីឆ្នាំ២០២១-២០២៧ កើនឡើងដល់សរុបចំនួន ៦២,០១៩,២៤១ ដុល្លារសហរដ្ឋអាមេរិក។ នៅក្នុងចំនួនជំនួយសរុបប្រមាណ ៦២លានដុល្លារសហរដ្ឋអាមេរិកនេះមានជំនួយផ្នែកទីប្រឹក្សាបច្ចេកទេសផ្តល់ជូនដល់អង្គការសុខភាពពិភពលោក (WHO) អង្គការ UNICEF និងអង្គការ CHAI ក្នុងចំនួនទឹកប្រាក់មួយចំនួនធំដែរ។

បន្ថែមលើនេះអង្គការ GAVI និងមជ្ឈមណ្ឌលកូវ៉ាក់ (COVAX) ក៏កំពុងតែបន្តការគាំទ្រលើផ្នែកពង្រឹងប្រព័ន្ធសុខាភិបាល សំដៅពង្រឹងការងារចាក់វ៉ាក់សាំងជាប្រចាំទូទៅ (Routine Immunization) បន្ថែមទៀតដល់ប្រទេសកម្ពុជាផងដែរ៕

# មន្ត្រីបរិស្ថានថា បរិមាណអន្ទាក់ដែលបានដោះនៅឆ្នាំ២០២១ បានកើនឡើងជាងឆ្នាំ២០២០

*អត្ថបទ៖ អមរិទ្ធ ដានុត*

អន្ទាក់មានច្រើនប្រភេទដែលបង្កមហន្តរាយចំពោះជីវិតសត្វព្រៃ និងធ្វើឱ្យមានគ្រោះថ្នាក់ដល់មនុស្ស! ក្រសួងបរិស្ថាននិងអង្គការមូលនិធិសកលសម្រាប់អភិរក្សធម្មជាតិ (WWF) ព្រមទាំងអង្គការដៃគូ បានរៀបចំយុទ្ធនាការអន្ទាក់សូន្យនៅខេត្តស្ទឹងត្រែងក្នុងក្របខណ្ឌនៃយុទ្ធនាការអន្ទាក់សូន្យក្នុងតំបន់ការពារធម្មជាតិរយៈពេល ៦ ខែ។

យុទ្ធនាការអន្ទាក់សូន្យនេះបានចាប់ផ្តើមបើកជាផ្លូវការនៅថ្ងៃទី៣ ខែមីនា ឆ្នាំ២០២២ យុទ្ធនាការនេះនឹងប្រារព្ធឡើងនៅតាមបណ្តាខេត្តនានានាភាគខាងកើតទន្លេមេគង្គរួមមាន ខេត្តស្ទឹងត្រែង ខេត្តក្រចេះ ខេត្តមណ្ឌលគិរី ខេត្តរតនគិរី ខេត្តព្រះវិហារ និងខេត្តកំពង់ធំ។





«យុទ្ធនាការអន្ទាក់សូន្យនៅក្នុងតំបន់ការពារធម្មជាតិកម្ពុជា» ផ្តួចផ្តើមនិងដឹកនាំរៀបចំដោយក្រសួងបរិស្ថានដោយមានការចូលរួមរបស់អង្គការអន្តរជាតិដៃគូក្នុងកិច្ចការអភិរក្សធនធានធម្មជាតិ។ លោក នេត្រ ភក្ត្រា រដ្ឋលេខាធិការក្រសួងបរិស្ថានបានថ្លែងថា ការបើកយុទ្ធនាការអន្ទាក់សូន្យមានគោលបំណងសំខាន់រួមមាន ការផ្សព្វផ្សាយអប់រំអំពីផលប៉ះពាល់ដោយសារអន្ទាក់ទៅលើជីវិតសត្វ និងជីវិតមនុស្ស។

លោកមានប្រសាសន៍ថា៖«ស្ថានភាពនៃការការពារនិងអភិរក្សធនធានធម្មជាតិដែលជាទីជម្រករបស់សត្វព្រៃនៅកម្ពុជាមានភាពល្អប្រសើរ ដែលបានផ្តល់ជាជម្រក សម្រាប់សត្វព្រៃ និងជាប្រភពទឹក និងចំណីរបស់សត្វព្រៃ តែអ្វីដែលយើងត្រូវគិតគូរបន្ថែមទៀតគឺធ្វើឱ្យតំបន់ការពារធម្មជាតិកាន់តែមានសុវត្ថិភាពសម្រាប់សត្វព្រៃនិងជីវៈចម្រុះផ្សេង ទៀត»។

លោកបានលើកឡើថា បរិមាណអន្ទាក់ដែលបានដោះនៅឆ្នាំ២០២១ មានចំនួន ៦១៦១១ អន្ទាក់ កើនឡើងប្រមាណជាង២០% បើប្រៀបធៀបនឹងបរិមាណអន្ទាក់ដោះបាននៅឆ្នាំ២០២០ ដែលមានចំនួន ៤៣ ២៧០ អន្ទាក់។

លោក គឹម ណុង អគ្គនាយកនៃអគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិនៃក្រសួងបរិស្ថានបានថ្លែងថា ក្នុងយុទ្ធនាការនេះសំដៅធ្វើយ៉ាងណាឱ្យប្រជាពលរដ្ឋតាមមូលដ្ឋានដែលមានទម្លាប់ដាក់អន្ទាក់ចាប់សត្វព្រៃឱ្យងាកមកគោរពច្បាប់ និងឱ្យពួកគាត់យល់ពីតម្លៃសត្វព្រៃ ហើយរួមគ្នាមកចូលរួមអភិរក្សសត្វព្រៃដែលជាសត្វមានតម្លៃមហាសាលមិនអាចកាត់ថ្លៃបានជាសាកល។

លោកបានថ្លែងថា ៖ «កម្ពុជាមានច្បាប់សម្រាប់ដាក់ទោសវិន័យហើយនិងសម្រាប់បទល្មើសដាក់អន្ទាក់គឺជាច្បាប់ល្មើសធនធានធម្មជាតិថ្នាក់លេខ៣ដែលក្នុងនេះមានទាំងការផាកពិន័យនិងទោសទណ្ឌ ដោយក្នុងនេះអាចប្រឈមនឹងជាប់ពន្ធនាគារពី១-៥ឆ្នាំ និងពិន័យជាប្រាក់ពី១៥លានដល់១៥០លានរៀល»។

ជាមួយគ្នានេះលោក សេង ទៀក ប្រធានអង្គការ WWF បានឱ្យដឹងថា បច្ចុប្បន្នអន្ទាក់ដែលត្រូវបានគេដោះនៅតាមតំបន់ការពារធម្មជាតិបានត្រឹមតែ២០ភាគរយប៉ុណ្ណោះហើយចំនួន ៨០ភាគរយទៀតមិនទាន់បានដោះដែលជនល្មើសបានដាក់នៅតាមតំបន់ធនធានធម្មជាតិនានានៅប្រទេសកម្ពុជា។

ប្រធានអង្គការ WWFរូបនេះបានលើកឡើងដោយបញ្ជាក់ថា ផ្អែកតាមរបាយការណ៍ឆ្នាំ ២០២០ នៅតាបន់អាស៊ីអាគ្នេយ៍មានអន្ទាក់ប្រមាណ១២លានអន្ទាក់ដូចជាប្រទេសឥណ្ឌូនេស៊ី ម៉ាឡេស៊ី វៀតណាមឡាវ ថៃនិងកម្ពុជាដែលកំពុងគំរាមកំហែងសត្វព្រៃ។ដោយអន្ទាក់ទាំងនេះគឺជាដមចមធ្វើឱ្យបាត់បង់នូវសត្វកម្រៗក្នុងលោកដូចជា ខ្លា ខ្លារខិន ខ្លាពពកស ឆ្កែព្រៃ ខ្លាឃ្មុំជាដើម។

លោក សេង ទៀក ចង់ឱ្យស្ថាប័នពាក់ព័ន្ធអនុវត្តច្បាប់ចំពោះជនល្មើសសម្លាប់សត្វព្រៃកម្រ ក៏ដូចជាភោជនីយដ្ឋានឬតំបន់នានាដែលបានជួញដូរសត្វព្រៃ ដែលទាំងនេះសំដៅធ្វើយ៉ាងណាការពារសត្វព្រៃកម្ពុជាមិនឱ្យបាត់បង់ពូជនៅថ្ងៃខាងមុខ៕





# យុវជនអាស៊ានត្រូវបានគេបណ្តុះបណ្តាលឲ្យក្លាយជាអ្នកដឹកនាំសម្រាប់អនាគត

*អត្ថបទ៖ អរិយបុត្រ*

ដោយមានគោលបំណងលើកកម្ពស់ការយល់ដឹងជាអន្តរជាតិនិងភាពជាអ្នកដឹកនាំក្នុងចំណោមបុគ្គលវ័យក្មេងក្នុងតំបន់បន្ថែមទៀត អង្គការយុវជនអាស៊ាន ដែលជាអង្គការមិនស្វែងរកប្រាក់ចំណេញ និងជាអង្គការមិនមែនរដ្ឋាភិបាលឈានមុខគេមួយនៅក្នុងអាស៊ាន បានរៀបចំកម្មវិធីបណ្តុះបណ្តាលតាមអនឡាញមួយ ដែលហៅថា វេទិកាភាពជាអ្នកដឹកនាំយុវជនអាស៊ានឆ្នាំ ២០២២ នាពេលថ្មីៗនេះ។

ព្រឹត្តិការណ៍នេះបានរៀបចំឡើងក្រោមប្រធានបទ «ភាពជាអ្នកដឹកនាំយុវជនថ្ងៃនេះ ដើម្បីថ្ងៃស្អែកប្រកបដោយនិរន្តរភាព» ដើម្បីអបអរសាទរចំពោះសកម្មភាពនៃភាពក្លាហាន និងការប្តេជ្ញាចិត្ត របស់យុវជននៅក្នុងតំបន់ ដែលប្រាថ្នាចង់ក្លាយជាអ្នកដឹកនាំអាស៊ានវ័យក្មេង ដែលអាចដើរតួនាទីយ៉ាងវិសេសវិសាលក្នុងការតស៊ូមតិលើបញ្ហាជាច្រើនរួមបញ្ចូលតាំងពីបញ្ហា សុខភាពផ្លូវចិត្ត និងការពង្រឹងសិទ្ធិអំណាចស្ត្រីនៅក្នុងតំបន់ជាដើម។

ប្រធានបទនេះក៏ត្រូវបានតម្រឹមជាមួយនឹងការប្រារព្ធទិវាសិទ្ធិនារីអន្តរជាតិរបស់អង្គការសហប្រជាជាតិក្រោមប្រធានបទ «សមភាពយេនឌ័រថ្ងៃនេះសម្រាប់ថ្ងៃស្អែកប្រកបដោយនិរន្តរភាព» ផងដែរ។

ព្រឹត្តិការណ៍នេះត្រូវបានចូលរួមដោយអ្នកចូលរួមចំនួន ប្រមាណជា ៥០០ នាក់ដែលមានអាយុពី ១៥ ទៅ ៣៥ ឆ្នាំមកពីមជ្ឈដ្ឋានវិជ្ជាជីវៈ និងការសិក្សាផ្សេងៗ ដែលបានរួមចំណែកផ្លាស់ប្តូរជីវិតដល់សង្គមរៀងៗខ្លួននៅក្នុងតំបន់។

អ្នកចូលរួមត្រូវបានផ្តល់ឱកាសក្នុងការបំផុសគំនិត បង្កើតទំនាក់ទំនង និងទទួលបានការយល់ដឹងកាន់តែស៊ីជម្រៅអំពីបញ្ហាប្រឈម និងបញ្ហាបច្ចុប្បន្នដែលកំពុងប្រឈមមុខផ្នែកចំនួនបី រួមមាន ការដាក់បញ្ចូល សុខភាពផ្លូវចិត្ត និងការពង្រឹងសិទ្ធិ ក៏ដូចជា តួនាទីស្ត្រីនៅក្នុងសង្គម ។

ដើម្បីដំណើរការកម្មវិធីបណ្តុះបណ្តាលនេះឲ្យជោគជ័យ អង្គការយុវជនអាស៊ានក៏បានជ្រើសរើសវាគ្មិនវ័យក្មេងចំនួនប្រាំមួយរូប ដើម្បីជំរុញឱ្យមានការពិភាក្សាក្នុងព្រឹត្តិការណ៍នេះផងដែរ ដែលក្នុងនោះមានពីរនាក់មកពីប្រទេសឥណ្ឌូនេស៊ី ម្នាក់មកពីប្រទេសវៀតណាម ម្នាក់មកហ្វីលីពីន ម្នាក់សិង្ហបុរី និងម្នាក់មកពីប្រទេសថៃ។

លោកស្រី ស៊ូ ចេន ម៉ាកជិង (Soe Tjen Marching) សាស្ត្រាចារ្យជាន់ខ្ពស់នៅសាកលវិទ្យាល័យឡុងដុង បាននិយាយថា ៖ «អ្វីដែលជំរុញទឹកចិត្តខ្ញុំឱ្យក្លាយជាអ្នកនិពន្ធគឺការជួបអ្នករស់រានមានជីវិតពីអំពើហិង្សា ដែលរឿងរ៉ាវរបស់ពួកគេពិតជាគួរឱ្យចាប់អារម្មណ៍ និងពោរពេញដោយការតស៊ូ... សូម្បីតែបន្ទាប់ពីមានការឈឺចាប់ក៏ដោយ។ ក្រោយពេលរងគ្រោះ ពួកគេនៅតែក្លាហាន និងមិនគួរឱ្យជឿ»។

ពាក់ព័ន្ធនឹងបញ្ហានេះ យុវនារីមួយរូប បានពន្យល់ថា ៖«ចលនារបស់ស្ត្រីគឺជាការរំលឹកជានិច្ចសម្រាប់យើងទាំងអស់គ្នា មិនថាជំនាន់ណាក៏ដោយថា ការតស៊ូដើម្បីសមភាពគឺពិតប្រាកដ និង វាអាចធ្វើបាន។ យើងអាចធ្វើបាន»។រសបន្តិច។ ក្នុងនាមជាយុវជន យើងគួរតែបង្កើតចលនា និងយុទ្ធនាការដើម្បីផ្លាស់ប្តូរផ្នត់គំនិតនេះសម្រាប់មនុស្សជំនាន់ក្រោយ»។

លោក ម៉ាយឃើល នូហ្គ្រាហា ប៊ូដ្យាតូ (Michael Nugraha Budiarto) អនុប្រធានអង្គការយុវជនអាស៊ានទទួលបន្ទុកកិច្ចការខាងក្រៅបានបន្ថែម ថា ៖ «នៅកន្លែងធ្វើការយើងនៅតែមិនមានសមភាពយេនឌ័រ ដោយសារប្រវត្តិសាស្ត្រ និងផ្នត់គំនិតរួមរបស់យើង ដែលថាយើងមើលឃើញថាស្ត្រីនៅតែទាបជាងបុរសបន្តិច។ ក្នុងនាមជាយុវជនយើងគួរតែបង្កើតចលនា និងយុទ្ធនាការដើម្បីផ្លាស់ប្តូរផ្នត់គំនិតនេះសម្រាប់មនុស្សជំនាន់ក្រោយ»។

វេទិកានេះជាវេទិកាមួយសម្រាប់ឱ្យអ្នកដឹកនាំវ័យក្មេងនៅអាស៊ាន បង្កើតបណ្តាញ បំផុសគំនិត និងអភិវឌ្ឍទំនាក់ទំនងរវាងបុគ្គល និងសហគមន៍ ដើម្បីបង្កើនចំណង់ចំណូលចិត្តរបស់ពួកគេក្នុងការបង្កើតការផ្លាស់ប្តូរប្រកបដោយអត្ថន័យនៅក្នុងតំបន់»៕

# ក្រសួងអប់រំ យុវជន និងកីឡា៖ ការសិក្សារបស់កុមារបានធ្លាក់ចុះនៅក្នុងអំឡុងពេលនៃជំងឺរាតត្បាត

*អត្ថបទ៖ អមរិទ្ធ ដានុត*

ក្រសួងអប់រំ យុវជន និងកីឡា បានបង្ហាញនូវលទ្ធផលថ្មីគួរឱ្យភ្ញាក់ផ្អើលមួយ ទាក់ទងនឹងការបាត់បង់ការរៀនសូត្ររបស់សិស្សានុសិស្សកម្ពុជាក្នុងអំឡុងពេលនៃការរាតត្បាតជំងឺកូវីដ ដោយក្នុងនោះកុមារាបានបាត់បង់ការរៀនសូត្រច្រើនជាងមុន និងទទួលលទ្ធផលខ្សោយជាងមុននៅក្នុងការធ្វើតេស្ត។

សេចក្តីប្រកាសព័ត៌មានរបស់ក្រសួងអប់រំ យុវជន និងកីឡា និងអង្គការយូនីសេហ្វ បានឱ្យដឹងថាលទ្ធផលនេះបានមកពីការវាយតម្លៃជាតិចុងក្រោយរបស់ក្រសួង អយក ទៅលើការរៀនសូត្រនៅថ្នាក់ទី៦ ដែលត្រូវបានធ្វើឡើងនៅខែវិច្ឆិកា ឆ្នាំ២០២១ និងបានប្រកាសផ្សព្វផ្សាយនៅខែមីនា ឆ្នាំ២០២២ បន្ទាប់ពីមានការវិភាគយ៉ាងលម្អិត។

នាយកដ្ឋានធានាគុណភាពអប់រំ (EQAD) របស់ក្រសួង បានវាយតម្លៃលើសិស្សានុសិស្សចំនួនជាង ៦.០០០នាក់នៅក្នុងសាលារៀនចំនួន ២៣០ នៅទូទាំងប្រទេសកម្ពុជា ហើយបានរកឃើញថាការសិក្សារបស់កុមារបានធ្លាក់ចុះនៅក្នុងអំឡុងពេលនៃជំងឺរាតត្បាត។ ដោយប្រៀបធៀបជាមួយការវាយតម្លៃដូចគ្នានៅឆ្នាំ២០១៦ ភាគរយនៃសិស្សានុសិស្ស ដែលមិនអាចបង្ហាញអំពីជំនាញចំណេះដឹងមូលដ្ឋានផ្នែកភាសាខ្មែរបានកើនឡើងពី ៣៤% ទៅ ៤៥% និងផ្នែកគណិតវិទ្យាបានកើនឡើងពី ៤៩% ទៅ ៧៤%។

សាលារៀននៅប្រទេសកម្ពុជាត្រូវបានបិទទ្វារអស់រយៈពេល ២៥០ថ្ងៃនៅឆ្នាំ២០២០ និង២០២១ ដែលចំនួននេះស្ទើរតែស្មើនឹងពីរភាគបីនៃឆ្នាំសិក្សាចំនួនពីរឆ្នាំ។ លទ្ធផលនៃការវាយតម្លៃលើការរៀនសូត្រនេះបង្ហាញថា ទោះបីជាសិស្សានុសិស្សទាំងអស់បានជួបប្រទះនឹងការបាត់បង់ការរៀនសូត្រ បន្ទាប់ពីការបិទសាលារៀនទាំងនេះក្តី ផលប៉ះពាល់មិនមានលក្ខណៈដូចៗគ្នាឡើយ។ កុមារាបានបាត់បង់ការរៀនសូត្រច្រើនជាងមុន និងទទួលលទ្ធផលខ្សោយជាងមុននៅក្នុងការធ្វើតេស្ត៖ កុមារាចំនួន ៥៥% ត្រូវបានវាយតម្លៃថា មិនសម្រេចបានជំនាញចំណេះដឹងមូលដ្ឋានផ្នែកភាសាខ្មែរឡើយនៅឆ្នាំ២០២១ ធៀបនឹងកុមារីចំនួន ៣៤%។

លោក ហង់ជួន ណារ៉ុន រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា បានលើកឡើងថាលទ្ធផលទាំងនេះគឺជាលទ្ធផលគួរឱ្យបារម្ភ។

លោកថា៖«យើងបានខិតខំប្រឹងប្រែងធ្វើការងារជាមួយដៃគូទាំងអស់របស់យើង ដើម្បីដាក់ចេញនូវវិធានការរៀនសូត្រពីចម្ងាយ នៅពេលសាលារៀនបិទទ្វារក្នុងអំឡុងពេលនៃជំងឺរាតត្បាត។ ឥលូវនេះគឺជាពេលដែលយើងទាំងអស់គ្នាត្រូវព្យាយាម និងជួយកុមារកម្ពុជាតាមឱ្យទាន់ការរៀនសូត្រ ដែលពួកគេបានបាត់បង់ ដែលនេះជាដំណើរការមួយដែលបានចាប់ផ្តើមរួចហើយ ប៉ុន្តែនៅពេលនេះវាត្រូវតែពន្លឿនបន្ថែមជាមួយនឹងការគាំទ្រពីដៃគូទាំងអស់នៅក្នុងវិស័យអប់រំ»។

ជាលទ្ធផលពីរបកគំហើញមិនគួរឲ្យពេញចិត្ត ក្រសួងអប់រំ បានរៀបចំកិច្ចប្រជុំរបស់ក្រុមការងារបច្ចេកទេសរួមជាមួយនឹងដៃគូវិស័យអប់រំទាំងអស់របស់ខ្លួន ដើម្បីរៀបចំជំហានបន្ទាប់។ ក្រសួងក៏បានចាត់វិធានការចាំបាច់មួយចំនួនដូចជាការកំណត់ការបង្រៀនមេរៀនបំប៉ននៅពេលសាលារៀនបើកឡើងវិញភ្លាម។

យូនីសេហ្វបានធ្វើការងារជាមួយដៃគូនានារួមមាន ក្រសួង អយក អង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (KAP) អង្គការ VVOB និងភាពជាដៃគូសាកលសម្រាប់ការអប់រំ (GPE) ដើម្បីផលិតកម្រងធនធានបោះពុម្ព និងក្រៅអនឡាញ(Offline) ដើម្បីគាំទ្រដល់ការរៀនសូត្របំប៉ននេះ។

គ្រូបង្រៀនចំនួនពីរពាន់នាក់បានទទួលការបណ្តុះបណ្តាលអំពីការប្រើប្រាស់ធនធានទាំងនេះ ប៉ុន្តែជាការចាំបាច់ វាត្រូវមានការណែនាំដល់គ្រូបណ្តុះបណ្តាលជាច្រើននាក់បន្ថែមទៀត។

នាយិកាយូនីសេហ្វប្រចាំកម្ពុជា លោកស្រីហ្វ៊ូហ្គ ហ្វយូហ្សិថ បានថ្លែងថា នៅក្នុងសកលលោក ការបាត់បង់ការរៀនសូត្រត្រូវបានគេយល់ឃើញថាជាផលវិបាកដ៏អាក្រក់បំផុតមួយក្នុងចំណោមផលវិបាកដ៏អាក្រក់បំផុតនានាដែលបង្កដោយជំងឺរាតត្បាត ប៉ុន្តែប្រទេសកម្ពុជា គឺជាប្រទេសមួយក្នុងចំណោមប្រទេសតិចតួច ដែលបានបង្ហាញទំហំនៃការបាត់បង់នេះជាមួយនឹងទិន្នន័យដែលអាចជឿទុកចិត្តបាន។

លោកស្រីបន្តថា ៖ «ខ្ញុំសូមទទួលស្គាល់នូវជំហានដ៏សំខាន់ៗ ដែលក្រសួង អយក បានដាក់ចេញ ដើម្បីបង្កើតភស្តុតាងយ៉ាងសំខាន់នេះសម្រាប់ផ្តល់ជាភស្តុតាង និងជាមគ្គុទ្ទេសក៏ដល់គោលនយោបាយ និងវិធានការចាំបាច់ដើម្បីផ្លាស់ប្តូរទិសដៅនៃនិន្នាការនេះ»។

លោកស្រី ហ្វ៊ូហ្គ ហ្វយូហ្សិថ បានបញ្ជាក់ទៀតថា កិច្ចការនេះរួមមានការបង្កើនការផ្តល់រយៈពេល និងប្រសិទ្ធភាពនៃការរៀនសូត្របំប៉ននេះ។ សិស្សានុសិស្សគប្បីទទួលបានការគាំទ្រដែលចាំបាច់ ដើម្បីជួយឱ្យពួកគេតាមទាន់ការអប់រំរបស់ខ្លួន។

លោកស្រីបានបន្ថែមថា ៖ «យើងក៏ត្រូវតែវិនិយោគច្រើនទៀតលើគណិតវិទ្យា និងចំណេះដឹងភាសាខ្មែរនៅថ្នាក់ដំបូងផងដែរ។ សិស្សានុសិស្សក្មេងៗត្រូវការមូលដ្ឋានរឹងមាំលើមុខវិជ្ជាស្នូលទាំងនេះ ដើម្បីទទួលបានលទ្ធផលកាន់តែល្អនៅថ្នាក់ក្រោយៗទៀត»។

អង្គការយូនីសេហ្វ ប្តេជ្ញាចិត្តផ្តល់កិច្ចខិតខំប្រឹងប្រែងអតិបរមាជាមួយដៃគូទាំងអស់ ដើម្បីជួយធ្វើឱ្យកិច្ចខិតខំប្រឹងប្រែងទាំងនេះសម្រេចបាន។

សេចក្តីប្រកាសព័ត៌មានដដែលនេះ បានបញ្ជាក់បន្ថែមថា សាលារៀននៅទីក្រុងបានជួបប្រទះនឹងការបាត់បង់ការរៀនសូត្រក្នុងកម្រិតខ្ពស់ជាង បើទោះជានៅតែមានលទ្ធផលនាំមុខក៏ដោយ។ ឧទាហរណ៍ ចំនួនសិស្សានុសិស្សដែលមិនសម្រេចបាននូវស្តង់ដារកម្រិតមូលដ្ឋានក្នុងមុខវិជ្ជាគណិតវិទ្យាបានកើនឡើងពីចំនួន ៣០% ទៅ ៦២% នៅសាលារៀននៅទីក្រុង ក្នុងខណៈដែលសាលារៀននៅជនបទ មានសិស្សានុសិស្សមិនបានសម្រេចនូវស្តង់ដារទាំងនោះបានកើនឡើងពី ៥៤% ទៅ ៧៧%។

សិស្សានុសិស្សកាន់តែច្រើនត្រូវបានរកឃើញធ្លាក់មុខវិជ្ជាគណិតវិទ្យា ជាជាងមុខវិជ្ជាភាសាខ្មែរ។ ចំពោះមុខវិជ្ជាគណិតវិទ្យា មានសិស្សចំនួន ៤៩% បានធ្លាក់កម្រិតស្តង់ដារមូលដ្ឋានក្នុងឆ្នាំ២០១៦ ធៀបនឹង ៧៤% ក្នុងឆ្នាំ២០២។ សម្រាប់ភាសាខ្មែរ ភាគរយខុសគ្នាគឺមានកម្រិតតិចជាងគឺ ៣៤% មិនបានជាប់កម្រិតស្តង់ដារមូលដ្ឋានក្នុងឆ្នាំ២០១៦ ធៀបនឹង ៤៥% ក្នុងឆ្នាំ២០២១ ៕

# កម្ពុជាប្តេជ្ញាជំរុញកំណើនសេដ្ឋកិច្ចឱ្យកើន ជាង ៥ភាគរយ នៅឆ្នាំ២០២២

*អត្ថបទ៖ អរិយបុត្រ*

កម្ពុជានៅពេលនេះកំពុងតែខិតខំនៅក្នុងការជំរុញកំណើនសេដ្ឋកិច្ចដែលទទួលវិបត្តិផ្ទួនៗពីរឆ្នាំជាប់គ្នាដោយសារតែការរីករាលដាលកូវីដ-១៩ ឲ្យទទួលបានកំណើនសេដ្ឋកិច្ចយ៉ាងហោចណាស់ឲ្យបាន ៥ភាគរយនៅក្នុងឆ្នាំ ២០២២ នេះ។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងថា ការរីករាលដាលនៃមេរោគកូវីដ-១៩ នៅតែបន្តអូសបន្លាយ ហើយជម្លោះរវាងអ៊ុយក្រែននិងរុស្ស៊ី ក៏អាចនឹងជះឥទ្ធិពលអវិជ្ជមានមកលើកំណើនសេដ្ឋកិច្ចសាកលនិងកម្ពុជា ប្រសិនបើជម្លោះនេះបន្តអូសបន្លាយ ប៉ុន្តែកម្ពុជារំពឹងថានឹងធានាបាននូវកំណើនសេដ្ឋកិច្ចក្នុងកម្រិតប្រមាណជា ៣ ភាគរយ នៅឆ្នាំ២០២១ និងបន្តកើនឡើងលើសពី ៥ ភាគរយនៅឆ្នាំ២០២២ ។

ពាក់ព័ន្ធនឹងបញ្ហានេះដែរ លោក អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានលើកឡើងថា ក្រៅពីការបន្តប្រយុទ្ធនឹងជំងឺកូវីដ-១៩ រាជរដ្ឋាភិបាលផ្តោតជាសំខាន់លើការស្តារ និងជំរុញកំណើនសេដ្ឋកិច្ច ឱ្យវិលត្រឡប់ទៅរកវិថីនៃកំណើនសក្តានុពលរបស់ខ្លួនឡើងវិញ ពិសេសតាមរយៈការជំរុញការអនុវត្ត ក្របខណ្ឌយុទ្ធសាស្ត្រ និងកម្មវិធីស្តារ និងជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ ២០២១-២០២៣ ។

លោកថា រាជរដ្ឋាភិបាលទើបបានប្រកាសដាក់ឱ្យអនុវត្តកាលពីថ្ងៃទី១៦ ខែធ្នូ ឆ្នាំ២០២១ ដោយឈរលើសសរស្តម្ភចំនួន ៣រួមមាន ការស្តារឡើងវិញនូវកំណើនក្នុងវិស័យសំខាន់ៗដែលជាចន្ទល់សេដ្ឋកិច្ច, ការកែទម្រង់ដើម្បីកសាងមូលដ្ឋានគ្រឹះរឹងមាំសម្រាប់កំណើន ពិពិធកម្ម និងភាពប្រកួតប្រជែង, និង ការពង្រឹងភាពធន់ប្រកបដោយចីរភាព និងបរិយាប័ន្ន។



លោកបានសង្កត់ធ្ងន់ថា ៖ «វិបត្តិភូមិសាស្ត្រនយោបាយរវាងរុស្ស៊ី និងអ៊ុយក្រែន នៅតំបន់អឺរ៉ុបនាបច្ចុប្បន្ន កំពុងតែបង្កបញ្ហាធ្ងន់ធ្ងរដល់ការវិវត្តនៃស្ថានភាពសង្គម-សេដ្ឋកិច្ច លើសាកលលោកក៏ដូចជាក្នុងតំបន់ ដែលតម្រូវឱ្យរាជរដ្ឋាភិបាលតាមដាន និងវាយតម្លៃជាប់ជាប្រចាំ ហើយដាក់ចេញនូវវិធានការចាំបាច់ សំដៅកាត់បន្ថយផលប៉ះពាល់អាក្រក់ពីសភាពការណ៍នេះឱ្យបានទាន់ពេល តាមលទ្ធភាពដែលអាចធ្វើទៅបាន»។

លោកបានបន្ថែមថា ទន្ទឹមនេះ ត្រូវខិតខំពង្រីកប្រព័ន្ធធារាសាស្ត្រ បណ្តាញស្រោចស្រពដំណាំ ការអភិវឌ្ឍបច្ចេកទេសដាំដុះឱ្យទទួលបានទិន្នផលខ្ពស់ និងមានគុណភាពស្របតាមតម្រូវការទីផ្សារ ការស្វែងរកទីផ្សារថ្មីៗដែលមានសក្តានុពលបន្ថែមទៀត ព្រមទាំងគិតគូរពីវិធានការនានា ដើម្បីជួយការពារតម្លៃកសិផល និងដំណាំផ្សេងៗរបស់ប្រជាពលរដ្ឋឱ្យមានស្ថិរភាព។

លោក អូន ព័ន្ធមុនីរ័ត្ន បានជំរុញឱ្យ អាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ត្រូវខិតខំគាំទ្រអង្គភាពប្រមូលចំណូល ក្នុងការកៀរគរប្រមូលប្រភពចំណូលចូលថវិកាជាតិ និងថវិកាខេត្ត ជាពិសេសត្រូវខិតខំកៀរគរ និងលើកទឹកចិត្តដល់ការវិនិយោគ អភិវឌ្ឍសហគ្រាសធុនតូច និងមធ្យម សម្រាប់បង្កើតឱកាសការងារ និងលើកកម្ពស់ជីវភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ក្នុងកាលៈទេសៈនៃវិបត្តិកូវីដ-១៩៕

# ក្រសួងកសិកម្មបង្ហាញវឌ្ឍនភាពនៃដំណាំ កៅស៊ូ និងផលិតកម្មកសិកម្មផ្សេងៗទៀត

*អត្ថបទ៖ អរិយបុត្រ*

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទថ្មីៗកន្លងទៅនេះ បានប្រកាសអំពីវឌ្ឍនភាពនៃការបង្កបង្កើនផល និង ការនាំចេញក៏ដូចជាតម្លៃជ័រកៅស៊ូ ដែលកំពុងតែ មានគុណតម្លៃសម្រាប់កំណើនកសិកម្ម និង ចូលរួមជាកោសិកាសម្រាប់កំណើនសេដ្ឋកិច្ចជារួម ។

ក្រសួងបានឲ្យដឹងថា គិតមកដល់ខែ កុម្ភៈ ឆ្នាំ២០២២ ផ្ទៃដីកៅស៊ូសរុបនៅកម្ពុជាមានចំនួន ៤០៤.០៤៤ ហិចតា ដោយផ្ទៃដីចំការបែបកសិឧស្សាហកម្មមានចំនួន ៤៧.៩៤៤ ហិចតា ហើយផ្ទៃដីចំការកៅស៊ូសម្បទានដីសេដ្ឋកិច្ចមានចំនួន ១៩២.៤០២ ហិចតា និង ផ្ទៃដីចំការកៅស៊ូគ្រួសារ មានចំនួន ១៦៣.៦៩៨ ហិចតា ។







ផលិតផលជ័រកៅស៊ូដែលកម្ពុជាសម្រេចបាននៅក្នុងរយៈពេល ពីរខែ នេះ គឺមានចំនួន ៣៤.១៣៧ តោន កើនឡើងប្រមាណជា ១.២៩៤ តោន ស្មើនឹង ៤ភាគរយ ។ ជាមួយនឹងទិន្នផលនេះ បរិមាណជ័រកៅស៊ូ ដែលត្រូវបានបញ្ចេញលក់នៅក្នុងខែ កុម្ភៈឆ្នាំ២០២២នេះ គឺសម្រេចបាន ចំនួន ៣២.៥២០ តោន កើនឡើង ១.៦៦៧ តោន ស្មើនឹង ៥ភាគរយ ខណៈដែលតម្លៃលក់ជ័រកៅស៊ូមធ្យមក្នុងរយៈពេលដដែល គឺមានតម្លៃ ១.៥៨៦ ដុល្លារនៅក្នុងមួយតោន ដោយតម្លៃនេះ មានភាពប្រសើរឡើងប្រមាណជា ២១ ដុល្លារ ។

ក្រៅពីផលិតផលជ័រកៅស៊ូ កម្ពុជាក៏កំពុងតែប្រមូលឈើកៅស៊ូ ដែលជាដើមចាស់ៗសម្រាប់បំពេញឧស្សាហកម្ម សំណង់ ក៏ដូចជាគ្រឿងសង្ហារឹម គឺមានចំនួន ៤៨៦ម៉ែត្រគូប ហើយបញ្ចេញលក់បានទាំងអស់នៅក្នុងតម្លៃ ២៧៨ ដុល្លារនៅក្នុងមួយម៉ែត្រគូប ។

ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ បានបញ្ជាក់ថា៖ «អង្ករនិងស្រូវនៅតែជាផលិតផលកសិកម្មនាំចេញនាំមុខរបស់កម្ពុជានៅក្នុងរយៈពេល២ ខែ នេះ ដោយ ការនាំចេញអង្ករនៅរយៈពេល២ ខែ នេះ មានបរិមាណសរុប ១០៣.០៥៨ តោន កើនឡើង ៣៥,២១ភាគរយ ការនាំចេញស្រូវវិញ គឺមានបរិមាណ៦៥១.១០១ តោន កើនឡើង ១៦,៤៧ ភាគរយ»។

ក្រៅពីនោះ ការនាំចេញផលិតផលកសិកម្មផ្សេងៗទៀត ដូចជា ផលិតផលពីដំឡូងមី គ្រាប់ស្វាយចន្ទី ម្ទេស ម្រេច ពោត ចេក ...ជាដើមក៏ស្ថិតនៅក្នុងស្ថានភាពកើនឡើងភាគច្រើនផងដែរ៕





# រាជរដ្ឋាភិបាលប្រកាសផ្តល់មូលនិធិបន្ថែម១០០លាន ដុល្លារសម្រាប់សហគ្រាសធុនតូចនិងមធ្យម

*អត្ថបទ៖ អរិយបុត្រ*

រាជរដ្ឋាភិបាលតាមរយៈក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានប្រកាសកាលពីពេលថ្មីៗនេះពីការបន្ថែមមូលនិធិចំនួន ១០០ លានដុល្លារសម្រាប់ធនាគារសហគ្រាសធុនតូចនិងមធ្យម ព្រមទាំងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម។

កញ្ចប់ជំនួយសម្រាប់គាំទ្រដល់សហគ្រាសធុនតូចនិងមធ្យមនេះ ត្រូវបានប្រកាសដោយលោក អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនៅខែ កុម្ភៈកន្លងទៅថ្មីៗនេះ។

លោក អូន ព័ន្ធមុនីរ័ត្ន បានឲ្យដឹងថា មូលនិធិចំនួន ១០០ លានដុល្លារនេះត្រូវបានដាក់បន្ថែមលើគម្រោងមូលនិធិហិរញ្ញប្បទានដែលមានស្រាប់សម្រាប់ធនាគារនិងស្ថាប័នហិរញ្ញវត្ថុខាងលើ ដើម្បីគាំទ្រដល់សហគ្រាសធុនតូច និងមធ្យម ព្រមទាំងវិស័យកសិកម្មដែលជាវិស័យសំខាន់ នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចជាតិ ទាំងនៅក្នុងការបង្កើតការងារ ការកែលម្អជីវភាពរស់នៅរបស់ប្រជាជន និងកំណើនសេដ្ឋកិច្ចជាតិ។

គួររំលឹកថា មូលនិធិបន្ថែមនេះ នឹងត្រូវផ្តល់ជូនធនាគារសហគ្រាសធុនតូចនិងមធ្យមចំនួន ៥០លានដុល្លារ សម្រាប់បន្តគម្រោងសហហិរញ្ញប្បទានទ្រទ្រង់ សហគ្រាសធុនតូចនិងមធ្យម ដំណាក់កាលទី២ដែលធ្វើឲ្យបដិភាគរបស់រាជរដ្ឋាភិបាលមានចំនួនរហូតដល់ទៅ ១២០ លានដុល្លារ។ មូលនិធិ ៥០ លានដុល្លារទៀតនឹងត្រូវផ្តល់ជូនទៅ ធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម សម្រាប់កម្មវិធីហិរញ្ញប្បទានពិសេស ដែលនៅក្នុងនោះ ថវិកា ១០ លានដុល្លារ នឹងប្រើប្រាស់ក្នុងវិស័យស្រូវ និងអង្ករ និង ៤០ លានដុល្លារទៀត។ តាមរយៈមូលនិធិនេះ វានឹងប្រើប្រាស់សម្រាប់ការផ្តល់ហិរញ្ញប្បទានផ្ទាល់ក្នុងទំហំ ៥០ ភាគរយនិងសម្រាប់កម្មវិធីសហហិរញ្ញប្បទានចែករំលែកហានិភ័យជាមួយនឹងគ្រឹះស្ថានហិរញ្ញវត្ថុ ក្នុងទំហំ៥០ ភាគរយ សំដៅគាំទ្រដល់អនុវិស័យផ្លែឈើ ការចិញ្ចឹមសត្វ វារីវប្បកម្មនិង ការកែច្នៃផលិតផលកសិកម្មជាដើម៕

# កម្ពុជាប្រកាសទទួលស្គាល់ ម៉ាកសម្គាល់ ភូមិសាស្ត្រទំនិញ «ទឹកឃ្មុំព្រៃមណ្ឌលគិរី»

*អត្ថបទ៖ អមរិន្ទ ដានុត*









លោក ប៉ាន សូរស ័ក្តិ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម បានថ្លែងឱ្យដឹងថា ក្រសួងពាណិជ្ជកម្ម នឹងបន្តគាំទ្រនិងស្វែងរកជំនួយតាមរយៈកិច្ចសហការពីអង្គការកម្មសិទ្ធិបញ្ញាពិភពលោក( WIPO) ទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) និងដៃគូអភិវឌ្ឍន៍នានា ដើម្បីបន្តអភិវឌ្ឍន៍ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ «ទឹកឃ្មុំព្រៃមណ្ឌលគិរី» តាមរយៈការបណ្តុះបណ្តាលសមាជិកសមាគមអភិរក្សឃ្មុំព្រៃខេត្តមណ្ឌលគិរី អំពីយុទ្ធសាស្ត្រទីផ្សារការគ្រប់គ្រង ការវេចខ្ចប់ និងការកសាងកេរ្តិ៍ឈ្មោះម៉ាក។

លោកបានថ្លែងដូចនេះក្នុងពិធីចុះបញ្ជីផ្លូវការនូវទឹកឃ្មុំព្រៃមណ្ឌលគិរីជាផលិតផលសម្គាល់ភូមិសាស្ត្រ ហើយក្រសួងពាណិជ្ជកម្មនឹងបន្តជំរុញ រៀបចំការចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ «ទឹកឃ្មុំព្រៃមណ្ឌលគិរី» ជាអន្តរជាតិនៅបណ្តាប្រទេសនានា ដើម្បីឱ្យទំនិញសម្គាល់ភូមិសាស្ត្រ «ទឹកឃ្មុំព្រៃមណ្ឌលគិរី» មានសក្តានុពលទាំងនៅលើទីផ្សារជាតិនិងអន្តរជាតិ។

លោកបានថ្លែងថា ៖ «ក្រសួងពាណិជ្ជកម្មនឹងបន្តកិច្ចសហការជាមួយអាជ្ញាធរមូលដ្ឋាន ក៏ដូចជាក្រសួងស្ថាប័នពាក់ព័ន្ធក្នុងការចូលរួមអភិវឌ្ឍន៍ម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ ទឹកឃ្មុំព្រៃមណ្ឌលគិរី ឱ្យក្លាយជាគោលដៅទេសចរណ៍តាមរយៈការរៀបចំហេដ្ឋារចនាសម្ព័ន្ធសមាគមអភិរក្សឃ្មុំព្រៃមណ្ឌលគិរី មូលដ្ឋានផលិតកម្ម និងទីកន្លែងប្រមូលផលទឹកឃ្មុំ ដើម្បីទាក់ទាញភ្ញៀវទេសចរ ស្របតាមផែនការមេស្តីពី ការអភិវឌ្ឍវិស័យទេសចរណ៍ខេត្តមណ្ឌលគិរី ឆ្នាំ២០២១ ដល់ឆ្នាំ ២០៣៥ របស់រាជរដ្ឋាភិបាល»។

លោក នេត្រ ភក្ត្រា អ្នកនាំពាក្យក្រសួងបរិស្ថាន បានលើកឡើងដែរថា នេះគឺជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រថ្មីមួយទៀតសម្រាប់ប្រជាពលរដ្ឋ ខេត្តមណ្ឌលគិរី និងសម្រាប់ប្រជាសហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃឈើ ដែលទឹកឃ្មុំព្រៃផលិតផលមូលដ្ឋានរបស់ខ្លួនត្រូវបានក្រសួងពាណិជ្ជកម្មចុះបញ្ជីម៉ាកសម្គាល់ភូមិសាស្ត្រទំនិញ «ទឹកឃ្មុំព្រៃមណ្ឌលគិរី»។

លោកថា នេះគឺជាមោទកភាពសម្រាប់បងប្អូនសហគមន៍មូលដ្ឋាន និងជាផ្នែកមួយយ៉ាងសំខាន់ក្នុងការទទួលស្គាល់គុណភាពនៃទឹកឃ្មុំព្រៃមណ្ឌលគិរី និងចូលរួមបង្កើនប្រាក់ចំណូលដល់សមាជិកនៃសមាគមអភិរក្សឃ្មុំព្រៃមណ្ឌលគិរី ក៏ដូចជាជួយលើកស្ទួយជីវភាពរបស់ពួកគាត់បន្ថែមទៀត។

លោក នេត្រ ភក្ត្រា ថា ក្នុងចំណោមសមាជិកចំនួន ១០ នៃសមាគមអភិរក្សឃ្មុំព្រៃមណ្ឌលគិរី ក្នុងនោះមានតំបន់ការពារធម្មជាតិចំនួន ៥ ក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន។

លោក សេង ទៀក នាយកអង្គការWWF បានឱ្យដឹងថា ផលិតផលសម្គាល់ភូមិសាស្ត្រនេះមានសារៈសំខាន់ណាស់ ព្រោះវាមិនត្រឹមតែជម្រុញទឹកចិត្តឲ្យចូលរួមការពារព្រៃឈើដែលជាប្រភពផ្កាព្រៃគ្រប់ប្រភេទនិងជាទីជម្រកសម្រាប់ឃ្មុំព្រៃនិងសត្វព្រៃប៉ុណ្ណោះទេ វាថែមទាំងជួយថែរក្សាប្រពៃណីរបស់ជនជាតិដើមភាគតិច និងជួយបង្កើតមុខរបរថ្មីៗនិងប្រាក់ចំណូលជាច្រើនទៀតដល់សមាជិកសហគន៍មូលដ្ឋាន។

អង្គការ WWF រួមជាមួយក្រសួងបរិស្ថាន មន្ទីរបរិស្ថាន រដ្ឋបាលព្រៃឈើ មន្ទីរកសិកម្ម រុក្ខាប្រមាញ់និងនេសាទ និងអង្គការដៃគូរនានា នឹងបន្តជួយគាំទ្រ និងជំរុញសហគន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ ដែលផលិតផលទឹកឃ្មុំព្រៃនៅសេសសល់ក្នុងខេត្តមណ្ឌលគិរីទាំងអស់ឲ្យចូលជាសមាជិកផលិតផលសម្គាល់ភូមិសាស្ត្រ៕

# រដ្ឋាភិបាល និងយុវជនកម្ពុជា៖ បញ្ហាសុវត្ថិភាពចំណីអាហារ គឺជាកង្វល់របស់យុវជនទាំងអស់ ដែលត្រូវរួមគ្នាធ្វើឱ្យស្ថានភាពអាហារូបត្ថម្ភប្រសើរឡើង



*អត្ថបទ៖ អមរិទ្ធ ដានុត*

របាយការណ៍របស់ការិយាល័យសុវត្ថិភាពចំណីអាហារនៃនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសម្អាងរបស់ក្រសួងសុខាភិបាល បង្ហាញថា ចាប់តាំងពីឆ្នាំ២០១៥ ដល់ឆ្នាំ២០២១ មានមនុស្ស១១៩នាក់ បានស្លាប់ក្នុងករណីពុលចំណីអាហារនិងមានអ្នករងគ្រោះសរុបមានចំនួន៤,៦៩៩នាក់។

នៅពេលកន្លងទៅថ្មីៗនេះក៏មានរបាយការណ៍ជាបន្តបន្ទាប់របស់អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ នៃក្រសួងពាណិជ្ជកម្ម និងក្រសួងសុខាភិបាលដែលបានបង្ហាញពីបញ្ហាទឹកដោះគោម្សៅផ្សំតាមរូបមន្តដែលមានកម្រិតជាតិដែកនិងជាតិសង្ក័សីទាបខ្លាំងហើយបណ្តាលឲ្យទារកជាច្រើនមានបញ្ហាកង្វះជាតិដែកធ្ងន់ធ្ងរព្រមទាំងចូលមន្ទីរពេទ្យ។

អាហារគ្មានសុវត្ថិភាពបង្កការគំរាមកំហែងដល់សុខភាពជាសាកល ដែលបង្កគ្រោះថ្នាក់ដល់មនុស្សគ្រប់រូប។ ទារក កុមារតូច ស្ត្រីមានផ្ទៃពោះ មនុស្សចាស់ និងអ្នកដែលមានជំងឺគឺងាយរងគ្រោះជាមួយនឹងបញ្ហាសុវត្ថិភាពម្ហូបអាហារ។

អង្គការសុខភាពពិភពលោកបានបញ្ជាក់ថា ជារៀងរាល់ឆ្នាំកុមារ ២២០ លាននាក់កើតជំងឺរាករូស ហើយ ៩៦,០០០ បានស្លាប់ដោយបញ្ហាសុវត្ថិភាពចំណីអាហារ។ ចំណីអាហារគ្មានសុវត្ថិភាពបានបង្កើតវដ្តដ៏កាច សាហាវនៃជំងឺរាករូសនិងកង្វះអាហារូបត្ថម្ភ ដែលគំរាមកំហែងដល់ស្ថានភាពអាហារូបត្ថម្ភរបស់អ្នកដែលងាយរងគ្រោះបំផុត។

លោក សុខ ស៊ីទ្ធ អគ្គលេខាធិការក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ បានលើកឡើងថា អាហារក្នុងចានរបស់មនុស្សមានឥទ្ធិពលខ្លាំងណាស់ចំពោះសុខភាព។ ទាំងអស់គ្នាប្រាថ្នាចង់បានអាហារដែលមានគុណភាពនិងសុវត្ថិភាពដើម្បីធានាបាននូវសុខភាពល្អ ប៉ុន្តែអាហារអាចក្លាយទៅជាវត្ថុកខ្វក់ ឬមានជាតិពុលដោយសារតែមានសារធាតុគីមីហួសកម្រិត ដែលធ្វើឱ្យបាត់បង់សុវត្ថិភាពនៅចំណុចណាមួយនៃការផលិត ការកែច្នៃនិងការចែកចាយ និងការរក្សាទុក។

លោកបានថ្លែងថា ៖ «ការទទួលខុសត្រូវចម្បងគឺស្ថិតនៅលើអ្នកផលិតនិងកែច្នៃអាហារនេះឯង។ នៅក្នុងប្រទេសកម្ពុជា ប្រជាជនទូទៅ

> ប្រជាជនទូទៅរួមទាំងយុវជនផងដែរ មានការព្រួយបារម្ភខ្លាំងពីសុវត្ថិភាពម្ហូបអាហារ ហើយតែងតែពិភាក្សាពីបញ្ហាបន្លែនិងផ្លែឈើ...

រួមទាំងយុវជនផងដែរ មានការព្រួយបារម្ភខ្លាំងពីសុវត្ថិភាពម្ហូបអាហារ ហើយតែងតែពិភាក្សាពីបញ្ហាបន្លែនិងផ្លែឈើ ព្រមទាំងផលិតផលអាហារមួយចំនួនទៀត នៅលើទីផ្សារមានសារធាតុគីមីដែលអាចធ្វើឲ្យប៉ះពាល់ដល់សុខភាព»។

នៅឆ្នាំ២០១៩ វិទ្យាស្ថានកម្ពុជាសម្រាប់ការស្រាវជ្រាវនិងអភិវឌ្ឍន៍ជនបទបានរកឃើញថា មានអ្នកចូលរួមសម្ភាសន៍ចំនួន៩៧%បាននិយាយថាអាហារដែលមានលក់នៅលើទីផ្សារពុំមានសុវត្ថិភាពគ្រប់គ្រាន់ទេ។ អ្នកចូលរួមសម្ភាសន៍ជាង៥០%បាននិយាយថាពួកគេមានបទពិសោធន៍ចុកចួល និងឈឺពោះបន្ទាប់ពីទទួលទានអាហារដែលបានទិញមកពីផ្សារ។

អ្នកចូលរួមសម្ភាសន៍ជាង៥០%ក៏បាននិយាយថាពួកគេចង់ឲ្យមានការពង្រឹងលើការអនុវត្តន៍ច្បាប់ ឬបទបញ្ញត្តិនានា ពាក់ព័ន្ធនឹងសុវត្ថិភាពចំណីអាហារនិងច្បាប់ការពារអ្នកប្រើប្រាស់ឲ្យបានម៉ឺងម៉ាត់និងមានប្រសិទ្ធភាពខ្ពស់ដើម្បីធានាបានសុខមាភាពដល់អ្នកទទួលទាន។

កញ្ញា ឈុន បូរមី អ្នកសម្របសម្រួលក្រុមយុវជនជើងឯកអាហារូបត្ថម្ភនៃអង្គការ ហែឡែន ខេលល័រ អន្តរជាតិ (Helen Keller International) បានលើកឡើងផងដែរថា បញ្ហាសុវត្ថិភាពចំណីអាហារគឺជាកង្វល់របស់យុវជនទាំងអស់ ដែលពួកគេមានការព្រួយបារម្ភខ្លាំងណាស់លើចំណីអាហារដែលដាក់លក់លើទីផ្សារនាពេលសព្វថ្ងៃនេះជាពិសេសបន្លែ ផ្លែឈើ ត្រី សាច់ដែលនាំចូល និងផលិតផលិតផលអាហារកែច្នៃ ដែលប្រើប្រាស់សារធាតុគីមីលើសកម្រិត។

កញ្ញា ឈុន បូរមី បានឱ្យដឹងថា ៖ «យុវជនមានក្តីព្រួយបារម្ភណ៍ថាចំណីអាហារដែលមានសារធាតុគីមីលើសកម្រិតទាំងនោះអាចបង្ករគ្រោះថ្នាក់ដល់សុខភាពធ្ងន់ធ្ងរក្នុងរយៈពេលវែងដូចជាជំងឺមហារីកជាដើម។ យុវជនយើងទាំងអស់គ្នាប្រាថ្នាចង់បាននូវការធានាសុវត្ថិភាពលើចំណីអាហារទាំងឡាយដែលដាក់លក់នៅតាមសាលានិងទីផ្សារទាំងអស់នៅកម្ពុជា ប្រយោជន៍ដើម្បីធានាបាននូវសុខមាលភាពមនុស្សគ្រប់ៗរូប»។

យុវជន ក៏ជាតួអង្គដ៏សំខាន់មួយក្នុងការជួយជំរុញការផ្លាស់ប្តូរនិងជាអ្នកដឹកនាំមិនអាចខ្វះបាន







ដើម្បីធានានិងលើកកម្ពស់ការយល់ដឹងនិងការអនុវត្តរបបអាហារសុខភាព និងសុវត្ថិភាពចំណីអាហារសម្រាប់ទាំងអស់គ្នាក្នុងការរួមចំណែកកាត់បន្ថយបញ្ហាអាហារូបត្ថម្ភគ្រប់ទម្រង់នៅកម្ពុជា។

កញ្ញា ឈុន បូរមី បានបញ្ជាក់ថា ៖ «យើងសង្កេតឃើញថាការយល់ដឹងនិងការអនុវត្តរបស់យុវជនអំពីការបរិភោគចំណីអាហារដែលមានសុវត្ថិភាពនិងរបបអាហារសុខភាព នៅមានកម្រិតនៅឡើយ ហើយបច្ចុប្បន្ននេះចំណីអាហារមួយចំនួនមានសារធាតុគីមីដែលងាយបង្កគ្រោះថ្នាក់ដល់អ្នកបរិភោគទាំងរយៈពេលវែងនិងរយៈពេលខ្លី»។

យុវតីរូបនេះ បានលើកទឹកចិត្តមិត្តយុវជនទាំងអស់ត្រូវបង្ហាញនូវ ភាពអង់អាចក្លាហានហ៊ានបញ្ចេញយោបល់ មានគំនិតឆ្នៃប្រឌិតខ្ពស់ មានទស្សនៈវិស័យវែងឆ្ងាយប្រកបដោយមហិច្ឆតា ដើម្បីយុវជនអាចចូលរួមធ្វើផែនការណ៍ និងអនុវត្តគោលនយោបាយទាំងឡាយស្តីពីសុវត្ថិភាពចំណីអាហារ។

អគ្គនាយករងនៃអគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប) នៃក្រសួងពាណិជ្ជកម្ម លោក ឌឹម ថេង ធ្លាប់បានថ្លែងប្រាប់សារព័ត៌មានក្នុងស្រុកថា ក.ប.ប បាននិងកំពុងយកចិត្តទុកដាក់ខ្ពស់លើសុវត្ថិភាពចំណីអាហារ ដើម្បីធានាបាននូវ សុខមាលភាពរបស់អ្នកប្រើប្រាស់។

លោកថា ក្រុមការងារបច្ចេកទេស ក.ប.ប បានចុះត្រួតពិនិត្យទីផ្សារលក់ផលិតផលអាហារជាប្រចាំ ក្នុងបំណងធ្វើយ៉ាងណាឲ្យផលិតផលទាំងអស់ ដែលដាក់លក់តាមទីផ្សារមានសុវត្ថិភាព និងអនុលោមតាមស្តង់ដារ និងបទបញ្ញត្តិ។

លោក ឌឹម ថេង បានថ្លែងថា ៖ «ប៉ុន្តែទោះយ៉ាងណា ក៏នៅមានចំណុចខ្វះចន្លោះច្រើន ដែលតម្រូវឲ្យភាគីពាក់ព័ន្ធធ្វើការរួមគ្នា ដើម្បីការងារមានប្រសិទ្ធភាពខ្ពស់»។




លោកស្រី Sanne Sigh តំណាងគម្រោង MUSEFO នៃអង្គការ GIZ បានឱ្យដឹងដែរថា យុវជនជាអនាគតរបស់កម្ពុជា។ យុវជនគឺជាតួអង្គសម្រាប់ការផ្លាស់ប្តូរ និងជាអ្នកដឹកនាំនាពេលខាងមុខនៅក្នុងការធានា និងលើកកម្ពស់របបអាហារសុខភាពល្អ សុវត្ថិភាពចំណីអាហារប្រកបដោយនិរន្តរភាពសម្រាប់ទាំងអស់គ្នា ជាពិសេសសម្រាប់ស្ត្រីដែលងាយរងគ្រោះនិងកុមារតូច ដើម្បីដោះស្រាយបញ្ហាអាហារូបត្ថម្ភគ្រប់ទម្រង់។

> អ្នកគឺជាអ្នកមានឥទ្ធិពល! អ្នកគឺជាអ្នកអាចផ្លាស់ប្តូរ! ហើយក្នុងពេលជាមួយគ្នានេះ អ្នកគឺជាតួអង្គសកម្មខ្លាំងនៅក្នុងប្រព័ន្ធស្បៀងនិងសុវត្ថិភាពចំណីអាហារ

លោកស្រីថា ៖ «អ្នកគឺជាអ្នកមានឥទ្ធិពល! អ្នកគឺជាអ្នកអាចផ្លាស់ប្តូរ! ហើយក្នុងពេលជាមួយគ្នានេះ អ្នកគឺជាតួអង្គសកម្មខ្លាំងនៅក្នុងប្រព័ន្ធស្បៀងនិងសុវត្ថិភាពចំណីអាហារ។ ថ្ងៃមួយ អ្នកអាចដឹកនាំផ្លូវដោយមិនដឹងខ្លួនលើការលើកកម្ពស់សុវត្ថិភាពចំណីអាហារនៅគ្រប់ដំណាក់កាលទាំងអស់ ចាប់ពីការគ្រប់គ្រងរហូតដល់ការរៀបចំនិងការរក្សាទុកចំណីអាហារ។ អ្នកមានសំឡេង ដូច្នេះសូមប្រើសំឡេងរបស់អ្នក»។

ជាមួយគ្នានេះដែរ លោក សុខ ស៊ីទ្ធ បានបញ្ជាក់ថា កម្ពុជាបាននិងកំពុងប្រឈមមុខជាខ្លាំងលើសុវត្ថិភាពចំណីអាហារដែលទាមទារឲ្យភាគីពាក់ព័ន្ធ ចូលរួមដោះស្រាយជាប្រព័ន្ធប្រកបដោយប្រសិទ្ធភាពខ្ពស់មួយ។

លោកថា ៖ «សុវត្ថិភាពម្ហូបអាហារបានដើរតួនាទីយ៉ាងសំខាន់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់យើង។ សុវត្ថិភាពចំណីអាហារនេះក៏មានការពាក់ពន្ធ័ដោយផ្ទាល់លើប្រព័ន្ធស្បៀងគឺចាប់ពីដំណាក់កាលផលិតកម្ម ការកែច្នៃ ការចែកចាយ និងរក្សាទុក រហូតដល់ការរៀបចំនិងការបរិភោគអាហារ ពោលគឺចាប់ពីកសិដ្ឋានរហូតដល់តុបាយ»។

ស្ថិតនៅក្នុងស្ថានភាពដ៏លំបាកនៃការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩នេះ ការពង្រឹងប្រព័ន្ធស្បៀង ដើម្បីសុវត្ថិភាពចំណីអាហារនិងរបបអាហារសុខភាពកាន់តែមានសារៈសំខាន់ ដែលតម្រូវឱ្យគ្រប់តួអង្គពាក់ព័ន្ធទាំងអស់យកចិត្តទុកដាក់ខ្ពស់ក្នុងការធ្វើឱ្យប្រព័ន្ធស្បៀងកាន់តែរឹងមាំ ផ្តល់នូវសន្តិសុខស្បៀងនិងអាហារូបត្ថម្ភសម្រាប់មនុស្សគ្រប់រូប មានភាពធន់នឹងបម្រែបម្រួលអាកាសធាតុ និងមានចីរភាពបរិស្ថាន ចីរភាពសង្គម និងចីរភាពសេដ្ឋកិច្ច សម្រាប់មនុស្ស ភពផែនដី និងវិបុលភាព។

លោក សុខ ស៊ីទ្ធ ថា ៖ «ខ្ញុំសូមអំពាវនាវឲ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ សូមបន្តកិច្ចសហការ និងចូលរួមជាមួយក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ដើម្បីយើងរួមគ្នា បញ្ចប់ភាពអត់ឃ្លាន សម្រេចឱ្យបានសន្តិសុខស្បៀង ធ្វើឱ្យប្រសើរឡើងស្ថានភាព អាហារូបត្ថម្ភ និងលើកកម្ពស់កសិកម្មប្រកបដោយចិរភាព នៅកម្ពុជា៕





# គម្រោងបណ្ដាញមន្ទីរពេទ្យវៃឆ្លាតបៃតង បង្កើន គុណភាពនៃការព្យាបាល តាមរយៈប្រព័ន្ធឌីជីថល

*អត្ថបទ៖ អមរិន្ទ ដានុត*

ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ប្រចាំកម្ពុជា លោក W. Patrick Murphy បានសាទរចំពោះមន្ទីរពេទ្យ និងគ្លីនិកឯកជន ចំនួន ២០ ដែលបានអនុវត្តគម្រោងបណ្ដាញមន្ទីរពេទ្យវៃឆ្លាតបៃតង ដោយជោគជ័យ ហើយលោករំពឹងថា គម្រោងនេះនឹងចូលរួមចំណែកយ៉ាងខ្លាំង ជួយជ្រុំជ្រែងដល់ការផ្ដល់សេវាជូនអតិថិជន ព្រមទាំងចូលរួមចំណែកក្នុងការកាត់បន្ថយដល់ផលប៉ះពាល់បរិស្ថាន និងការប្រែប្រួលអាកាសធាតុផងដែរ។



លោកបានថ្លែងដូចនេះ ក្នុងពិធីសិក្ខាសាលាផ្សព្វផ្សាយលទ្ធផលគម្រោង ស្ដីពី «ការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីលើកកម្ពស់គុណភាពសេវាសុខាភិបាល និងមន្ទីរពេទ្យវៃឆ្លាតបៃតង» ដែលគម្រោងនេះ បានឧបត្ថម្ភគាំទ្រមន្ទីរពេទ្យ និងគ្លីនិក មកពីភ្នំពេញ បាត់ដំបង និងសៀមរាប ឱ្យចូលរួមអនុវត្តគម្រោងនេះ និងបានដាក់ឈ្មោះថា «បណ្ដាញសមាជិកមន្ទីរពេទ្យវៃឆ្លាតបៃតង»។





បណ្ដាញមន្ទីរពេទ្យវៃឆ្លាតបៃតង គឺជាបណ្ដាញសមាជិកមន្ទីរពេទ្យ និងគ្លីនិក ចំនួន ២០ ដែលបានចូលរួមនៅក្នុងយុទ្ធនាការស្ដីពី បរិស្ថានទីក្រុងស្អាត និងបៃតង ដោយបានផ្លាស់ប្ដូរពីការប្រើប្រាស់ក្រដាស ការព្រីនឯកសារ និងកាត់បន្ថយការប្រើប្រាស់សម្ភារៈនានា នៅក្នុងមន្ទីរពេទ្យ ហើយងាកមកប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងមន្ទីរពេទ្យឌីជីថល «ពេទ្យយើង» ដើម្បីលើកកម្ពស់បច្ចេកវិទ្យា នៅក្នុងមន្ទីរពេទ្យបៃតង។

លោក W. Patrick Murphy មានប្រសាសន៍ថា៖ «គម្រោងដើមរបស់យើង គឺយើងចង់ឱ្យមានកំណត់ត្រាអ្នកជំងឺ ត្រឹមតែ ៣៥ ០០០នាក់ប៉ុណ្ណោះ ប៉ុន្តែក្នុងពេលអនុវត្ត គម្រោងនេះ សម្រេចបានដល់ទៅជាង ១០ម៉ឺននាក់»។ លោកបានបន្ថែមថា៖ «ដូច្នេះគម្រោងរបស់យើង រវាងដៃគូ ជាមួយសហរដ្ឋអាមេរិកនេះ មិនត្រឹមតែជាគំនិតផ្ដួចផ្ដើមគម្រោងទាក់ទងនឹងសុខភាព នៅក្នុងវិស័យសុខាភិបាលនោះទេ តែក៏គិតដល់វិស័យផ្សេងៗទៀត នៅក្នុងវិស័យនេះ ទាក់ទងនឹងគម្រោងទីក្រុងឆ្លាតវៃ ទាក់ទងនឹងគម្រោងសេដ្ឋកិច្ចឌីជីថល និងពង្រឹងភាពអង់អាចរបស់ស្ត្រី រួមទាំងការប្រយុទ្ធប្រឆាំងនឹងការប្រែប្រួលអាកាសធាតុ»។

យោងតាមសេចក្ដីប្រកាសព័ត៌មានរបស់ពេទ្យយើង ស្ដីពីការប្រើប្រាស់បច្ចេកវិទ្យា ដើម្បីលើកកម្ពស់គុណភាពសេវាសុខាភិបាល និងមន្ទីរពេទ្យវៃឆ្លាតបៃតង បានលើកឡើងថា មន្ទីរពេទ្យ និងគ្លីនិកទាំង ២០ ដែលជាសមាជិក នៅក្នុងគម្រោង បានសម្រេចចិត្តចូលរួមនៅក្នុងបណ្ដាញសមាជិកមន្ទីរពេទ្យវៃឆ្លាតបៃតង ដោយបានផ្លាស់ប្ដូរមន្ទីរពេទ្យរបស់ខ្លួន ពីការប្រើប្រាស់ក្រដាស មកជាឌីជីថលវិញ ដើម្បីផ្ដល់ភាពងាយស្រួល ក្នុងការគ្រប់គ្រង និងប្រតិបត្តិការ នៅក្នុងមន្ទីរពេទ្យរបស់ខ្លួន ព្រមទាំងលើកកម្ពស់ប្រព័ន្ធបច្ចេកវិទ្យា ក្នុងវិស័យសុខាភិបាល នៅកម្ពុជា។

ប្រភពដដែលនេះបានបន្តថា គម្រោងបណ្ដាញមន្ទីរពេទ្យវៃឆ្លាតបៃតង បានចាប់ផ្ដើម កាលពីខែតុលា ឆ្នាំ២០២០ និងបញ្ចប់នៅបំណាច់ខែមីនា ឆ្នាំ២០២២ នេះ។ គម្រោងនេះ ចូលរួមប្រើប្រាស់ពីវេជ្ជបណ្ឌិត និងបុគ្គលិកមន្ទីរពេទ្យ ចំនួន ៨៦៧នាក់ ព្រមទាំងគ្រប់គ្រងទិន្នន័យប្រវត្តិអ្នកជំងឺ ចំនួន ១០៨ ៧៥០នាក់ ដែលភាគច្រើនជាស្ត្រី។

តាមរយៈការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងមន្ទីរពេទ្យឌីជីថលពេទ្យយើង មិនត្រឹមតែចូលរួមនៅក្នុងយុទ្ធនាការបរិស្ថាន ទីក្រុងស្អាត និងបៃតង ប៉ុណ្ណោះទេ ប៉ុន្តែវាបានជួយពន្លឿនរាល់ប្រតិបត្តិការទាំងអស់ នៅក្នុងមន្ទីរពេទ្យ ឬគ្លីនិក តាមរយៈប្រព័ន្ធឌីជីថល ដើម្បីជំរុញឱ្យការព្យាបាលកាន់តែលឿន រហ័ស ទំនើប ចំណេញពេលវេលា និងថវិកា សម្រាប់អ្នកផ្ដល់សេវា និងអ្នកជំងឺ ជាពិសេសអ្នកជំងឺជាស្ត្រី និងកុមារ។

លោកស្រី ប៉ុង លីមសាន ស្ថាបនិក និងជានាយកប្រតិបត្តិកម្មវិធីពេទ្យយើង នៃក្រុមហ៊ុន ហ្វីស វីម៉ិន ថេក អេស៊ា បានលើកឡើងថា គម្រោងបណ្ដាញមន្ទីរពេទ្យវៃឆ្លាតបៃតង (Green Network Hospital) មានគោលបំណងបង្កើនគុណភាពនៃការព្យាបាល តាមរយៈប្រព័ន្ធឌីជីថល។ មានន័យថា មន្ទីរពេទ្យទាំងអស់ ធ្វើប្រតិបត្តិការ ចាប់ពីអ្នកជំងឺចូល រហូតដល់អ្នកជំងឺចេញ រួមទាំងប្រតិបត្តិការផ្នែកផ្សេងទៀត នៅក្នុងមន្ទីរពេទ្យ តាមប្រព័ន្ធឌីជីថល។

លោកស្រី ប៉ុង លីមសាន បានបន្ថែមថា៖ «យើងក៏មានគោលបំណងមួយទៀត គឺចូលរួមជួយដល់បរិស្ថាន ព្រោះយើងដឹងហើយថា កន្លងមកតាមមន្ទីរពេទ្យ ប្រើប្រាស់ក្រដាសក្នុងការបំពេញឯកសារអ្នកជំងឺ និងប្រតិបត្តិការនានា។ ប៉ុន្តែនៅពេលនេះ យើងជំនួសប្រតិបត្តិការទាំងអស់នោះ តាមប្រព័ន្ធឌីជីថល។ គម្រោងរបស់យើង ក៏ជួយច្រើនលើអ្នកជំងឺ ដែលជាស្ត្រី និងកុមារផងដែរ»។

ចំណែកលោកស្រី ឱ វណ្ណឌីន រដ្ឋលេខាធិការក្រសួងសុខាភិបាល បានថ្លែងឱ្យដឹងដែរថា គម្រោង «ការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់ដំណើរការមន្ទីរពេទ្យវៃឆ្លាតបៃតង» សំដៅចូលរួមចំណែកនៅក្នុងការធ្វើទំនើបកម្មបច្ចេកវិទ្យា ឌីជីថល នៅក្នុងវិស័យសុខាភិបាលកម្ពុជា ហើយក៏ជាការបោះជំហានជាវិជ្ជមានមួយទៀត នៅក្នុងការរួមចំណែកអនុវត្តផែនការយុទ្ធសាស្ត្រសុខាភិបាលជាតិ ដែលបាន និងកំពុងតែផ្ដោតការយកចិត្តទុកដាក់ខ្ពស់ លើការធ្វើទំនើបកម្មបច្ចេកវិទ្យា ឌីជីថល នៅតាមមន្ទីរពេទ្យរដ្ឋ និងឯកជន។

លោកស្រីមានប្រសាសន៍ថា៖ «កម្មវិធីពេទ្យយើង ជាចំណែកមួយក្នុងការបង្កើនសក្ដានុពលដ៏វិសេសវិសាលទៅលើការផ្ដល់សេវាពិគ្រោះ និងព្យាបាលជំងឺតាមបែបឌីជីថល ជូនដល់បងប្អូនប្រជាពលរដ្ឋ ដែលប្រើប្រាស់សេវាមន្ទីរពេទ្យឯកជន និងជាការចូលរួមចំណែកមួយផងដែរ នៅក្នុងការអភិវឌ្ឍន៍វិស័យសុខាភិបាលកម្ពុជា តាមបែបឌីជីថល»។

គម្រោងនេះ បានជួយដល់មន្ទីរពេទ្យឯកជន នៅក្នុងរាជធានីភ្នំពេញ ខេត្តបាត់ដំបង និងខេត្តសៀមរាប ឱ្យដំណើរការគ្រប់គ្រងសេវាព្យាបាលជំងឺបែបឌីជីថល និងនាំឱ្យមន្ទីរពេទ្យ និងគ្លីនិកឯកជនទាំងអស់នោះ មានតួនាទី មិនត្រឹមតែជាអ្នកផ្ដល់សេវា ប្រកបដោយការទទួលខុសត្រូវទេ ប៉ុន្តែបានក្លាយជាមន្ទីរពេទ្យ និងគ្លីនិកមានការទទួលខុសត្រូវចូលរួមកសាងទីក្រុងបៃតង និងបរិស្ថានស្អាតទៀតផង។

លោកស្រី ឱ វណ្ណឌីន បន្តថា៖ «ការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលទំនើប សម្រាប់លើកកម្ពស់គុណភាពសេវាសុខាភិបាល ក៏ជាចំណុចសំខាន់មួយ ដែលត្រូវបានរាប់បញ្ចូល គិតគូរ និងផ្ដួចផ្ដើមនៅក្នុងគោលនយោបាយយុទ្ធសាស្ត្ររបស់ក្រសួងសុខាភិបាល ហើយក្រសួងសុខាភិបាលក៏កំពុងតែគាំទ្រ និងជំរុញលើកទឹកចិត្តឱ្យមានការចូលរួមឱ្យបានពេញលេញពីគ្រប់ភាគីពាក់ព័ន្ធទាំងស្ថាប័នរដ្ឋ វិស័យឯកជន និងអង្គការដៃគូនានា»។

កម្មវិធីពេទ្យយើង ដោយក្រុមហ៊ុន ហ្វីស វីម៉ិន ថេក អេស៊ា ជាប្រព័ន្ធគ្រប់គ្រងមន្ទីរពេទ្យឌីជីថលដំបូងគេនៅកម្ពុជា ដែលត្រូវបានបង្កើតឡើងដើម្បីចូលរួមចំណែកកសាងប្រព័ន្ធសុខាភិបាលទំនើបឌីជីថលនៅកម្ពុជា និង សំរាប់សហគមន៍អាស៊ានតាមរយៈការផ្ដល់សុវត្ថិភាពដល់កំណត់ត្រាព្យាបាល ទិន្នន័យសុខភាពអ្នកជំងឺ និងជួយឲ្យគ្លីនិក និងមន្ទីពេទ្យ ដៃគូដំណើរការរលូន និងពុំមានការរំខាន។

លោក ប៊ិន សុជាតិ ទីប្រឹក្សាស្ថាបនិក និងគ្រប់គ្រងអាជីវកម្ម «ពេទ្យយើង» របស់ក្រុមហ៊ុន ហ្វីស វីម៉ិន ថេក អេស៊ា បានប្រាប់ថា លោកកំពុងតែរៀបចំគម្រោងស្នើសុំការគាំទ្រជំហ៊ានទីពីរ ប៉ុន្តែលោកនៅមិនទាន់ដឹងថាតើខាងម្ចាស់គម្រោងសម្រេចបែបណានៅឡើយទេ។

លោកបានបញ្ជាក់ថា៖ «បើជោគជ័យ យើងនឹងគាំទ្រ២៦ មន្ទីរពេទ្យ និងគ្លីនិកឯកជនថ្មីផ្សេងទៀត ហើយបន្ថែមក្រុងគោលដៅវៃឆ្លាតថ្មី នៅខេត្តកណ្ដាល កំពត និងខេត្តកែប»៕





# ក្រសួងបរិស្ថានបាននិងកំពុងអនុវត្តគម្រោង និរន្តរភាព តំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា

*អត្ថបទ៖ អមរិន្ទ ដានុត*




ក្រសួងបរិស្ថានបាននិងកំពុងអនុវត្តគម្រោងនិរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជា-CSLEP ដើម្បីធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងតំបន់ការពារធម្មជាតិ ជំរុញឱកាសសម្រាប់អភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ និងបង្កើនប្រវ៉ាក់តម្លៃអនុផលព្រៃឈើ នៅតំបន់ជួរភ្នំក្រវាញ និងបឹងទន្លេសាប។

នេះជាការលើកឡើងរបស់លោក សៅ សុភាព រដ្ឋលេខាធិការក្រសួងបរិស្ថាន ថ្លែងក្នុងសិក្ខាសាលាពិគ្រោះយោបល់ស្ដីពី «ហិរញ្ញប្បទានប្រកបដោយចីរភាព សម្រាប់តំបន់ការពារធម្មជាតិ និងការអភិរក្សជីវៈចម្រុះនៅកម្ពុជា»។

លោក សៅ សុភាព បានថ្លែងថា គម្រោងនេះមានរយៈពេល ៦ឆ្នាំ (២០២០-២០២៥) ដែលបាននិងកំពុងអនុវត្តដោយសហការជាមួយអង្គការ UNDP នៅក្នុងខេត្តគោលដៅចំនួន ៧ រួមមាន ខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ កោះកុង បាត់ដំបង សៀមរាប និងខេត្តកំពង់ធំ។

លោកបានថ្លែងថា៖ «គម្រោងនិរន្តរភាពតំបន់ទេសភាព និងទេសចរណ៍ធម្មជាតិកម្ពុជានេះ ត្រូវបានអនុវត្តរួមគ្នាដោយក្រសួងបរិស្ថាន និងក្រសួងអភិវឌ្ឍន៍ជនបទ និងត្រូវបានបែងចែកជា ៥ សមាសភាគសំខាន់ៗ»។

សមាសភាគទាំងនោះរួមមាន៖ ការពង្រឹងសមត្ថភាពក្នុងការរៀបចំផែនការ និងការគ្រប់គ្រងតំបន់ទេសភាព, ការពង្រឹងឱកាសសម្រាប់ការអភិវឌ្ឍទេសចរណ៍ធម្មជាតិ និងខ្សែប្រវ៉ាក់តម្លៃអនុផលព្រៃឈើ, ការជំរុញការតភ្ជាប់ខ្សែផ្លូវចេញ-ចូល នៅតាមជនបទ,ការគ្រប់គ្រងគម្រោង ការត្រួតពិនិត្យ និងការវាយតម្លៃ និងការឆ្លើយតបនឹងគ្រោះអាសន្ន។

គម្រោង CSLEP ក៏បានស្វែងរកជម្រើសហិរញ្ញប្បទានប្រកបដោយចីរភាពសម្រាប់ការគ្រប់គ្រង និងអភិរក្សតំបន់ការពារធម្មជាតិក្នុងប្រទេសកម្ពុជាឱ្យមាននិរន្តរភាព។

អនុរដ្ឋលេខាធិការ ក្រសួង បរិស្ថាន លោកស្រី ចាន់ សុម៉ាលី បានលើកឡើងផងដែរថា គម្រោង CSLEP ត្រូវអនុវត្តបន្តពី ដំណោះស្រាយអាទិភាពចំនួន២ ដែលបានកំណត់នៅក្នុងផែនការហិរញ្ញវត្ថុជីវៈចម្រុះនៃ គម្រោង BIOFIN។

លោកស្រីថា៖ «ការអនុវត្តនេះទទួលបានជោគជ័យ ត្រូវតែពឹងផ្អែកទៅលើប្រភព២សំខាន់ គឺធនធានថវិកា និង ធនធានមនុស្ស»៕

# ឧស្សាហកម្មភាពយន្ត ចម្រៀង និងតន្ត្រី គឺជាឧស្សាហកម្ម ច្នៃប្រឌិតនៅក្នុងវិស័យវប្បធម៌ដែលមានសក្ដានុពល

*អត្ថបទ៖ អមរិន្ទ ដានុត*

ឧស្សាហកម្មភាពយន្ត ចម្រៀង និងតន្ត្រី គឺជាឧស្សាហកម្មច្នៃប្រឌិតនៅក្នុងវិស័យវប្បធម៌ដែលមានសក្ដានុពលមិនចេះរីងស្ងួត ដែលតួអង្គក្នុងវិស័យឯកជនទាំងអស់ត្រូវខិតខំទាញយកឱកាស ទាំងនេះឱ្យបានជាអតិបរមា ជាពិសេសនៅពេលដែលរាជរដ្ឋាភិបាលបានបើកឱ្យដំណើរការឡើងវិញនូវ សកម្មភាពសង្គមនិងសេដ្ឋកិច្ច រួមទាំង សារមន្ទីរ រោងភាពយន្ត រោងសម្ដែងសិល្បៈ ក៏ដូចជាការរៀបចំពិធីអាពាហ៍ពិពាហ៍និងពិធីបុណ្យប្រពៃណីនានាជាដើម។




*(រូបភាពតំណាង) កម្មវិធីមើលរឿងភាគរបស់ Sastra Film៖ រូបភាព Sastra Film*



*ផ្ទាំងផ្សព្វផ្សាយអបអរសាទរទិវាវប្បធម៌ជាតិ លើកទី២៤៖ រូបភាព Sastra Film*

«ការដាក់ចេញនូវនីតិវិធីប្រតិបត្តិស្តង់ដារ (SOP)សម្រាប់ សកម្មភាពសិល្បៈវប្បធម៌ បូករួមនឹងភាពជោគជ័យនៃយុទ្ធនាការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ នៅទូទាំងប្រទេស ខ្ញុំពិតជាមានសុទិដ្ឋិនិយមថាឧស្សាហកម្មវប្បធម៌កម្ពុជានឹងមានសន្ទុះងើបឡើងវិញឆាប់ និងចូលរួមស្ដារជីវភាពរបស់ប្រជាពលរដ្ឋ និងសេដ្ឋកិច្ចកម្ពុជា ទាំងនៅក្នុងអំឡុងនិងក្រោយពេលវិបត្តិកូវីដ-១៩»។ នេះជាការលើកឡើងរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន។

លោកបានថ្លែងឡើងដូចនេះ ក្នុងឱកាសអបអរសាទរទិវាវប្បធម៌ជាតិ លើកទី២៤ ឆ្នាំ២០២២ ក្រោមប្រធានបទ «យុវជនដើម្បីវប្បធម៌ជាតិ»។

ទោះបីក្នុងឆ្នាំ២០២២នេះ ទិវាវប្បធម៌ជាតិត្រូវបន្តរៀបចំទៅតាមគន្លងប្រក្រតីភាពបែបថ្មីក៏ដោយ ប៉ុន្តែនេះ គឺជាស្មារតីយកចិត្តទុកខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាទាំងចំពោះវប្បធម៌ជាតិ និងចំពោះសុខភាពសាធារណៈ ពិសេសនៅក្នុងកាលៈទេសៈដែលវីរុសកូវីដ-១៩ បំប្លែងខ្លួនថ្មីអូមីក្រុង បាននិងកំពុងរីករាលដាលឆ្លងខ្លាំងគួរឱ្យ កត់សម្គាល់នៅក្នុងសហគមន៍។

លោកបានបញ្ជាក់ថា ពីមួយឆ្នាំទៅមួយឆ្នាំ កម្មវិធីអបអរសាទរទិវាវប្បធម៌ជាតិ ត្រូវបានរៀបចំកាន់តែអធិកអធមឡើងៗ ដោយចាប់ពីឆ្នាំ២០១៨ មក រាជរដ្ឋាភិបាលបានរៀបចំឱ្យមានពិធីជួបជុំនិងទទួលទានអាហារសាមគ្គីដ៏ធំរវាងប្រមុខរាជរដ្ឋាភិបាលកម្ពុជា ជាមួយអ្នកសិល្បៈវប្បធម៌ពីគ្រប់មជ្ឈដ្ឋានប្រមាណ៤០០០នាក់។

ដោយឡែក ចំពោះកម្មវិធីអបអរសាទរទិវាវប្បធម៌ ជាតិ លើកទី២៣ ក្នុងឆ្នាំ២០២១កន្លងទៅ រាជរដ្ឋាភិបាលបានផ្អាករាល់កម្មវិធីទាំងឡាយណាដែលមានការ ជួបជុំមនុស្សដោយផ្ទាល់ច្រើន និងសម្រេចរក្សាទុកត្រឹមការរៀបចំសារាចរ គំនូរផ្សាយឯកសារ វីដេអូ និងបដា អបអរសាទរជាដើម ដើម្បីទប់ស្កាត់ការរីករាលដាលឆ្លងជំងឺកូវីដ-១៩ ពិសេសព្រឹត្តិការណ៍ «២០ កុម្ភៈ»។

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានថ្លែងថា៖ «ទោះបីរងផលប៉ះពាល់ពីវិបត្តិនៃជំងឺកូវីដ-១៩ យ៉ាងណាក្ដី សិល្បៈវប្បធម៌កម្ពុជានៅតែមានភាពធន់ប្រៀបបានទៅនឹងកងទ័ពជួរក្រោយ ដែលតែងតែបង្ហាញសកម្មភាពជាប្រចាំក្នុងការជួយជំរុញលើកទឹកចិត្ត ដល់កង ទ័ពជួរមុខ ក្នុងការប្រយុទ្ធប្រឆាំងតតាំងជាមួយមេរោគដ៏កាចសាហាវមួយនេះ»។

តាមរយៈកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា និងភាពជាដៃគូល្អរវាងរដ្ឋនិងឯកជន ធ្វើឱ្យឧស្សាហកម្មភាពយន្ត ចម្រៀង និង តន្ត្រីកម្ពុជាមានការប្រែប្រួលមុខមាត់កាន់តែប្រសើរឡើងគួរជាទីមោទនៈទាំងនៅក្នុងប្រទេសនិងនៅលើឆាកអន្តរជាតិ។

លោកស្រី ភឿង សកុណា រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ បានលើកឡើងដែរថា អនុលោមទៅតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៦នៃរដ្ឋសភា លទ្ធផលការងារដែលសម្រេចបាននេះ គឺអាចចាត់ទុកថាជាលទ្ធផលល្អមួយ នៅក្នុងកាលៈទេសៈដ៏លំបាកជាងគេដែលបណ្ដាលមកពីការបិទខ្ទប់ប្រទេសនិងភូមិសាស្ត្រសំខាន់ៗ បូករួមជាមួយនឹងការផ្អាកសកម្មភាពសង្គម សេដ្ឋកិច្ច និងសិល្បៈវប្បធម៌ស្ទើរជិតពេញមួយឆ្នាំ២០២១កន្លងទៅ៕

# ព្រះវិហារសន្តមីកាអែលបង្កើតសាលាមត្តេយ្យថ្មី

*អត្ថបទ៖ ដាលីស*

លោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ អូលីវីយេ ជ្មីតហាស្លេ បានសម្ពោធអាគារសិក្សាសាលាមត្តេយ្យរបស់ព្រះសហគមន៍សន្តមីកាអែល ដែលមានឈ្មោះថា មជ្ឈមណ្ឌលអប់រំកុមារសន្តមីកាអែល នាព្រឹកថ្ងៃទី៣ មេសា ២០២២ នៅព្រះវិហារសន្តមីកាអែល ក្រុងកំពង់សោម ខេត្តព្រះសីហនុ។



នៅក្នុងកម្មវិធីសម្ពោធនេះ លោកអភិបាល អូលីវីយេ មានប្រសាសន៍ថា សាលាមត្តេយ្យថ្មីនេះអាចណែនាំកូនៗឱ្យរីកចម្រើនទាំងចំណេះដឹង និងមានទំនាក់ទំនងនៅក្នុងជីវិតផ្ទាល់ខ្លួនជាកូន និងជាមិត្ត។ ក្នុងពេលជាមួយគ្នានេះដែរ លោកអភិបាល ក៏អធិដ្ឋានសូមព្រះជាម្ចាស់ប្រទានពរដល់សាលាមត្តេយ្យថ្មីនេះ ដែលជាកន្លែងមួយដែលណែនាំឱ្យកូនៗអាចរៀនដោយអំណរសប្បាយ និងរៀបចំចិត្តគំនិតដោយអប់រំកុមារដើម្បីឱ្យមានអនាគតដ៏សុខសាន្ត។

លោកបូជាចារ្យ អ៊ុន សុន បូជាចារ្យទទួលខុសត្រូវមណ្ឌលសកម្មភាពខេត្តព្រះសីហនុ មានប្រសាសន៍ថា ថ្ងៃនេះយើងមានអំណរសោមនស្សរីករាយមែនទែនដែលបានបើកសាលាថ្មីមួយ ដើម្បីអប់រំកុមារឱ្យត្រៀមចូលថ្នាក់បឋមសិក្សា ដែលមានអាយុចន្លោះ៤ទៅ៥ឆ្នាំ។

លោកបន្តថា សាលានេះបង្កើតឡើងដោយមានបំណងចង់ជួយដល់ឪពុកម្ដាយដែលរវល់ធ្វើការ «ជាពិសេសកន្លែងនេះមិនមែនត្រឹមតែរៀនអក្សរទេ ប៉ុន្តែចង់អប់រំក្មេងៗឱ្យរៀបចំខ្លួន ដើម្បីមានទំនាក់ទំនងរវាងកុមារនិងកុមារ ចេះដឹងគុណនិងអរគុណគ្នាទៅវិញទៅមក និងអប់រំពួកគេឱ្យទៅជាកុមារល្អ ពលរដ្ឋល្អ ព្រោះវិស័យអប់រំជាវិស័យដែលយើងត្រូវការយកចិត្តទុកដាក់ធ្វើជាឪពុកម្ដាយទី២ និងធ្វើនៅក្នុងសេចក្ដីស្រឡាញ់ដើម្បីតបស្នងដឹងគុណដល់ព្រះជាម្ចាស់ដោយអំណោយទាន និងកម្លាំងរបស់យើង»

ទោះបីជាសាលាមត្តេយ្យនេះត្រូវបានសម្ពោធដាក់ឱ្យប្រើប្រាស់ហើយក្ដី ក៏ប៉ុន្តែមិនទាន់បើកបង្រៀននៅឡើយទេ ដែលនឹងចាប់ផ្ដើមមានសកម្មភាពនៅក្រោយពេលចូលឆ្នាំប្រពៃណីខ្មែរ គឺនៅដើមខែឧសភាខាងមុខ ដោយបច្ចុប្បន្នកំពុងទទួលចុះឈ្មោះចូលរៀនបណ្ដើរ។ នេះបើតាមប្រសាសន៍របស់លោក បូជាចារ្យអ៊ុន សុន។

លោក បន្ថែមថា សម្រាប់សាលាមត្តេយ្យនៅកំពង់សោមនេះ យើងត្រូវការការចូលរួមសហការពីមាតាបិតា ឬអាណាព្យាបាលក្នុងការចូលរួមឧបត្ថម្ភប្រចាំខែសមរម្យសម្រាប់ការអប់រំ ដើម្បីទ្រទ្រង់ចំណាយលើម្ហូប និងសម្ភាររៀនកុមារ ហើយចំពោះមាតាបិតាក្រីក្រព្រះសហគមន៍នឹងគិតទៅតាមនោះដែរ។

មណ្ឌលអប់រំកុមារសន្តមីកាអែល មានបន្ទប់សិក្សាសម្រាប់កុមារចំនួន២បន្ទប់ និងអាចទទួលកុមារឲ្យចូលរៀនបានចំនួន១០នាក់ក្នុងមួយបន្ទប់។

ក្រៅពីកិច្ចការងារអប់រំព្រះវិហារក៏មានសកម្មភាពផ្សេងទៀត ដូចជា ចុះសួរសុខទុក្ខអ្នកក្រីក្រ និងចាស់ជរា ជួសជុលនិងសង់ផ្ទះ ចុះសួរសុខទុក្ខទណ្ឌិតក្នុងពន្ធនាគារតាមរយៈសកម្មភាពអន្តរសាសនាជាដើម៕

# កាតូលិកភូមិភាគភ្នំពេញ ទូលសូមសន្តិភាពសម្រាប់ពិភពលោកតាមរយៈព្រះនាងម៉ារី

*អត្ថបទ៖ ដាលីស*

ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ ដឹកនាំដោយលោកអភិបាល អូលីវីយេ ជ្មីតហាស្លេ ទូលអង្វរព្រះជាម្ចាស់តាមរយៈព្រះនាងម៉ារីសម្រាប់សុខសន្តិភាពប្រទេសអ៊ុយក្រែន និងរុស្ស៊ី ព្រមទាំងពិភពលោកទាំងមូល ដោយសូត្រផ្គាំ (អធិដ្ឋានតាមមាលា) រួមជាមួយសម្ដេចប៉ាបហ្វ្រង់ស៊ីស្កូក្នុងថ្ងៃបុណ្យទេវទូតជូនដំណឹងអំពីកំណើតព្រះយេស៊ូដល់ព្រះនាងម៉ារី នារសៀលថ្ងៃទី២៥ មីនា ២០២២។

នៅក្នុងការណែនាំពិធីសូត្រផ្គាំដែលធ្វើឡើងនៅព្រះវិហារព្រះមាតានៃសន្តិភាព អរិយក្សត្រ ក្នុងខេត្តកណ្ដាលលោកអភិបាលមានប្រសាសន៍ថា ថ្ងៃនេះ សម្ដេចប៉ាបហ្វ្រង់ស៊ីស្កូ អញ្ជើញព្រះសហគមន៍នីមួយៗក្នុងពិភពលោក ចួបជុំគ្នានៅវិសាលវិហារឬកន្លែងដែលគោរពព្រះនាងម៉ារី ដើម្បីអធិដ្ឋានសូមសុខសន្តិភាពនៅក្នុងពិភពលោក និងដើម្បីថ្វាយប្រទេសអ៊ុយក្រែន និងរុស្ស៊ីក៏ដូចជាប្រទេសនានាក្នុងពិភពលោក ដែលកំពុងមានសង្គ្រាម ទៅក្នុងព្រះបេះដូងដ៏និមលរបស់ព្រះនាងម៉ារី ដែលជាម្ចាស់ក្សត្រីយ៍នៃសន្តិភាព។

ក្រោយបញ្ចប់ពិធីសូត្រផ្គាំ ព្រះសហគមន៍បានបន្តដោយមានអភិបូជា។ នៅក្នុងធម្មទេសនា លោកអភិបាលរំលឹកបន្ថែមថា ថ្ងៃនេះយើងនឹករឭកថ្ងៃព្រះយេស៊ូចាប់កំណើតនៅក្នុងផ្ទៃពោះព្រះនាងម៉ារី។ ទេវទូតនិយាយទៅកាន់ព្រះនាងម៉ារីថា «គ្មានការអ្វីដែលព្រះជាម្ចាស់ធ្វើមិនកើតឡើយ។»



លោកអភិបាលបន្ថែមថា ព្រះនាងម៉ារីនៅលើផែនដីនេះជាសញ្ញាសម្គាល់នៃស្ថានបរមសុខ ដោយព្រះនាងម៉ារីណែនាំឱ្យមានសុខដុមរនា ដែលយើងត្រូវការ នាំឱ្យអំពើហិង្សា ការស្អប់គ្នារលត់បាត់ និងកាត់បន្ថយការសងសឹកនិងចេះលើកលែងទោស។ លើសពីនេះព្រះនាងម៉ារីរំដោះ និងថែរក្សាពិភពលោកពីសង្គ្រាម។

លោកអភិបាលអូលីវីយេ បន្តថា នៅពេលដែលយើងអធិដ្ឋានផ្គាំ ឬអធិដ្ឋានតាមមាលា នាំឲ្យយើងមើលឃើញនូវអាថ៌កំបាំងរបស់ព្រះនាងម៉ារីនិងព្រះយេស៊ូ ដោយចូលនៅក្នុងជីវិតរបស់ព្រះជាម្ចាស់ទាំងអំណរសប្បាយ ពន្លឺ សិរីរុងរឿង និងទុក្ខលំបាក ដែលនាំឱ្យយើងមើលឃើញផ្លូវដើម្បីទទួលស្គាល់ថា ពិតមែនយើងជាបងប្អូនគ្នា និងជាព្រះមហាក្សត្រីយ៍នៃក្រុមគ្រួសារទាំងមូលនៅក្នុងពិភពលោក។ «ព្រះនាងម៉ារីជាម្ចាស់ក្សត្រីនៃសុខសន្តិភាព»។

លោកអភិបាលបន្ថែមថា ទាំងនេះនាំឱ្យយើងយល់ថា គ្មានការណ៍អ្វីដែលព្រះជាម្ចាស់ធ្វើមិនបាននោះទេ និងគម្រោងការនោះកើតមានឡើងលុះត្រាតែយើងទុកចិត្តលើព្រះជាម្ចាស់៕





# លោកអភិបាលៈតំបន់ខាងកើតទន្លេមេគង្គ ជាកន្លែងមរណសាក្សីនិងទីសក្ការៈ





*អត្ថបទ៖ ដាលីស*

គ្រីស្តបរិស័ទជាច្រើនកុះករ បាននាំគ្នាប្រារព្ធខួប៧៦ឆ្នាំនៃមរណភាពរបស់លោកបូជាចារ្យ ទ្រឿង ប៉ូយៀប ក្រោមអធិបតីភាព លោកអូលីវីយេ ជ្មីតហាស្លេអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញ នាថ្ងៃ ១២ មីនា ២០២២ នៅព្រះវិហារព្រះបេះដូងព្រះយេស៊ូ នៃមណ្ឌលសកម្មភាពទន្លេមេគង្គ ស្ថិតក្នុងខេត្តកណ្ដាល។ ក្នុងធម្មទេសនានាឱកាសនេះ លោកអភិបាលអូលីវីយេបានមានប្រសាសន៍ថា ទឹកដីផ្លូវត្រី ជាតំបន់មួយដែលជាប្រវត្តិសាស្ត្ររបស់ព្រះសហគមន៍ ដែលមានគ្រីស្តបរិស័ទពីដើមបានសាបព្រោះនៅលើទឹកដីនេះ ដើម្បីណែនាំឱ្យជីវិតបានរីកចម្រើនពីមួយថ្ងៃទៅមួយថ្ងៃ និងដើម្បីឱ្យព្រះបន្ទូលរបស់ព្រះជាម្ចាស់អាចមានផ្លែដ៏ពិតប្រាកដ។

លោកអភិបាលព្រះសហគមន៍រំឭកថា ព្រះសហគមន៍តំបន់ខាងកើតទន្លេមេគង្គ ជាទឹកដីនៃមរណសាក្សីដែលនៅផ្លូវត្រី មានលោកប៉ូយៀប នៅពោធិ៍ធំជាទឹកដីកំណើតរបស់លោកឆ្មារ សាឡាស់ និងឆ្មារ សាឡឹម។ ជីវិតពួកគាត់គឺជាគ្រាប់ពូជធ្លាក់នៅក្នុងដីដើម្បីឲ្យមានផលផ្លែជាច្រើន។

ក្នុងឱកាសនេះដែរលោកអភិបាលរំឭកនិងផ្ដាំផ្ញើដល់គណៈកម្មការមរណសាក្សីថា «គួរគិតដល់កន្លែងពោធិ៍ធំ សូមឱ្យមានកន្លែងខ្លះដើម្បីនឹករឭកដល់មរណសាក្សីនៅខ្មែរយើង»។

តាមប្រសាសន៍របស់លោកអភិបាលអូលីវីយេបានឲ្យដឹងទៀតថា លោកយៀបបានធ្វើការអស្ចារ្យជាច្រើនសម្រាប់ប្រជាជនមួយចំនួន ទាំងពុទ្ធបរិស័ទ ទាំងគ្រីស្តបរិស័ទ។

លោកអភិបាលបន្ថែមថា ទីសក្ការៈមួយទៀតដែលនៅភាគខាងកើតដែរនោះ គឺព្រះសហគមន៍អរិយក្សត្រ ដែលមានរូបសំណាកព្រះនាងម៉ារីចំនួន២ដែលត្រូវបានរកឃើញប៉ុន្មានឆ្នាំកន្លងមកជាកន្លែងបូជនីយចរដ៏ពិសេសមួយ។

លោកអភិបាលព្រះសហគមន៍ភូមិភាគភ្នំពេញមានប្រសាសន៍ទៀតថា នៅពេលយើងមើលខាងកើតទន្លេមេគង្គ ជាកន្លែងដែលព្រះអាទិត្យរះ កន្លែងដែលយើងនឹករឭកឃើញព្រះយេស៊ូដែលមានព្រះជន្មរស់ឡើងវិញ ដែលជាពន្លឺនៃព្រះអាទិត្យបំភ្លឺពិភពលោក នាំឲ្យយើងមានកម្លាំងដើម្បីរីកចម្រើន។

នៅក្នុងរដូវ៤០ ថ្ងៃនេះ លោកអភិបាលសូមឱ្យគ្រីស្តបរិស័ទទាំងអស់ភ្ជាប់ខ្លួនជាពិសេសជាមួយព្រះជាម្ចាស់ ដើម្បីបានទទួលរង្វាន់នៅស្ថានបរមសុខសម្រាប់មនុស្សជាតិដែលធ្វើតាមព្រះហឫទ័យព្រះជាម្ចាស់ ដូចលោកអាប្រាហាំ ដែលជាមនុស្សសុចរិតនិងអ្នកជឿមុនគេបង្អស់។

ក្នុងឱកាសនោះដែរលោកអភិបាលបានសំណូមពរដល់គ្រីស្តបរិស័ទទាំងអស់ អធិដ្ឋានសម្រាប់សង្គ្រាមនៅអ៊ុយក្រែន ដែលពេលនេះកំពុងតែមានផលលំបាកកាន់តែខ្លាំង ដោយសារប្រទេសអឺរ៉ុប២៧ បានចំណាយប្រាក់របស់ខ្លួន ផ្ដល់ជាសព្វាវុធដល់អ៊ុយក្រែន ដែលទង្វើដែលពិភពលោកព្រួយបារម្ភ។

លោកអភិបាលអូលីវីយេ បានជំរុញឱ្យគ្រីស្តបរិស័ទបន្តយកចិត្តទុកដាក់អធិដ្ឋាន ដោយពោលថា ថ្ងៃនេះយើងមានពេលវេលាដើម្បីអធិដ្ឋានដើម្បីកែប្រែចិត្តគំនិត និងអធិដ្ឋានសម្រាប់អ្នកដឹកនាំប្រទេសកម្ពុជានិងប្រទេសនានាក្នុងពិភពលោក ដើម្បីមានគោលដៅតែមួយគឺការកសាងសន្តិភាព។ កសាងសុខសន្តិភាពកុំឱ្យជាពាក្យដែលចេញត្រឹមតែបបូរមាត់ ប៉ុន្តែឱ្យយើងអនុវត្តជាក់ស្ដែងនៅក្នុងជីវិតរបស់យើង ក្នុងដួងចិត្តរបស់យើងផ្ទាល់៕

## កញ្ញា ម៉ៅ សាវ៉េត ៖ «បើយើងជឿលើព្រះជាម្ចាស់ ព្រះអង្គនឹងរៀបចំផ្លូវសម្រាប់យើងយ៉ាងល្អបំផុត»

*អត្ថបទ៖ ឆាក លាំង*

ម៉ៅ សាវ៉េតវ័យ៣៥ឆ្នាំ ជាស្រីម្នាក់ក្នុងចំណោមបងប្អូនប្រុសស្រីចំនួន៩នាក់ ក្នុងគ្រួសារគ្រីស្តបរិស័ទ រស់នៅក្នុងភូមិកំពង់គោ ខេត្តកំពង់ធំ។

គ្រីស្តបរិស័ទរូបនេះបានប្រាប់ពីទុក្ខលំបាករបស់ខ្លួន ក្នុងការប្រតិបត្តិជំនឿលើព្រះយេស៊ូថា កញ្ញាត្រូវបានគេមើលងាយ គេថាជាមនុស្សម្នាក់មានជំនឿលើសាសនាដទៃ ជាសាសន៍ដទៃជាដើម។ ពេលខ្លះនាងទ្រាំមិនបាន ក៏មានចិត្តចង់តបតដោយកាយវិការឬពាក្យសម្ដីដែលមិនគួរសមត្រឡប់ទៅវិញ។

កញ្ញាបានប្រាប់ថា ៖ «តែសក្ខីភាពរបស់ព្រះយេស៊ូ បានបំភ្លឺឲ្យខ្ញុំ ចេះឆ្លើយតបទៅវិញដោយសកម្មភាព ដែលបង្ហាញពីក្ដីស្រលាញ់ ហើយមិនយូប៉ុន្មាន បងប្អូនទាំងនោះក៏កែប្រែ និងមានទំនាក់ទំនងល្អឡើងវិញ»។

កញ្ញា សាវ៉េតបន្តថា ៖ « ខ្ញុំជឿថាព្រះជាម្ចាស់គង់នៅជាមួយយើងគ្រប់ពេលវេលា តួយ៉ាងក្រុមគ្រួសាររបស់ខ្ញុំធ្លាប់ជួបនឹងការលំបាកខ្លាំង ពេលឪពុកធ្លាក់ពីលើដើមត្នោត ត្រូវព្យាបាលជាង៣ឆ្នាំនៅមន្ទីរពេទ្យ។ ពេលនោះគោក្របី និងទ្រព្យមានតំលៃត្រូវលក់យកមកព្យាបាលឪពុក តែមិនគ្រប់នោះទេ ហើយជំពាក់គេទៀត»។

គ្រីស្តបរិស័ទរូបនេះបានប្រាប់ឱ្យដឹងទៀតថា កញ្ញានិងប្អូនៗត្រូវខិតខំធ្វើការយ៉ាងលំបាកដើម្បីមានបាយហូបមួយពេល។ ពេលយប់ឡើងពួកគេភ័យខ្លាច ខ្វះភាពកក់ក្ដៅពីឪពុកម្ដាយ តែការចូលព្រះវិហារ ស្ដាប់ព្រះបន្ទូលនិងកំលាំងចិត្តដែលមកពីព្រះអង្គ បានជួយក្រុមគ្រួសាររបស់នាងឲ្យបន្តដំណើរទៅមុខ រហូតដល់សព្វថ្ងៃនេះ។

កំពុងតែបំពេញការងារជាអ្នករចនាទំព័រនៅការិយាល័យអប់រំជំនឿសន្តអីរ៉ាណេកម្ពុជា កញ្ញា ម៉ៅ សាវ៉េត តែងតែចូលព្រះវិហាររៀងរាល់ថ្ងៃអាទិត្យ ដើម្បីស្ដាប់ព្រះបន្ទូល អធិដ្ឋាន ដែលកញ្ញាយល់ថាវាជាកិច្ចការមួយ ដែលមានសារៈសំខាន់សំរាប់ជីវិតនាង។

ទោះរវល់នឹងការងារយ៉ាងណាក៏ដោយ ក៏កញ្ញាបានខិតខំធ្វើឲ្យបានរួចរាល់ដើម្បីមានពេលទៅព្រះវិហារ។ គ្រីស្តបរិស័ទរូបនេះគូសបញ្ជាក់ថា ៖ «ដូចជាមានដុំភ្លើងមួយដុំនៅក្នុងខ្លួនរបស់ខ្ញុំ ដែលដុតបញ្ឆេះអារម្មណ៍ និងក្រើនរំលឹកឲ្យទៅព្រះវិហារនៅថ្ងៃអាទិត្យជាដាច់ខាត»។

កញ្ញា សាវ៉េត លើកឡើងទាំងមានជំនឿជឿជាក់ថា ៖ «នៅពេលដែលយើងម្នាក់ៗ ជឿ និងសង្ឃឹមលើព្រះជាម្ចាស់ ដែលមានវត្តមាននៅក្នុងខ្លួនយើងគ្រប់គ្នា យើងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធតាមរយៈកិច្ចការប្រចាំថ្ងៃនោះ យើងផ្ទាល់នឹងដឹងថាព្រះអង្គតែងតែរៀបចំផ្លូវសម្រាប់យើង ទោះពេលបច្ចុប្បន្នធ្លាក់ដល់កំរិតណាក៏ដោយ»។

យ៉ាងណាមិញ ជីវិតរបស់កញ្ញាសាវ៉េតផ្ទាល់មានព្រះជាម្ចាស់តែមួយព្រះអង្គគឺគ្រាប់គ្រាន់ ទាំងសេចក្ដីស្រលាញ់ អំណរសប្បាយ ទុក្ខព្រួយ។ គ្រប់ពេលបំពេញការងារ សកម្មភាពជួបនឹងមនុស្សផ្សេងៗ គឺពោរពេញដោយស្នាមញញឹម និងវត្តមានរបស់ព្រះជាម្ចាស់ផ្ទាល់ តាមរយៈបងប្អូនទាំងនោះ។ នេះជាការលើកឡើងបន្ថែមរបស់កញ្ញា សាវ៉េត។

យុវនារីមួយរូបដែលតែងតែបង្ហាញវត្តមានច្រើន ក្នុងកិច្ចការព្រះសហគមន៍ និងសង្គមខាងក្រៅរូបនេះ បានបង្កើតកម្មវិធីរៃអង្គាសថវិកាជាមួយមិត្តភ័ក្ក ដែលមានជំនឿផ្សេងគ្នានៅសកលវិទ្យាល័យជារៀងរាល់ខែ ហើយយកប្រាក់ទាំងនោះទៅទិញសម្ភារៈសិក្សាសម្រាប់ចែកជូនកូនសិស្សនៅតាមតំបន់ជនបទ និងជនក្រីក្រ។

កញ្ញា សាវ៉េត បានប្រាប់ថា ៖ «យើងមានជំនឿផ្សេងគ្នាក៏ពិតមែន តែយើងមានគោលដៅរួមគ្នា គឺធ្វើការងារដោយក្ដីស្រលាញ់ និងជួយប្អូនៗដែលកំពុងជួបនឹងការលំបាក តាមសមត្ថភាពរៀងៗខ្លួន»។

បច្ចុប្បន្នមិនត្រឹមតែជាអ្នករចនាទំព័រនៅការិយាល័យអប់រំជំនឿទេ តែកញ្ញាសាវ៉េត ក៏បំពេញបេសកកម្មជាអ្នកអប់រំជឿ ដល់បងប្អូនអ្នកស្វែងយល់ពីព្រះយេស៊ូគ្រីស្ត នៅព្រះសហគមន៍សន្តយូសែបផ្សារតូចផងដែរ។ កញ្ញាអះអាងថា ៖ «គិតមកដល់ពេលនេះ ខ្ញុំបានធ្វើជាអ្នកណែនាំជំនឿជិត២០ឆ្នាំហើយ ហើយខ្ញុំក៏មិនមានគំនិតថាឈប់ធ្វើកិច្ចការនេះដែរ ទោះបីហត់នឿយនិងការងារក៏ដោយ ព្រោះថាការចែករំលែកជំនឿទៅបងប្អូនជំនាន់ក្រោយ»។

កញ្ញាថា «គឺនេះជាអំណរសប្បាយមួយ ក្នុងអំណរសប្បាយជាច្រើនទៀតដែលខ្ញុំបានធ្វើឲ្យមនុស្សទូទៅបានស្គាល់ព្រះជាម្ចាស់ ហើយវាជាបេសកកម្មដែលខ្ញុំបានទទួលយក តាំងតែពីថ្ងៃដែលខ្ញុំជ្រមុជទឹកមកម្ល៉េះ»។

ពេលសួរដល់រឿងគូស្រករ កញ្ញា សាវ៉េត ហាក់ជាឆ្លើយដោយមិនប្រាដកប្រជា ថានឹងមានគ្រួសារឬចូលក្នុងក្រុមគ្រួសារអ្នកណាមួយឡើយ ដោយកញ្ញា គ្រាន់តែបញ្ជាក់ថា ពេលចាស់ទៅនឹងប្រឡប់ទៅស្រុកកំណើតវិញដើម្បីមើលថែឪពុកម្ដាយ និងចង់បង្កើតជាកន្លែងតូចមួយដើម្បីជួយអប់រំដល់កូនក្មេង និងមនុស្សទូទៅដែលចង់ស្គាល់ព្រះជាម្ចាស់ ហើយបន្តធ្វើការងារអ្នកអប់រំជំនឿបន្តទៅមុខរហូត៕

# រដ្ឋាភិបាលឥណ្ឌា ចុះអនុស្សរណៈយោគយល់ជាមួយអង្គការការីតាសកម្ពុជា

*អត្ថបទ៖ កែវ កញ្ញា*

រដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា និងអង្គការការីតាសកម្ពុជា បានចុះអនុស្សរណៈយោគយល់គ្នា សម្រាប់កុមារកំព្រា កុមារងាយរងគ្រោះ តាមរយៈសេវាគ្លីនិកចល័តនៅកម្ពុជា នៅឯមន្ទីរពេទ្យជ័យជំនះ ខេត្តកណ្តាល កាលពីថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២២ ។

កម្មវិធីចុះអនុស្សរណៈនេះ ធ្វើឡើងដោយមានលោក គីម រតនា នាយកប្រតិបត្តិនៃអង្គការការីតាសកម្ពុជា និងលោកជំទាវបណ្ឌិត ឌីវីយ៉ានី ខប្រាហ្គេដ (Dr. Devyani Khobragade) ឯកអគ្គរាជទូតនៃសាធារណរដ្ឋឥណ្ឌាប្រចាំនៅកម្ពុជា និងមានតំណាងពីក្រសួងសុខាភិបាល និងមន្ត្រីខេត្តកណ្តាលចូលរួមផងដែរ។

ថ្លែងក្នុងឱកាសនោះ លោក គីម រតនា បានថ្លែងអំណរគុណចំពោះរដ្ឋាភិបាលឥណ្ឌា ដែលបានផ្តល់ជំនួយសម្រាប់គម្រោងនេះ ដែលផ្តល់អត្ថប្រយោជន៍ដល់កុមារកំព្រា កុមារងាយរងគ្រោះ កុមារមានពិការភាពផ្លូវចិត្ត និងកុមារដែលគេបោះបង់ចោល។ លោករតនា បានថ្លែងអំណរគុណជាពិសេសចំពោះលោកជំទាវឯកអគ្គរដ្ឋទូតសម្រាប់ការគាំទ្រ និងកិច្ចសហប្រតិបត្តិការជាបន្តបន្ទាប់របស់លោកជំទាវ ដែលបានបន្តដល់ មជ្ឈមណ្ឌលផ្លូវចិត្តកុមារ និងយុវជន(CCAMH) នៃអង្គការការីតាសកម្ពុជា ក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ។

> ការកសាងសមត្ថភាពអ្នកថែទាំ និងអ្នកជំនាញដើម្បីផ្តល់សិទ្ធិអំណាចដល់កុមារ និងក្មេងជំទង់ដែលមានពិការភាពច្រើន និងគ្រួសាររបស់ពួកគេ





នៅក្នុងសុន្ទរកថាស្វាគមន៍របស់លោកវេជ្ជបណ្ឌិត ប៊ូមីកុមារ ជេហ្គាន់ណាថាន់ (Bhoomikumar JEGANNATHAN) អ្នកទទួលខុសត្រូវ CCAMH បានគូសបញ្ជាក់ពីភាពពាក់ព័ន្ធតាមបរិបទនៃគម្រោងនេះ ដោយសារវាមានគោលបំណងដើម្បីទៅដល់កុមារដែលមានពិការភាពផ្នែកប្រព័ន្ធប្រសាទ និងផ្លូវចិត្តផ្សេងទៀតដែលមិនអាចទទួលបានសេវាថែទាំសុខភាពដោយសារជំងឺរាតត្បាតកូវីដ-១៩ ។

លោកជំទាវ បណ្ឌិត ឌីវីយ៉ានី ខប្រាហ្គេដ បានកោតសរសើរចំពោះតួនាទីរបស់លោកវេជ្ជបណ្ឌិត ប៊ូមីកុមារ ក្នុងការអភិវឌ្ឍន៍សេវាសុខភាពផ្លូវចិត្តកុមារនៅកម្ពុជា ដោយមានការគាំទ្រពីរដ្ឋាភិបាលនៃប្រទេសឥណ្ឌា។ លោកជំទាវបានសង្កត់ធ្ងន់លើផលប៉ះពាល់ជាវិជ្ជមាននៃគម្រោង ផលប៉ះពាល់រហ័ស (QIP) ឆ្ពោះទៅរកការពង្រឹងទំនាក់ទំនងទ្វេភាគីរួម និងសុច្ឆន្ទៈរវាងប្រជាជនឥណ្ឌា និងកម្ពុជា។

អ្នកស្រី សុខ ឌៀវ៉ូហ្សេត ប្រធានកម្មវិធីសហគមន៍នៃមជ្ឈមណ្ឌលផ្លូវចិត្តកុមារនិងយុវជនមានប្រសាសន៍ថា ជាមួយនឹងគម្រោងដែលបានចុះហត្ថលេខាថ្មីៗនេះ គឺរដ្ឋាភិបាលឥណ្ឌាបានផ្តល់នូវរថយន្តចល័ត១គ្រឿង និងវគ្គបណ្តុះបណ្តាលបុគ្គលិកនៃCCAMH នៅប្រទេសឥណ្ឌា។

អ្នកស្រី ឌៀវ៉ូហ្សេត បានប្រាប់វិទ្យុវេរីតាស់អាស៊ីនៅថ្ងៃ២១ ខែមីនានេះថា ជំនួយរថយន្តចល័ត នឹងជួយសម្រួលដល់កិច្ចការងារដឹកជញ្ជូនគ្រួសារកុមារមានពិការភាព ដែលត្រូវមកបើកថ្នាំរាល់ខែនៅតាខ្មៅ (CCAMH) និងសម្រួលដល់បុគ្គលិកCCAMH ដែលផ្តល់សេវាប្រឹក្សាតាមផ្ទះ។ អ្នកស្រីបញ្ជាក់ថា «ជាទូទៅ បុគ្គលិករបស់យើងប្រើម៉ូតូផ្ទាល់ខ្លួនដើម្បីធ្វើដំណើរទៅភូមិ ដូច្នេះ រថយន្តចល័តជួយសម្រួលម្យ៉ាង។ យើងអាចដឹកគាត់និងសម្រួលការងារចុះទៅភូមិ ដឹកឥវ៉ាន់ទៅតាមភូមិជាដើម»

អ្នកស្រីប្រធានកម្មវិធីសហគមន៍រូបនេះបន្ថែមថា កម្មវិធីរបស់មជ្ឈមណ្ឌលបច្ចុប្បន្នបានជួយដល់គ្រួសារចំនួន៦០ ដែលមានកូនជាកុមារពិការសតិបញ្ញា និងផ្លូវចិត្ត ដែលធ្វើឡើងក្នុងភូមិចំនួន១៨ ស្ថិតនៅក្នុងស្រុកចម្ការលើនៃខេត្តត្បូងឃ្មុំ និងស្រុកឱរាំងឪនៃខេត្តកំពង់ចាម។ អ្នកស្រីបន្តថា «ភាគច្រើន យើងជួបក្មេងពិការបញ្ញា ទន់ដៃជើងប្រកាច់» ហើយគ្រួសាររបស់ពួកគាត់ជាកសិករ អ្នកចម្ការ អ្នកនេសាទក្រីក្រជាដើម។

អ្នកស្រីឌៀវ៉ូហ្សេតបញ្ជាក់ថា ដោយស្ថានភាពគ្រួសារក្រីក្របែបនេះ ជារៀងរាល់ខែខាងមជ្ឈមណ្ឌលផ្តល់ជាសោហ៊ុយដល់គ្រួសាររបស់កុមារទាំងនោះ នាំកូនៗរបស់ពួកគាត់មកពិនិត្យសុខភាពនិងទទួលថ្នាំព្យាបាល នៅមជ្ឈមណ្ឌលផ្លូវចិត្តកុមារនាក្រុងតាខ្មៅខេត្តកណ្តាល។

អ្នកស្រីឌៀវ៉ូហ្សេត ឲ្យដឹងទៀតថា កម្មវិធីចុះទៅតាមភូមិ គឺបុគ្គលិកអង្គការចុះស្វែងរក និងពិនិត្យសុខភាពដល់កុមារ ប្រសិនបើរកឃើញថាពួកគាត់មានតម្រូវការផ្សេង ឬមានជំងឺត្រូវព្យាបាលផ្សេង អង្គការនឹងបញ្ជូនពួកគាត់ទៅកាន់អង្គការដៃគូបន្តទៀត។ ក្នុងករណីរកឃើញកុមារមានពិការភាពខាងបញ្ញា យើងប្រឹក្សាជាមួយក្រុមគ្រួសារ បង្រៀនឪពុកម្តាយ បង្ហាត់ពួកគាត់ដោយផ្ទាល់។

អ្នកស្រីបន្ថែមថា ក្នុងមួយខែក្រុមការងារចុះទៅម្តង ហើយយើងក៏មានចងក្រងឪពុកម្តាយជាក្រុម និងមានអ្នកស្ម័គ្រចិត្តភូមិចំនួន២នាក់ក្នុងមួយភូមិ ដែលសរុបទៅយើងមាន៣៦នាក់ក្នុង១៨ភូមិ។

អ្នកស្រីបញ្ជាក់ថា ជាមួយនឹងគម្រោងជួយដល់កុមារដែលមានពិការភាពផ្នែកសតិបញ្ញានេះ ខាងរដ្ឋាភិបាលនៃសាធារណរដ្ឋឥណ្ឌា បានជួយគាំទ្រតាំងពីឆ្នាំ២០១៩ លើផ្នែកបណ្តុះបណ្តាលធនធានមនុស្សក្នុងប្រទេសនិងក្រៅប្រទេសពីវិទ្យាស្ថានជាតិសម្រាប់ពង្រឹងសមត្ថភាពសិទ្ធិអំណាចដល់ជនមានពិការភាពចំរុះ (National Institute for Empowerment of Persons with Multiple Disabilities-NIEPMD) នៅប្រទេសឥណ្ឌា និងជំនួយដល់ការបោះពុម្ពលើឯកសារទាក់ទងនឹងគម្រោងកុមារមានពិការភាព ដូចជា សៀវភៅ ខិតបណ្ណផ្សព្វផ្សាយជាដើម។

តាមរយៈសេចក្តីប្រកាសព័ត៌មានរបស់ស្ថានទូតឥណ្ឌាប្រចាំនៅកម្ពុជា ចេញផ្សាយនៅថ្ងៃទី១៨ ខែមីនា បានឲ្យដឹងថា ក្រោមគម្រោង ផលប៉ះពាល់រហ័ស (QIP) ស្ថានទូតឥណ្ឌាបានអនុវត្តគម្រោងផ្សេងទៀតក្នុងភាពជាដៃគូជាមួយអង្គការការីតាសកម្ពុជា ស្តីអំពី «ការកសាងសមត្ថភាពអ្នកថែទាំ និងអ្នកជំនាញដើម្បីផ្តល់សិទ្ធិអំណាចដល់កុមារ និងក្មេងជំទង់ដែលមានពិការភាពច្រើន និងគ្រួសាររបស់ពួកគេ» ដែលស្ថិតក្រោមដំណាក់កាលចុងបញ្ចប់ ដែលផ្តល់អត្ថប្រយោជន៍ដល់កុមារ និងគ្រួសាររបស់ពួកគេប្រហែល ១៣០០ នាក់។

ក្រោមគម្រោង QIP រដ្ឋាភិបាលឥណ្ឌាអនុវត្តគម្រោងចំនួន ១០ ជារៀងរាល់ឆ្នាំក្នុងប្រទេសកម្ពុជា ដោយផ្តល់មូលនិធិរហូតដល់ ៥០០០០ ដុល្លារអាមេរិកក្នុងមួយគម្រោង។ ចាប់តាំងពីឆ្នាំ ២០១៥-១៦ រដ្ឋាភិបាលនៃប្រទេសឥណ្ឌាបានអនុម័តគម្រោងចំនួន ៤៦ ក្នុងវិស័យព័ត៌មានវិទ្យា កសិកម្ម សុខភាព អនាម័យ ការផ្តល់សិទ្ធិអំណាចដល់ស្ត្រី សុខុមាលភាពកុមារ ការអភិវឌ្ឍជនបទ ហេដ្ឋារចនាសម្ព័ន្ធសង្គម (រួមទាំងការកសាងសមត្ថភាព) បរិស្ថាន។ល៕





# ព្រះសហគមន៍កាតូលិកកម្ពុជា មានបេក្ខជនជិត ២០០នាក់ ត្រៀមទទួលអគ្គសញ្ញាជ្រមុជទឹក

*អត្ថបទ៖ កែវ កញ្ញា*

នៅក្នុងរាត្រីបុណ្យចម្លងក្នុងឆ្នាំ២០២២នេះ ព្រះសហគមន៍កាតូលិកទាំងបីភូមិភាគមានមនុស្សពេញវ័យចំនួន១៩១នាក់ ដែលត្រៀមខ្លួនដើម្បីទទួលអគ្គសញ្ញាជ្រមុជទឹក ដែលក្នុងនោះមាននៅភូមិភាគភ្នំពេញចំនួន៩៥នាក់ ភូមិភាគបាត់ដំបង ចំនួន៤៧នាក់ និងភូមិភាគកំពង់ចាមចំនួន ៤៩នាក់។

ក្នុងសំលៀកបំពាក់អាវស សំពត់បត់ និងមានពានាស្បៃពណ៌ស្វាយ ជាពណ៌តំណាងឲ្យរដូវអប់រំពិសេស ដែលមានរយៈពេល៤០ថ្ងៃ បេក្ខជនដែលត្រៀមខ្លួន ដែលបានទទួលការត្រាស់ហៅពីលោកអភិបាលរួច ត្រូវបង្ហាញខ្លួនក្នុងខោអាវបែបនេះ នៅក្នុងព្រះវិហារជាប្រចាំរហូតដល់ថ្ងៃទទួលពិធីជ្រមុជទឹក។

ស្ត្រីឈ្មោះណន ធារី អាយុ៣៣ឆ្នាំ ជាបេក្ខជនជំហានទី២ មកពីព្រះសហគមន៍រោងចក្រក្នុងភូមិភាគភ្នំពេញ បានឲ្យដឹងថា នាងបានសិក្សាវគ្គអប់រំជំនឿជាងមួយឆ្នាំមកហើយ។ «ខ្ញុំគិតថានេះជាការត្រាស់ហៅរបស់ព្រះអង្គ។»

ជារៀងរាល់ថ្ងៃ ធារីបានស្តាប់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ បានធ្វើឲ្យអារម្មណ៍របស់នាងស្រស់ថ្លា ហើយបានធ្វើឲ្យនាងភ្ជាប់ចិត្តគំនិតជាមួយព្រះជាម្ចាស់។ «ខ្ញុំគិតថា ទ្រង់ស្រឡាញ់ខ្ញុំ ហើយខ្ញុំនឹងព្យាយាមស្រឡាញ់និងឈ្វេងយល់ពីទ្រង់ដូចគ្នា។» ណន ធារីបន្ថែម។

ធារីបានឲ្យដឹងទៀតថា ជីវិតរបស់នាងបានផ្លាស់ប្តូរ ដោយរស់នៅមានអធ្យាស្រ័យច្រើនជាងមុន និងមានជីវិតរីករាយច្រើនជាងមុន។ ស្ត្រីរូបនេះ បន្តថា ការប្តូរជំនឿមកកាន់សាសនាគ្រីស្តគ្មាននរណាជំទាស់នោះឡើយ។ ធារីបញ្ជាក់ «ឲ្យតែខ្ញុំសប្បាយចិត្ត ហើយព្រះអង្គស្រឡាញ់ខ្ញុំ អ្នកជុំវិញខ្លួន ជាពិសេសឪពុកម្តាយ បងប្អូនគាំទ្រខ្ញុំជានិច្ច។»



*(រូបភាពឯកសារ) ពិធីទទួលអគ្គសញ្ញាជ្រមុជទឹកនៅភូមិភាគភ្នំពេញ ៖ រូបភាព ព្រះសហគមន៍ភូមិភាគភ្នំពេញ*

ស៊ន់ ណារី អាយុ១៨ឆ្នាំ កំពុងរៀនថ្នាក់ទី ១១ នៅរាជធានីភ្នំពេញ និងជាបេក្ខជនត្រៀមទទួលអគ្គសញ្ញាជ្រមុជទឹក បានឲ្យដឹងថា ជីវិតនាងជាទូទៅមិនសូវប្រាស្រ័យទាក់ទងជាមួយអ្នកដទៃ ព្រោះនាងជាមនុស្សខ្លាចគេ។ ក្រោយពេលស្គាល់ព្រះសហគមន៍ នាងចាប់ផ្តើមស្គាល់មនុស្សជាច្រើន។ «ពេលខ្ញុំនៅក្នុងព្រះសហគមន៍ ហ៊ាននិយាយច្រើន។ មកទាក់ទងជាមួយគេទៅ គឺសប្បាយច្រើន ជាងនៅតែឯង។»

ចំពោះណារី ជំនឿលើព្រះយេស៊ូ បានឲ្យនាងមានភាពក្លាហានជាងមុន ហើយអាចយល់អំពីរបៀបប្រាស្រ័យទាក់ទងមនុស្សពេលបច្ចុប្បន្នបានច្រើន។

យុវតីរូបនេះ បានឲ្យដឹងថា ការផ្លាស់ប្តូរជំនឿរបស់ខ្លួន គឺធ្វើឡើងតាមរយៈអ៊ំរបស់គាត់ដែលជាគ្រីស្តបរិស័ទកាតូលិក។ «ខ្ញុំស្គាល់ព្រះសហគមន៍យូរហើយ តែខ្ញុំទើបតែចូលរៀនបានបីឆ្នាំ។»

ណារីបញ្ជាក់ថា ឪពុកម្តាយរបស់គាត់មិនបានហាមឃាត់ឡើយ នៅពេលដែលគាត់ប្រាប់ថា គាត់ផ្លាស់ប្តូរសាសនា។ ប៉ុន្តែជំនឿមួយនេះបានធ្វើឲ្យមនុស្សនៅក្បែរនាងមួយចំនួនឆ្ងល់អំពីទង្វើមួយចំនួន។ ណារីបន្តថា «នៅពេលទៅរៀនមុនប្រឡង ឬញ៉ាំបាយ ខ្ញុំតែងតែអធិដ្ឋាន ហើយគេតែងមើលមកខ្ញុំ ហើយសួរខ្ញុំ ម៉េចបានជឿលើព្រះជាម្ចាស់? ពេលគេសួរសំណួរខ្លះ ខ្ញុំមិនអាចឆ្លើយបាន តែពេលខ្ញុំរៀន(អប់រំជំនឿ) ខ្ញុំអាចឆ្លើយបាន។»

ក្រោយពេលទទួលពិធីជ្រមុជទឹករួច ណារីចង់ក្លាយជាអ្នកអប់រំបន្តជំនឿដល់អ្នកឈ្វេងយល់ ដើម្បីឲ្យគេបានស្គាល់និងមានអំណរសប្បាយដូចជារូបនាងដែរ។

យុវតីហេង លីដា អាយុ១៧ឆ្នាំ កំពុងធ្វើការងារនៅទីក្រុងភ្នំពេញ ហើយជារៀងរាល់អាទិត្យគាត់ត្រូវចំណាយពេលវេលាដោយជិះម៉ូតូ រយៈពេល ២ម៉ោង ទើបទៅដល់ព្រះវិហារគ្រួសារដ៏វិសុទ្ធនៅអ្នកលឿង ក្នុងភូមិភាគកំពង់ចាម។

លីដា បានឲ្យដឹងទៀតថា នាងបានធ្វើបែបនេះ ជិត១ឆ្នាំមកហើយ តាំងពីនាងបានការងារធ្វើនៅទីក្រុងភ្នំពេញ។ លីដា មានម្តាយជាគ្រីស្តបរិស័ទនិងឪពុកជាពុទ្ធបរិស័ទ បានឲ្យដឹងថា «ខ្ញុំមានអារម្មណ៍ក្តុកក្តួលនៅពេលឃើញគេទៅព្រះវិហារនៅក្នុងពិធីបុណ្យធំៗ។ ពេលខ្ញុំទៅ ខ្ញុំមានអារម្មណ៍ថា សប្បាយខ្លាំងមែនទែន អត់ដឹងនិយាយយ៉ាងណា។»

លីដា ឲ្យដឹងទៀតថា ទោះបីជានាងមិនទាន់ក្លាយជាគ្រីស្តបរិស័ទ ប៉ុន្តែកាយវិការរបស់នាងបានបង្ហាញឲ្យអ្នកនៅជុំវិញខ្លួនបានដឹងថា នាងជាគ្រីស្តបរិស័ទ។ ហើយទោះបីជាពេលខ្លះនាងមិនទទួលបានជោគជ័យក្នុងជីវិតក៏ដោយ ក៏នាងអាចទៅមុខបាន។ លីដាបញ្ជាក់ថា «ក្នុងជីវិតជាគ្រីស្តបរិស័ទ មិន(មែន)ថារឿងទាំងអស់យើងទទួលបានជោគជ័យទេ តែវាហាក់ដូចជាផ្តល់កំលាំងចិត្តជាងមុន។»

បេក្ខជនទាំងបីរូបខាងលើនេះ នឹងទទួលអគ្គសញ្ញាជ្រមុជទឹកក្នុងរាត្រីបុណ្យចម្លងខាងមុខនេះ នៅតាមព្រះសហគមន៍រៀងៗខ្លួន ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ២០២២នេះ។

លោកអភិបាលអូលីវីយ៉េ ឆ្មឹតហស្លេ អភិបាលនៃព្រះសហគមន៍ភូមិភាគភ្នំពេញមានប្រសាសន៍ថា បេក្ខជនមួយចំនួន «គេបានធ្វើដំណើរជាមួយព្រះសហគមន៍២-៣-៤-៥ រហូតដល់១០ឆ្នាំ មុនគេសម្រេចចិត្តថា ឥឡូវនេះ គេដើរតាមព្រះយេស៊ូបាន អស់មួយជីវិត។» លោកអភិបាលបន្តថា ក្នុងរយៈពេលនៃរដូវអប់រំពិសេសនេះ អ្នកដែលត្រៀមខ្លួនទទួលជ្រមុជទឹក គឺត្រូវឲ្យគេយកចិត្តទុកដាក់អធិដ្ឋាន ចូលព្រះវិហារដើម្បីទទួលការអប់រំថែមទៀត និងមានចិត្តគំនិតច្បាស់លាស់ដើម្បីទទួលពិធីបុណ្យជ្រមុជទឹកនៅរាត្រីបុណ្យចម្លង។

«ហើយបន្ទាប់មកត្រូវឲ្យគេក្លាយជាគ្រីស្តបរិស័ទសកម្ម មិនមែនជាគ្រីស្តបរិស័ទដែលចូលវិហារយូរៗម្តង ពេលបុណ្យធំ ផ្ទុយទៅវិញ យើងគឺជាថ្ម ដ៏មានជីវិត។ ដូច្នេះ ខ្ញុំជម្រុញឲ្យបេក្ខជនថ្ងៃនេះ ផ្តល់សក្ខីភាពអំពីជំនឿអំពីព្រះយេស៊ូទៅដល់ប្រជាជនទាំងអស់នៅលើទឹកដីកម្ពុជា។

លោកដួង សាវង់ ប្រធានការិយាល័យអប់រំជំនឿភូមិភាគភ្នំពេញ មានប្រសាសន៍ថា សម្រាប់មនុស្សពេញវ័យដែលចង់ប្តូរជំនឿមកជាកាតូលិក បេក្ខជនត្រូវរៀន និងត្រៀមខ្លួនរយៈពេលជិត២ឆ្នាំ ដោយមានដំណាក់កាលមួយចំនួន។

លោកប្រធានរូបនេះ បន្តថា «ក្នុងគរុកោសល្យរបស់ព្រះសហគមន៍កាតូលិក មុនដំបូង យើងហៅពួកគាត់ថា ជាក្រុមឈ្វេងយល់។ យើងមានអត្ថបទគម្ពីរសមស្របជាមួយពួកគេ។ នេះ យើងប្រើរយៈពេលមួយឆ្នាំ។»

លោកសាវង់ បន្ថែមថា ក្រោយមកឃើញថាគេមានជំនឿហើយ ព្រះសហគមន៍ធ្វើពិធីឲ្យគេចូលព្រះសហគមន៍ ដែលយើងហៅថាជំហានទី១។ ហើយគេត្រូវរៀនអប់រំបន្តទៀត ដោយត្រូវស្គាល់អំពីប្រវត្តិនៃគម្ពីរសម្ពន្ធមេត្រីចាស់ ស្គាល់ព្រះយេស៊ូកាន់ច្បាស់ និងស្គាល់ប្រពៃណីព្រះសហគមន៍ និងពិធីបុណ្យផ្សេងៗ។ ក្រោយមកបើឃើញគេមានជំនឿច្រើនហើយ ព្រះសហគមន៍ឃើញថា គេអាចទៅជាគ្រីស្តបរិស័ទបាន អ៊ីចឹងនៅក្នុងអាទិត្យទី១ក្នុងរដូវអប់រំពិសេស អ្នកអប់រំជំនឿនិងគណៈកម្មការអប់រំជំនឿព្រមព្រៀងគ្នាជ្រើសរើសបេក្ខជន ហើយស្នើសុំទៅលោកអភិបាលដើម្បីធ្វើពិធីត្រាស់ហៅដល់បេក្ខជនដើម្បីទទួលអគ្គសញ្ញាជ្រមុជទឹក។

លោកបន្ថែមថា នៅក្នុងរដូវអប់រំពិសេសដែលបេក្ខជនត្រៀមទទួលពិធីជ្រមុជទឹក ព្រះសហគមន៍មានពិធីជម្រះចិត្តចំនួន៣ដងសម្រាប់ពួកគាត់ទៅតាមអត្ថបទគម្ពីរនៅក្នុងអាទិត្យនីមួយៗ រហូតដល់រាត្រីបុណ្យចម្លងទើបគេអាចទទួលអគ្គសញ្ញាជ្រមុជទឹកបាន។

នៅក្នុងរាត្រីនោះ បេក្ខជនទទួលអគ្គសញ្ញាចំនួន៣គឺ ជ្រមុជទឹក អរព្រះគុណ(ទទួលព្រះកាយ) និងលាបថ្វាស។ «ប៉ុន្តែព្រះសហគមន៍ភូមិភាគភ្នំពេញ ទុកអគ្គសញ្ញាលាបថ្វាសពេលក្រោយ នៅថ្ងៃបុណ្យព្រះវិញ្ញាណយាងមក លោកអភិបាលនឹងធ្វើសម្រាប់បងប្អូនបន្តទៀត។» លោកសាវង់បញ្ជាក់។

ជាទូទៅបុណ្យព្រះវិញ្ញាណយាងមក គឺក្រោយបុណ្យចម្លងរយៈពេល៥០ថ្ងៃ។ លោកបន្តថា «អ៊ីចឹងដើម្បីទៅជាគ្រីស្តបរិស័ទ គេត្រូវទទួលអគ្គសញ្ញាចំនួន៣នោះ។»

ទោះបីជាក្លាយជាគ្រីស្តបរិស័ទហើយ ប៉ុន្តែព្រះសហគមន៍ឃើញថា ជីវិតរបស់គេមានជាប់អំពើបាប ដូច្នេះ ព្រះសហគមន៍ឲ្យរៀនបន្ថែមទៀតអំពីអគ្គសញ្ញាលើកលែងទោស។ ហើយក្រោយៗមកទៀតគេអាចទទួលអគ្គសញ្ញាផ្សេងៗ ដូចជាអគ្គសញ្ញាអាពាហ៍ពិពាហ៍ ឬតែងតាំងជាដើម។

ជ្រមុជទឹករួច ពួកគាត់អាចបន្តចូលរួម និងបម្រើព្រះសហគមន៍តាមរយៈគណៈកម្មការចំនួនបី គឺសង្គហៈ ពិធីបុណ្យ និងអប់រំជំនឿ។ លោកដួង សាវង់បន្ថែមថា «គ្រីស្តបរិស័ទខ្លះក្រោយជ្រមុជទឹកហើយ គាត់មានអំណោយទានចូល

អានបន្តទំព័រ-១៩

# ការិយាល័យយុវជន ជំទង់ និងកុមារភូមិភាគភ្នំពេញរៀបចំ អធិដ្ឋានតេហ្សេសម្រាប់សន្តិភាពនៅប្រទេសអ៊ុយក្រែន

*អត្ថបទ៖ .....*

តាមរយៈសាររបស់សម្ដេចប៉ាប បានស្នើឲ្យគ្រីស្តបរិស័ទ្ធនៅទូទាំងពិភពលោក យកថ្ងៃទី០២ ខែមីនា ជា ថ្ងៃបុណ្យរោយផេះ ដើម្បីរួមគ្នាអធិដ្ឋានដើម្បីសន្តិភាពសម្រាប់ប្រទេសអ៊ុយក្រែន។ ក្នុងនោះការិយាល័យយុវជន ជំទង់ និងកុមាតូចក៏បានរៀបចំអធិដ្ឋានតេហ្សេ ដោយបានអញ្ជើញបងប្អូនគ្រីស្តបរិស័ទ្ធប្រមាណ៣០នាក់មកចូលរួមនៅព្រះវិហារសន្តប៉ូល និងសន្តសិលា ភ្នំពេញថ្មី។



លោក ស៊ាន់ សារឿន ជាអ្នកទទួលខុសត្រូវការិយាល័យយុវជន ជំទង់ និងកុមារ បានឱ្យដឹងថា ដោយសារតែក្នុងប្រទេសអ៊ុយក្រែននិងប្រទេសរុស្ស៊ី កំពុងតែមានសង្គ្រាម ជាពិសេសនៅប្រទេសអ៊ុយក្រែនមានប្រជាជនជាច្រើនដែលត្រូវជំលៀសប្រជាជនជាច្រើនដែលបានបាត់បង់ផ្ទះសំបែង និងជាប្រទេសដែររងគ្រោះដោយសារការឆ្លានពានពីប្រទេសរុស្ស៊ី។

លោកបានបន្តថា ៖ «ការរៀបចំអធិដ្ឋានតេហ្សេនេះគឺដើម្បីឲ្យបញ្ឈប់សង្គ្រាម និងឲ្យអ្នកដឹកនាំរកវិធីសាស្ត្រដើម្បីផ្សះផ្សារដោះស្រាយ ចរចារ តាមរយៈការសុំទូលអង្វររបស់យើងទៅព្រះជាម្ចាស់»។ លោក សាន់ សារឿន ឲ្យដឹងទៀតថា ៖ «យើងជាគ្រីស្តបរិស័ទ្ធដែលមានជំនឿលើព្រះជាម្ចាស់គឺយើងចង់បានសុខសន្តិភាព សេចក្ដីសុខ សេរីភាពក្នុងការរស់នៅ ដូច្នេះអ្វីដែលប្រទេសរុស្ស៊ីកំពុងតែធ្វើទៅលើប្រទេសអ៊ុយក្រែនវាមិនស្របតាមព្រះសហឬទ័យនៃសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់»។

លោក សារឿន បានបញ្ជាក់ថា លោកសង្ឃឹមថានឹងមានសន្តិភាពនិងបញ្ឈប់សង្គ្រាមជាបន្ទាន់នៅប្រទេសអ៊ុយក្រែនតាមរយៈការអធិដ្ឋានថ្ងៃទី២ មីនានេះ។

លោក សាន់ សារឿន គ្រោងនឹងធ្វើការអធិដ្ឋានទូលសុំអង្វរព្រះជាម្ចាស់ ជារៀងរាល់សប្តាហ៍សម្រាប់សុខសន្តិភាពនៅប្រទេសអ៊ុយក្រែនដរាបណាសង្គ្រាមនៅតែមិនទាន់បញ្ចប់។ លោកថា ការអធិដ្ឋាននេះបញ្ជាក់ពីការចូលរួមចំណែក រួបរួមគ្នាសុំសន្តិភាព និងបញ្ឈប់សង្គ្រាម ហើយបងប្អូនជាគ្រីស្តបរិស័ទក៏អាចធ្វើការអធិដ្ឋានផ្ទាល់ខ្លួនឬតាមព្រះសហគមន៍របស់ខ្លួនបានដែរ ដើម្បីឲ្យប្រជាជនអ៊ុយក្រែនបានវិលមកស្រុកកំណើត ដើម្បីបានប្រកបមុខរបររកស៊ីវិញ និងមានឯករាជ្យភាពឡើងវិញ។

អ្នកទទួលខុសត្រូវការិយាល័យយុវជន ជំទង់ និងកុមាររូបនេះ ក៏បានផ្ដាំផ្ញើទៅកាន់យុវជនយុវនារី និងគ្រីស្តបរិស័ទទាំងអស់ថា ទោះបីសង្គ្រាមនេះមិនស្ថិតនៅក្នុងប្រទេសនេះក៏ដោយ តែលោកមានជំនឿថា សេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់ ទុក្ខលំបាករបស់ប្រជាជនអ៊ុយក្រែន ទុក្ខលំបាករបស់ពិភពលោកក៏ដូចជាទុក្ខលំបាកនៅក្នុងព្រះសហគមន៍នៃប្រទេសកម្ពុជា គួរតែរួមរួមគ្នាដើម្បីអធិដ្ឋានដើម្បីទូលអង្វរដើម្បីស្វះស្វែងរកគ្រប់វិធីគ្រប់មធ្យោបាយ ទោះមិនអាចទៅជួបផ្ទាល់ឬផ្តល់ថវិការ ប៉ុន្តែកំលាំងខាងផ្លូវវិញ្ញាណ គឺជាការគាំទ្រមួយក៏ជាអ្វីមួយយ៉ាងសំខាន់។

លោក សារឿន បានបន្ថែមថា ៖ «ការអធិដ្ឋានបែបនេះបង្ហាញពីការរួបរួម ពីសាមគ្គីភាពដល់ប្រទេសអ៊ុយក្រែនដើម្បីឲ្យមានសន្តិភាពនិងដើម្បីឲ្យយុវជនរបស់យើងចាប់អារម្មណ៍អាចបង្កើតកម្មវិធីណាមួយបង្ហាញពីការចូលរួមតាមរយៈការអធិដ្ឋានផ្ទាល់ខ្លួន តាមរយៈការចែកចាយលើហ្វេសប៊ុក ដែលយើងគិតថាវាមានប្រយោជន៍និងបង្ហាញថាយើងចូលរួមចំណែក ដោយសេចក្តីស្រឡាញ់ ស្រឡាញ់សន្តិភាព យុត្តិធម៌ឡើងវិញនៅក្នុងប្រទេសអ៊ុយក្រែន ជាពិសេសប្រទេសរុស្ស៊ីដែរ ឲ្យមេដឹកនាំទាំងពីរវិលមករកតុចរចារ និងដកទ័ពចេញពីប្រទេសអ៊ុយក្រែន»។

# លោក ផាន់ ប៉ូរ៉ា ៖ «ពេលខ្ញុំឃើញបងប្អូនក្រីក្រវេទនា ខ្ញុំតែងតែឃើញព្រះភក្ត្រព្រះយេស៊ូនៅក្នុងពួកគាត់ម្នាក់ៗ»

*អត្ថបទ៖ ហៀម សុកខុន*

នេះជាការថ្លែងឡើងយ៉ាងច្បាស់ៗពីគ្រីស្តបរិស័ទមួយរូបនៅព្រះសហគមន៍កោះរកា គឺលោក ផាន់ ប៉ូរ៉ា ដែលលោកក៏ជាក្រុមប្រឹក្សាជាន់ខ្ពស់របស់សមាគមសប្បុរសធម៌សន្តវិនសេនដឺប៉ូលកម្ពុជានិងជាបុគ្គលម្នាក់ដែលតែងតែស្វែងរកជំនួយដោយធម្យោបាយផ្សេងៗរួមទាំងយកថវិការផ្ទាល់ខ្លួនព្រមទាំងប្រើកំលាំងកាយចិត្តជួយបងប្អូនក្រីក្រដែលត្រូវការជំនួយ។

លោក ផាន់ ប៉ូរ៉ា ចូលចិត្តចែករំលែកទៅកាន់បងប្អូនក្រីក្រ ព្រោះលោកយល់ថា នេះជាអត្តសញ្ញាណរបស់គ្រីស្តបរិស័ទ។ លោកថា ៖ «បើជាគ្រីស្តបរិស័ទត្រឹមតែទៅព្រះវិហារ ទៅអធិដ្ឋាន ទៅអភិបូជាសុំឲ្យអ្នកក្រីក្របានសេចក្តីសុខសាន្ត មានអ្នកផ្សេងគេជួយ នោះវាមិនគ្រប់គ្រាន់ឡើយ»។

លោក ផាន់ ប៉ូរ៉ា បានឲ្យដឹងទៀតថា នៅពេលលោកជួយអ្នកក្រីក្រ ក៏លោកទទួលការតិះទៀនខ្លះដែរដោយអ្នកខ្លះឆ្ងល់ថាលោកបានលុយមកពីណាទៅជួយអ្នកក្រ? តើគាត់នេះទៅធ្វើអីបានបានលុយ? និងមានសំនួរជាច្រើនដែលនេះជាបញ្ហាដែលលោកបានជួប។ ប៉ុន្តែផ្ទុយទៅវិញលោកបានយកសំនួរទាំងនេះមករិះគិត អ្វីដែលគេនិន្ទាមិនមិនអាចធ្វើឲ្យលោកមិនចាប់អារម្មណ៍ជួយអ្នកក្រីក្របានទេ។

កាលពីថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ កន្លងទៅ លោក ផាន ប៉ូរ៉ា ទើបតែសាងសង់ផ្ទះជូនគ្រួសារក្រីក្រ១ខ្នងដែលមានទំហំ៤ម៉ែត្រគុណ៥ម៉ែត្រ ដែលមានសមាជិកក្នុងគ្រួសារ៦នាក់ ស្ថិតនៅភូមិថ្មល់កែង២ សង្កាត់កំពង់ចាមក្រុង ខេត្តកំពង់ចាម។

លោក ថា មូលហេតុដែរលោកធ្វើផ្ទះឲ្យគ្រួសារនេះ ដោយសារនៅពេលដែលលោកឆ្លងកាត់រោងចក្រនៅខេត្តកំពង់ចាម ឃើញគ្រួសារមួយនេះជួលបន្ទប់មួយតូចរស់នៅរហូតដល់ចំនួន ៦នាក់ ហើយរាល់ពេលភ្លៀងម្តងៗគឺទឹកភ្លៀងហូរចូលបន្ទប់ ហើយអ្នកខ្លះដេកក្រោមគ្រែ ខ្លះដេកលើគ្រែ។

អ្នកស្រី នូ ស៊ីនឿន អាយុ៤២ឆ្នាំ ជាកម្មករសំណង់ និងជាគ្រួសារដែលទទួលបានជួយសាងសង់ផ្ទះពីលោក ផាន់ ប៉ូរ៉ា បានឲ្យដឹងថា មួយថ្ងៃលោកស្រីរកចំណូលបាន៣ម៉ឺនរៀល តែប្រាក់ចំណូលនេះមិនអាចទប់ទល់នឹងការចំណាយប្រចាំថ្ងៃគ្រប់នោះទេ ព្រោះកូនទាំង៤នាក់របស់គាត់រៀនទាំងអស់គ្នា។ ដូច្នេះចំណូលរកបានផ្គត់ផ្គង់សម្រាប់ការចាយវាយហូបចុកប្រចាំថ្ងៃតែប៉ុណ្ណោះ។

អ្នកស្រី នូ ស៊ីនឿន បានប្រាប់ថា ៖ «នៅពេលដែរជួលបន្ទប់នៅក្បែររោងចក្រ ការរស់នៅរបស់លោកស្រីមានផលវិបាកជាខ្លាំងព្រោះរាល់ពេលមានភ្លៀងម្តងៗ ទឹកហូរចូលរហូត»។

កូនច្បងរបស់អ្នកស្រី នូ ស៊ីនឿន ទទួលបានអាហារូបករណ៍ពីអង្គការកុមារមេគង្គ រីឯប្តីអ្នកស្រី ជាអ្នកដើរបញ្ចូលហ្គាសនិងជួសជុលចង្រ្កានហ្គាស ដែលអាចរកចំណូលពេលខ្លះបានរហូតដល់១០ម៉ឺនរៀលឬតិចជាងនេះក៏មាន។

អ្នកស្រី នូ ស៊ីនឿន បានបង្ហាញនូវក្តីរីករាយជាខ្លាំងដែលមានសប្បុរសជន និងលោក ផាន់ ប៉ូរ៉ា ជួយសាងសង់ផ្ទះសម្រាប់គ្រួសាររបស់គាត់ ដែលចាប់ពីពេលនេះទៅអ្នកស្រីមានជំរកសមរម្យមួយនឹងគេ។

រីឯអ្នកស្រី លី សារ៉ាត អាយុ ៤២ឆ្នាំ ជាស្រ្តីមេម៉ាយ បានឱ្យដឹងដែរថា បន្ទាប់ពីផ្ទះគាត់ពុកផុយអស់ទៅ រូបគាត់និងកូនស្រីបានសុំផ្ទះគេស្នាក់នៅ ប៉ុន្តែក្រោយមកលោក ផាន់ ប៉ូរ៉ា ក៏ជួយទិញឈើនិងដែកជួយជួសជុលផ្ទះឱ្យរឹងមាំវិញ ទោះបីវាមិនធំតែគាត់សប្បាយចិត្តនិងមានភាពកក់ក្តៅខុសប្លែកពីនៅជាមួយគេ។







# យុវជនកាតូលិកកំពង់ធំ រិះគិតនិងចែករំលែក ពិសោធន៍ក្នុងរដូវអប់រំពិសេស



*អត្ថបទ៖ កក ស្រីនិ*

ព្រះវិហារគង្វាលដ៏សប្បុរស កំពង់រទេះ ខេត្តកំពង់ធំ នៃព្រះសហគមន៍ភូមិភាគបាត់ដំបង បានរៀបចំកម្មវិធីណែនាំដល់ក្រុមយុវជន ក្រោមប្រធានបទ «តើយើងត្រូវធ្វើអីខ្លះក្នុងរដូវអប់រំពិសេស? និងរិះគិតអំពីមហាសន្និបាតព្រះសហគមន៍សកល២០២១-២០២៣» ក្រោមការដឹកនាំដោយ កញ្ញា ម៉ារី ភ័ក្ត្រ កាលពីថ្ងៃទី១១-១៣ ខែមីនា ឆ្នាំ២០២២។

កញ្ញា ម៉ារីភ័ក្ត្រ ជាប្រធានយុវជនសម្រាប់ភូមិភាគបាត់ដំបងបានណែនាំអំពីរដូវអប់រំពិសេស ដោយលើក យកអំពីសារសម្តេចប៉ាប និងសារលើកទឹកចិត្តពីលោកអភិបាល ព្រមទាំងរិះគិតទាក់ទងទៅនឹងពិធីបុណ្យក្នុងរដូវអប់រំពិសេស។

ចំពោះកម្មវិធីនេះផងដែរ តាមរយៈសារលិខិតសម្តេចប៉ាបហ្វ្រង់ស៊ីស្កូ ម៉ារីភ័ក្ត្របានថ្លែងថា សម្តេចប៉ាបចង់ឮពីព្រះសហគមន៍ទាំងមូលអំពីអ្វីៗដែលកើតក្នុងព្រះសហគមន៍ និងតាមតំបន់នីមួយៗ តើយើងទាំងអស់គ្នាគួរធ្វើអ្វី ដើម្បីជួយឱ្យព្រះសហគមន៍កាន់តែប្រសើរ និងរីកចម្រើន?

អ្នកណែនាំ ម៉ារីភ័ក្រ បានឲ្យដឹងថា ក្នុងឱកាសយើងជួបជុំនេះ យើងស្តាប់ និងចែករំលែកបទពិសោធជាមួយគ្នា អំពីតួនាទីក្នុងការរៀបចំខ្លួននារដូវអប់រំពិសេសនេះ។ ក្នុងនោះដែរ ប្រធានយុវជនភូមិភាគរូបនេះ បន្ថែមថា អង្គពិធីគឺចង់ឲ្យ យុវជន ត្រិះរិះពិចារណា ពីរបៀបរស់នៅដើម្បីផ្សារភ្ជាប់ជាមួយព្រះយេស៊ូ តាមរយៈការរៀបចំចិត្តគំនិត ប្រុងស្មារតីដើម្បីបង្កើនទំនាក់ទំនងជាមួយព្រះជាម្ចាស់តាមការអធិដ្ឋាន និងធ្វើអំពើល្អ ដើម្បីបង្ហាញពីសេចក្តីស្រឡាញ់ យុត្តិធម៌ និងសាមគ្គីភាព។

យុវជន យុវនារី ទាំងនេះមកពី ព្រះសហគមន៍កំពង់គោ ព្រះសហគមន៍កំពង់រទេះ និងព្រះសហគមន៍ព្រែកស្បូវ។ នេះជាការប្រជុំតាមតំបន់ជាលើកទី២ ក្រោយពេលមានជំងឺកូវីដ-១៩ រាតត្បាតនៅក្នុងប្រទេសកម្ពុជា ដែលលើកទី១បានធ្វើតាមរយៈអនឡាញកាលពីអំឡុងខែកក្កដា ឆ្នាំ២០២១នេះ។

តាមការឱ្យដឹងពីយុវនារី យួន ណៃយ៉ាង ដែលសព្វថ្ងៃជាអ្នកឈ្វេងយល់ និងរៀនអប់រំជំនឿនៅព្រះវិហារគង្វាលដ៏សប្បុរស កំពង់រទេះ បានឱ្យដឹងថា «អ្វីដែលខ្ញុំទទួលបានក្នុងរយៈពេល២ថ្ងៃកន្លងមកនេះ ខ្ញុំនឹងយកមកអនុវត្តនៅក្នុងជីវិតរស់នៅប្រចាំថ្ងៃស្របតាមការណែនាំក្នុងសារលិខិតសម្តេចប៉ាបនោះ គឺត្រូវអធិដ្ឋានឱ្យបានច្រើន ប្រព្រឹត្តិអំពើល្អទៅកាន់អ្នកដទៃ និងមនុស្សជុំវិញខ្លួន ដោយកែប្រែទម្លាប់ មិនល្អឱ្យក្លាយទៅជាទម្លាប់ល្អឱ្យបានច្រើន។»

ណៃយ៉ាងបន្ថែមថា មួយទៀតយើងមិនត្រូវនឿយណាយក្នុងការប្រព្រឹត្តអំពើល្អដោយប្រឆាំងនឹងកាមតណ្ហា មិនត្រូវនឿយណាយនឹងការអធិដ្ឋាន និងទទួលអគ្គសញ្ញាស្រាយបាប។

ស្រដៀងគ្នានេះដែរ កញ្ញា ឈុំ គឹមអាន អាយុ១៨ឆ្នាំ ជាអ្នកឈ្វេងយល់ជំនឿដែរនោះ បានរៀបរាប់ថា «អ្វីដែលខ្ញុំចាប់អារម្មណ៍នោះគឺពាក្យ «នឿយណាយ» ដែលមានន័យចំពោះខ្ញុំ ដោយមិនត្រូវនឿយណាយក្នុងការអត់ធ្មត់ មិននឿយណាយក្នុងការស្រឡាញ់និងជួយអ្នកដទៃ ហើយនិងអធិដ្ឋានឱ្យបានច្រើន។»

គឹមអាន បន្ថែមថា «ខ្ញុំនឹងអនុវត្តនៅថ្ងៃព្រហស្បត្តិ៍ដោយចូលរួមតាំងព្រះកាយនិងអធិដ្ឋានដើរផ្លូវឈើឆ្កាងនៅថ្ងៃសុក្រ និងថ្ងៃអាទិត្យចូលរួមអភិបូជា ព្រមទាំងអធិដ្ឋានខ្លួនឯងមុនពេលចូលគេង និងធ្វើល្អទៅកាន់អ្នកដទៃ លើកលែងទោសឱ្យអ្នកដទៃ ហើយនិងចែករំលែកសម្ភារខ្លះៗ ឬក៏អ្វីផ្សេងទៀតទៅដល់អ្នកដទៃផងដែរ»។

ក្នុងពិធីជួបជុំរយៈពេលបីថ្ងៃនេះ លោកអភិបាល ទេព ច័ន្ទពិសិដ្ឋ អភិបាលព្រហសហគមន៍កាតូលិកភូមិភាគបាត់ដំបង បានអញ្ជើញចូលរួមជាអធិបតី នៅពេលរសៀលថ្ងៃអាទិត្យទី១៣ ផងដែរ ដើម្បីបិទកម្មវិធីអធិដ្ឋាន ដោយប្រោះទឹកព្រះពរ។ លោកអភិបាលក៏បាននិយាយលើកទឹកចិត្តដល់យុវជនទាំងអស់ក្នុងរដូវអប់រំពិសេស ដោយមាន៤ចំណុចសំខាន់ៗគឺ៖ ចូលរួមអធិដ្ឋាន ធ្វើទាន តមអាហារ និងចូលរួមជាមួយព្រះសហគមន៍គ្រប់សកម្មភាព៕

# ព្រះសហគមន៍ព្រែកទាល់មានបើកវគ្គ បំប៉នថ្នាក់ភាសាអង់គ្លេសសម្រាប់កុមារ

*អត្ថបទ៖ កក ស្រីនិ*

កុមារាកុមារីចំនួន១៥នាក់បានធ្វើដំណើរតាមទូក រៀងរាល់ថ្ងៃចន្ទដល់សុក្រដើម្បីមកសិក្សាបន្ថែមលើមុខវិជ្ជាភាសាអង់គ្លេស ដែលបង្កើតឡើងដោយព្រះសហគមន៍ព្រែកទាល់ ដែលមានទីតាំងនៅភូមិព្រែកទាល់ ឃុំកោះជាវាំង ស្រុកឯកភ្នំ ខេត្តបាត់ដំបង។

លោក ឈិត ប៊ុន លឹម ជាគ្រូបង្រៀនភាសាបរទេសបានមានប្រសាសន៍ថា ព្រះសហគមន៍បានបើកថ្នាក់បំប៉នភាសាអង់គ្លេសសម្រាប់កុមារអាយុចន្លោះពី១២ទៅ១៤ឆ្នាំ មានសិស្សសរុបចំនួន១៥នាក់ក្នុងនោះស្រី១០នាក់ និងប្រុស៥នាក់។ ការសិក្សានេះ បានរៀបចំឡើងនៅលើផ្ទះបណ្តែតទឹក តាមបណ្តោយបឹងទន្លេសាប ដែលចាប់ផ្តើមឡើងនៅម៉ោង៧ព្រឹក ដែលមានរយៈពេល៣ម៉ោងរាល់ថ្ងៃចន្ទដល់សុក្រ។





លោកគ្រូរូបនេះបានបន្ថែមទៀតថា លោកចាប់ផ្តើមបង្រៀនបំប៉នថ្នាក់ភាសាអង់គ្លេសនេះចាប់តាំងតែពីឆ្នាំ២០១៥មកម្ល៉េះ ដោយសារ តែក្មេងៗ ខ្លះរៀនដល់ ថ្នាក់ទី៩ទៅហើយ តែនៅមិនចេះអ្វីសោះ ដូច្នេះ ទើបបង្រៀនឱ្យពួកគាត់មានមូលដ្ឋានគ្រឹះខ្លះៗពីថ្នាក់ ខាងក្រោមទៅ។

លោកប៊ុនលឹមបានឲ្យដឹងថា៖ «សម្រាប់គ្រួសារដែលមានជីវភាពធូរធារមានជាកាណូត ឬក៏ទូកសម្រាប់ឱ្យកូនគេជិះមករៀន។ ក្មេងខ្លះទៀតក៏ចង់មករៀនដែរ ប៉ុន្តែដោយសារគ្មានអ្វីជិះ ព្រោះឪពុកម្តាយរបស់ពួកគាត់យកទូកទៅនេសាទ»។

កុមារា សៀង ឆេងហ័រ បានឱ្យដឹងថា គាត់បានមករៀនទីនេះមួយរយៈហើយ។ ជាសិស្សថ្នាក់ទី៦ ឆេងហ័រ បានឲ្យដឹងទៀតថា ៖ «ខ្ញុំនិងមិត្តភក្ត័អភិវឌ្ឍខ្លួនអាចចេះបានខ្លះគ្រាន់បើជាងកាលពីពេលមិនទាន់បានមករៀនទីនេះ»៕

# ព្រះសហគមន៍កាតូលិកកម្ពុជា ...

*បន្តពីទំព័រ-១៧*

បម្រើក្នុងគណៈកម្មការអប់រំជំនឿអីចឹងទៅ ហើយគណៈកម្មការនេះ ត្រូវការបំពាក់បំប៉នអំពីគរុកោសល្យនៃការអប់រំជំនឿ និងបច្ចេកទេសផ្សេងៗ។»

មុនកូវីដ-១៩ យើងធ្វើសិក្ខាសាលាម្រាប់អ្នកអប់រំជំនឿក្នុងមួយឆ្នាំម្តង ជាអន្តរភូមិភាគ ហើយតាមភូមិភាគ យើងធ្វើតាមសេចក្តីត្រូវការ ដោយផ្តោតសំខាន់លើបច្ចេកទេសនៃការអប់រំជំនឿ។

ប្រទេសកម្ពុជាស្ថិតនៅក្នុងប្រទេសបេសកកម្មមួយក្រោមក្រសួងប្រកាសដំណឹងល្អសម្រាប់ប្រជាជាតិទាំងឡាយរបស់សន្តអាសនៈនាទីក្រុងរ៉ូម។ ព្រះសហគមន៍កាតូលិកមានវត្តមាននៅក្នុងប្រទេសនេះ ក្នុងអំឡុងឆ្នាំ១៥៥៥ ប៉ុន្តែដោយសារអស្ថិរភាពនៅក្នុងប្រទេសជាពិសេសក្នុងរបបប្រល័យពូជសាសន៍ប៉ុលពត (១៩៧៥) ព្រះសហគមន៍ក៏ដូចជាសាសនានានាក្នុងប្រទេសត្រូវបានបំផ្លាញ ហើយបានងើបឡើងវិញក្នុងអំឡុងឆ្នាំ១៩៩០ ដោយមានគ្រីស្តបរិស័ទតិចតួចនៅសេសសល់។ រហូតមកដល់បច្ចុប្បន្ននេះ គ្រីស្តបរិស័ទកាតូលិក មានចំនួនប្រមាណជាង២ម៉ឺននាក់ ក្នុងចំណោមប្រជាជនជាង១៥លាននាក់៕



# សកម្មភាពនានារបស់ព្រះសហគមន៍កាតូលិកកម្ពុជា



## ព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ







## ព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង







## ព្រះសហគមន៍កាតូលិកភូមិភាគកំពង់ចាម



